សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences  Économiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការសុំកូននៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ   កញ្ញា **ណាន ភូឡាប**
កញ្ញា **ខូច ស្រីមុំច**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ទូរ សុខុម៉ា**

បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

៙

នាងខ្ញុំឈ្មោះ **ណាន កូឡាប** និង **ខុង ស្រីមុំច** ជានិស្សិតបរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈ ក្រុមP4C5 ជំនាន់ទី១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំសិក្សា ២០២០-២០២១។

សូមថ្លែងអំណរគុណ និងសម្តែងនូវកតញ្ញូធម៌ការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

+ លោកឪពុក អ្នកម្តាយ ទាំងពីរដែលលោកជាអ្នកមានគុណយ៉ាងធំធេងចំពោះកូនដ៏មានតម្លៃពុំអាចកាត់ថ្លៃបាន ព្រោះលោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សារូបកូនៗតាំងពីកូននៅក្នុងផ្ទៃឧទរនូវឡើយ ហើយនៅពេលដែលកូនធំដឹងក្តីបន្តិចឡើង លោកទាំងពីរបានទូន្មានអប់រំប្រៀនប្រដៅ ដាស់តឿនកូនឲ្យប្រព្រឹត្តិតែអំពើល្អសេពគប់មិត្តភក្តិល្អជាដើម ម្យ៉ាងវិញទៀតលោកបានខិតខំធ្វើការទាំងថ្ងៃក្តៅ ថ្ងៃរងារត្រជាក់សព្វបែបយ៉ាង ដើម្បីបានថវិការយកមកទំនុកបម្រុងការសិក្សារបស់កូន ព្រមទាំងផ្តល់ការស្រលាញ់ ការថ្នាក់ថ្នមភាពកក់ក្តៅ និងការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរដល់កូនៗទាំងអស់គ្នា ទាំងនេះគឺជាមហាគុណដ៏ធំធេង ដែលកូនពុំអាចបំភ្លេចបានឡើយក្នុងជីវិតរបស់កូន។

+ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យគ្រប់រូប នៃសាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ដោយទំនួលខុសត្រូវយ៉ាងខ្ពង់ខ្ពស់ ចំពោះការសិក្សារបស់និស្សិតទាំងអស់ ដោយលោកពុំគិតពីបញ្ហាការនឿយហត់អ្វីឡើយផ្ទុយទៅវិញលោកខំដាស់តឿន ទូន្មាន អប់រំសិស្សនិស្សិតអោយខិតខំប្រឹងប្រែងសិក្សា ស្វែងរកចំណេះវិជ្ជាមកដាក់ខ្លួន និងពង្រឹងខ្លួនឯងធ្វើយ៉ាងណាឲ្យជាមនុស្សម្នាក់ដែលមានសមត្ថភាពពេញលេញដែលសង្គមគេត្រូវការជាដើម ។ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យគ្រប់រូប ក៏តែងតែខិតខំប្រឹងប្រែងក្នុងការសិក្សាស្រាវជ្រាវ រិះរកបកគំហើញថ្មីៗបន្ថែមដើម្បីផ្ទេរនូវពុទ្ធិ និងបទពិសោធដ៏ល្អៗដល់សិស្សនិស្សិតគ្រប់ៗគ្នាផង ។

+ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បណ្ឌិត **ទូរ សុខុម៉ា** ដែលជាសាស្ត្រាចារ្យណែនាំរបស់យើងខ្ញុំទាំងពីរនាក់ ដែលលោកតែងតែផ្តល់នូវគន្លឹះ ទ្រឹស្តី និងការអនុវត្តក្នុងការសិក្សាស្វែងយល់លើប្រធានបទរបស់យើងខ្ញុំ សាស្ត្រាចារ្យមិនដែលរអ៊ូរទាំ ឬមានភាពធុញទ្រាន់ចំពោះការផ្តល់នូវគំនិតយោបល់អ្វីឡើយ បើទោះបីមានការនឿយហត់ក្នុងការបំពេញការងារ យ៉ាងណាក្តីក៏សាស្ត្រាចារ្យនៅតែផ្តល់ស្នាមញញឹម ហើយសប្បាយចិត្តពេលដែលឃើញសិស្សនិស្សិតខិតខំសិក្សាស្រាវជ្រាវឯកសារនានាដែលពាក់ព័ន្ធទៅលើប្រធានបទ សាស្ត្រាចារ្យថែមទាំងព្យាយាមពន្យល់ណែនាំ និងប្រាប់នូវបទពិសោធល្អៗ ព្រមទាំងវិធីសាស្ត្រផ្សេងៗដែលទាក់ទងនិងការសិក្សាស្រាវជ្រាវផងដែរ ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់សូមជូនពរឲ្យលោកឪពុក អ្នកម្ដាយ ឯកឧត្តមសាកលវិទ្យាធិការ ឯកឧត្តមសាកលវិទ្យាធិការរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តនិស្សិត និងបុគ្គលិកដែលបម្រើការងារនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់មានតែសុខភាពល្អ សម្រេចបានជោគជ័យគ្រប់ភារកិច្ច និងសូមឲ្យសមប្រកបជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីក្លាយជាសការៈដទៃឡើយ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១

ត្រូវនឹងថ្ងៃ២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

# អារម្ភកថា

៚៙

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាសាកលវិទ្យាល័យមួយដែលបានផ្តល់នូវជម្រកកក់ក្តៅដល់នាងខ្ញុំ **ឈាន ភូឡាប** និង **ខូច ស្រីម៉ិច** រយៈពេលបួនឆ្នាំក្នុងការសិក្សាបរិញ្ញាបត្ររដ្ឋបាលសាធារណៈ ក្រៅពីការណែនាំ អប់រំ ទូន្មាន ប្រៀនប្រដៅ ពីសំណាក់លោកឪពុក អ្នកម្តាយ ដែលជាគ្រូដំបូងរបស់យើងខ្ញុំ ឬ/និងជាគ្រូទីមួយ ដែលផ្តល់នូវការដាស់តឿន បង្ហាត់បង្រៀន បង្ហាញផ្លូវល្អ ហើយយើងខ្ញុំពិតជាមានសំណាងដែលបានមកសិក្សាបន្តនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលជាសាកលវិទ្យាល័យមួយដែលយើងខ្ញុំប៉ងប្រាថ្នាថាពេលបញ្ចប់មធ្យមសិក្សាទុតិយភូមិ យើងខ្ញុំនឹងមកបន្តការសិក្សានៅទីនេះ ឥឡូវបំណងប្រាថ្នារបស់យើងខ្ញុំបានសម្រេច ហើយពិតជាមានភ័ព្វសំណាងណាស់ដែលបានមកជួបសាស្ត្រាចារ្យដែលមានចំណេះដឹង បទពិសោធន៍ ក្រមសីលធម៌ខ្ពស់ ក្នុងការបង្ហាត់បង្រៀន ការផ្ទេរនូវពុទ្ធិ ចែករំលែកនូវចំណេះដឹង និងការដាស់តឿនប្រកបដោយវិជ្ជាជីវៈហើយពុំដែលគិតពីការលំបាកភាពនឿយហត់អ្វីឡើយ។

នៅក្នុងផ្នែកមួយនៃការសិក្សាបរិញ្ញាបត្ររដ្ឋបាលសាធារណៈបួនឆ្នាំ យើងខ្ញុំចាប់អារម្មណ៍លើប្រធានបទមួយដែលទាក់ទងទៅនឹង នីតិវិធីនៃការសុំកូននៅកម្ពុជា ដែលយើងខ្ញុំយល់ថា ការសុំកូនគឺជាប្រធានបទដ៏ពេញនិយមមួយសម្រាប់មនុស្សបច្ចុប្បន្ន ដែលអាចជួយដល់កុមារកំព្រាគ្មានទីពឹង កុមារក្រីក្រ ជាច្រើនលាននាក់ឲ្យមានអនាគតល្អ ជួយដល់អ្នកដែលចង់បានកូនយកទៅចិញ្ចឹមឲ្យគ្រួសារកាន់តែមានសុភមង្គល និងជួយដល់ប្រទេសជាតិឲ្យមានការអភិវឌ្ឍន៍ និងសម្បូរទៅដោយធនធានមនុស្ស ដែលការសុំកូននេះកើតមាននៅក្នុងប្រទេសជាច្រើនទូទាំងសាកលលោករួមមានទាំងកម្ពុជាផងដែរ។ ម្យ៉ាងវិញទៀតដោយសារតែនៅប្រទេសកម្ពុជាយើងប្រឈមនឹងបញ្ហាមួយចំនួនដូចជា ការជួញដូរកុមារ ការយកកុមារទៅចិញ្ចឹមដោយខុសច្បាប់ ការប្រើកម្លាំងពលកម្ម និងប្រើអំពើហិង្សាលើកុមារ ដែលទាំងនេះគឺជាអំពើអមនុស្សធម៌ រំលោភសិទ្ធិកុមារធ្ងន់ធ្ងរ ដូច្នេះហើយវាបង្កឲ្យមានភាពភ័យខ្លាច អសុវត្ថិភាព អសន្តិសុខសង្គម ដែលបង្កជាផលប៉ះពាល់ខ្លាំងណាស់ដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋ។

ហេតុនេះហើយបានជាយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទ "នីតិវិធីនៃការសុំកូននៅកម្ពុជា" មកធ្វើជាការសិក្សាស្រាវជ្រាវដើម្បីបានជាគន្លឹះ ឯកសារ និងចំណេះដឹងបន្ថែមដល់និស្សិតជំនាន់ក្រោយៗបន្តទៀត។

បើទោះបីជាខ្លឹមសារទាំងស្រុងនៅក្នុងសៀវភៅសារណា ឬរបាយការណ៍កម្មសិក្សានេះមានការពិនិត្យយ៉ាងណាក្តី យើងខ្ញុំគិតថាវានៅតែមាននូវចំណុចខ្វះខាតមួយចំនួន និងមានន័យខុសឆ្គង ឬ/និងអាចថាខុសនូវអក្ខរាវិរុទ្ធខ្លះដោយអចេតនា ឬការភ្លាំងភ្លេចខ្លះ ជាក់ជាមិនខានឡើយ តែទោះបីជាយ៉ាងណា យើងខ្ញុំទាំងពីរនាក់សូមទទួលនូវមតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ មិត្តអ្នកអាន មិត្តនិស្សិត ទាំងអស់គ្នា ដើម្បីឲ្យការសិក្សាស្រាវជ្រាវក្រោយទៀតកាន់តែមានភាពសុក្រិត និងល្អប្រសើរហើយទទួលបានផលប្រយោជន៍ច្រើនដល់មិត្តអ្នកអាន និងមិត្តនិស្សិតជំនាន់ក្រោយៗទៀត ។ សូមអរគុណ!!!

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**......................................................................................................១
១. លំនាំបញ្ហានៃការស្រាវជ្រាវ ......................................................................................១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ..................................................................................២
៣. គោលបំណងនៃការស្រាវជ្រាវ ....................................................................................២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ..........................................................................៣
៥. សារៈសំខាន់នៃការស្រាវជ្រាវ......................................................................................៣
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ.............................................................................................៤
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ...........................................................................................៥

# ជំពូក១

# មូលដ្ឋានច្បាប់នៃការសុំកូន

**១.១ ការកំណត់និយមន័យ** ........................................................................................ ៦
**១.២ ទិដ្ឋភាពទូទៅនៃការសុំកូន** ....................................................................................... ៧
**១.៣ បទដ្ឋានគតិយុត្តនៃការសុំកូន**......................................................................................... ៧
១.៣.១ លក្ខខណ្ឌកំណត់ដើម្បីបង្កើតការសុំកូន............................................................................... ៨
១.៣.១.១ លក្ខខណ្ឌសុំកូនពេញលេញ ...................................................................................... ៨
១.៣.១.២ លក្ខខណ្ឌសុំកូនធម្មតា................................................................................................១១
១.៣.១.៣ លក្ខខណ្ឌសុំកូនអន្តរប្រទេស ...................................................................................... ១៣
១.៣.២ អានុភាពនៃការសុំកូន ..........................................................................................................១៥
១.៣.២.១ អានុភាពនៃការសុំកូនពេញលេញ.................................................................................១៥
១.៣.២.២ អានុភាពនៃការសុំកូនធម្មតា .......................................................................................១៧
១.៣.២.៣ អានុភាពនៃការសុំកូនអន្តរប្រទេស ............................................................................. ១៨
**១.៤ ទោសបញ្ញត្តិ**.........................................................................................................................១៩

# ជំពូក២
# នីតិវិធីតុលាការនៃការសុំកូន

**២.១ រចនាសម្ព័ន្ធនៃស្ថាប័នតុលាការ** .......... ២១
**២.២ នីតិវិធីនៃការសុំកូន** .......... ២៤
២.២.១ នីតិវិធីតុលាការចំពោះការបង្កើតសុំកូនពេញលេញ .......... ២៤
២.២.២ នីតិវិធីតុលាការចំពោះការបង្កើតសុំកូនធម្មតា .......... ២៧
២.២.៣ នីតិវិធីនៃការកាត់កាល់សុំកូន .......... ២៨
២.២.៤ នីតិវិធីសុំកូនអន្តរប្រទេស .......... ២៩
**២.៣. ការសុំកូនក្រៅនីតិវិធី** .......... ៣៧

# ជំពូក៣
# ការវិភាគទិន្នន័យ

**៣.១ វិភាគលក្ខខណ្ឌច្បាប់ក្នុងករណីសុំកូន** .......... ៣៩
៣.១.១. សុំកូនពេញលេញ .......... ៣៩
៣.១.២ សុំកូនធម្មតា .......... ៣៩
**៣.២ វិភាគនីតិវិធីនៅក្នុងការសុំកូន** .......... ៤០
**៣.៣ ចំណុចខ្លាំង និងចំណុចខ្សោយ** .......... ៤១
**សេចក្ដីសន្និដ្ឋាន** .......... ៤៣
**អនុសាសន៍** .......... ៤៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

រដ្ឋជាច្រើននៅក្នុងពិភពលោកមានករណីសុំកូនចិញ្ចឹម ក្នុងនោះផងដែរកម្ពុជាក៏កើតមាននូវករណីកូនចិញ្ចឹម ឬកូនសុំនេះផងដែរ វាក្លាយទៅជាវប្បធម៌មួយដែលកើតមានឡើងតាំងពីយូរលង់ណាស់មកហើយ គ្រាន់តែនីតិវិធីនៃការសុំនោះខ្លះត្រឹមត្រូវតាមលក្ខណៈច្បាប់ ហើយខ្លះនោះក៏ពុំត្រឹមត្រូវតាមលក្ខណៈច្បាប់ ។ បញ្ហានេះយើងត្រូវសង្កេតទៅមើលលើច្បាប់នីតិវិធីនៃការសុំកូន ដែលពីមុនយើងមានច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ក៏ប៉ុន្តែវាពុំទាន់គ្រប់ជ្រុងជ្រោយនៅឡើយទេ ពោលគឺ គោលការណ៍សុំកូនអន្តរប្រទេសគ្មានចែងជាដើម ។

បច្ចុប្បន្ន ដោយសារការយកចិត្តទុកដាក់ទៅលើកុមារពីសំណាក់ប្រជាជនខ្មែរ ជាពិសេសគឺ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់សច្ចាប័នកាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ ក្នុងអនុសញ្ញាស្តីពី សិទ្ធិកុមារ និងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិរបស់កុមារ ។ ជាមួយគ្នានេះដែរ ដោយយល់ឃើញថា កុមារ គឺពិតជាមានសារៈសំខាន់ជាទំពាំងស្នងឬស្សី ពាក់ព័ន្ធនឹងសុំកូននេះ រដ្ឋបានចងក្រងច្បាប់ស្តីពី សុំកូនធម្មតា សុំកូនពេញលេញ[១] និងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ដែលចែងពីសិទ្ធិរបស់កូនសុំ ពោលគឺបញ្ញត្តិអំពីលទ្ធភាពរបស់អ្នកសុំ ដើម្បីថែរក្សាកូនសុំនេះឲ្យបានត្រឹមត្រូវ ។ ចំពោះប្រធានបទ នីតិវិធីនៃការសុំកូននៅកម្ពុជា គឺជាប្រធានបទមួយដែលមានសារៈសំខាន់ណាស់សម្រាប់សិស្សនិស្សិតទូទៅក្នុងការសិក្សាស្រាវជ្រាវ ស្វែងយល់ ពង្រឹងនូវពុទ្ធិ ជាពិសេសសម្រាប់ប្រជាពលរដ្ឋទាំងក្នុង និងក្រៅប្រទេសដែលមានបំណងចង់បានកូនយកទៅចិញ្ចឹមដោយស្របតាមនីតិវិធីច្បាប់ ហើយកាន់តែមានសារៈសំខាន់ថែមទៀតចំពោះសុវត្ថិភាព សុខុមាលភាព ការធានា ការអប់រំ និងអនាគតរបស់កុមារ ដែលជួយឲ្យកុមារកម្ពុជាកាន់តែទទួលបាននូវការមើលថែដិតដល់ពីសំណាក់ឪពុកម្តាយចិញ្ចឹម ដែលមានលទ្ធភាពគ្រប់គ្រាន់តាមផ្លូវច្បាប់ ឲ្យពួកគេមានចំណេះដឹងជ្រៅជ្រះ និងជីវិតកាន់តែភ្លឺត្រចះត្រចង់។ ទន្ទឹមនឹងការកកើតមាននៃនីតិវិធីនេះ កម្ពុជាក៏ធ្លាប់បាន និងកំពុងតែបន្តកើតមាននូវសកម្មភាពមួយចំនួនដែលផ្ទុយនឹងច្បាប់នេះ ដូចជាការយកកូនទៅចិញ្ចឹមតាមរយៈការសុំដែលធ្វើឡើងជាលក្ខណៈបុគ្គល គ្មានការទទួលដឹងលឺពីច្បាប់ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ ការរំលោភសិទ្ធិកុមារ ការប្រើអំពើហិង្សាលើកុមារ ការញុះញង់ ការបង្ខិតបង្ខំឲ្យផ្តល់កូន ការប្រើលុយដើម្បីទាក់ទាញយកកុមារមកចិញ្ចឹមជាដើម។

ទោះបីជាមានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល និងច្បាប់ការពារក្នុងករណីសុំកូនក៏ដោយក៏នៅតែមានករណីយកកូនមកចិញ្ចឹម មិនត្រឹមត្រូវតាមច្បាប់ ក្នុងន័យជាប្រយោជន៍អាពាហ៍ពិពាហ៍ ឬជាប្រយោជន៍ទាញយកកម្លាំង ដោយការធ្វើពលកម្មលើកុមារដើម្បីទាញយកកម្រៃ ឬដើម្បីឲ្យកុមារធំឡើងមើលថែខ្លួនពេលចាស់ជរា ។

---

[១] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ដូច្នេះ តើប្រធានបទខាងលើនេះនឹងរួមចំណែកអ្វីខ្លះសម្រាប់ការការពារផលប្រយោជន៍អ្នកសុំកូន អ្នកផ្តល់កូនសុំ និងកូនសុំ?

តើប្រធានបទនេះនឹងអាចមានប្រយោជន៍អ្វីខ្លះសម្រាប់សង្គមជាតិទាំងមូល?

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

យោងតាមលំនាំបញ្ហាខាងលើ យើងឃើញថានៅក្នុងករណីនៃការសុំកូននេះ នៅតែមានបញ្ហាជាច្រើនកើតឡើងជុំវិញមូលហេតុ នៅក្នុងការយកកូនមកចិញ្ចឹមមិនព្រមអនុវត្តតាមនីតិវិធីច្បាប់ ដោយគេចវេសពីការបង់ពន្ធ ការឆ្លងកាត់នីតិវិធីដ៏ស្មុគស្មាញ និងចំណាយអស់ថវិកាច្រើន។ ម្យ៉ាងទៀត ប្រជាពលរដ្ឋនៅតែពុំសូវយកចិត្តទុកដាក់ទៅលើបញ្ហានេះ ដោយសារតែជីវភាពក្រីក្រ និងគ្មានចំណេះដឹងជ្រៅជ្រះជាដើម ជាហេតុធ្វើឲ្យពួកមេខ្យល់ដែលជាជនខិលខូច មានឱកាសងាយស្រួលក្នុងការញុះញង់ដល់ឪពុកម្តាយបង្កើត ឬអាណាព្យាបាលរបស់កុមារ ឲ្យផ្តល់កូនឱ្យខ្លួនយកទៅចិញ្ចឹមដោយធានាយ៉ាងមុតមាំពីការមើលថៃយ៉ាងយកចិត្តទុកដាក់ ដែលផ្តល់ឲ្យកុមារនូវអនាគតមួយដែលល្អប្រសើថែមទៀតផង ហើយពួកគេផ្តល់ត្រឹមតែលុយបន្តិចបន្តួចតែប៉ុណ្ណោះ។ លើសពីនេះទៅទៀត មេខ្យល់បានលក់កុមារដូចជាទំនិញនៅលើទីផ្សារទៅឲ្យជនទីបីក្នុងតម្លៃខ្ពស់បំផុត ហើយអ្វីដែលគួរឲ្យខ្លាចនិងជាបញ្ហាចោទធ្ងន់នោះគឺ ជនដែលទិញកុមារយកទៅចាត់ទុកកុមារដូចជាទាសករ ដោយការរំលោភបំពានទាំងផ្លូវកាយ និងផ្លូវចិត្ត។

តើអ្វីជាបញ្ហា នៅក្នុងនីតិវិធីសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា?

តើធ្វើដូចម្តេចដើម្បីឲ្យប្រជាជនមានការយល់ដឹងក្នុងនីតិវិធីនៃការសុំកូនត្រឹមត្រូវស្របតាមច្បាប់?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះគោលបំណងនៃការស្រាវជ្រាវលើប្រធានបទនេះ ដោយរូបនាងខ្ញុំបានមើលឃើញពីបញ្ហាមួយចំនួនៈ

ទី១ ដើម្បីសិក្សាស្វែងយល់អំពីបទបញ្ញត្តិផ្សេងៗក្នុងការសុំកូនទៅតាមនីតិវិធីផ្លូវច្បាប់

ទី២ ដើម្បីសិក្សាស្វែងយល់ពីការអនុវត្តជាក់ស្តែងនៃច្បាប់ស្តីពីការសុំកូន

ទី៣ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់សិទ្ធិកុមារ ជួយដល់កុមារកម្ពុជា ដែលកំព្រាគ្មានឪពុកម្តាយ ក្រីក្រលំបាក គ្មានចំណេះដឹង រងនូវការគាបសង្កត់ អត់ឃ្លាន ការប្រើអំពើហិង្សា ឬការធ្វើពលកម្ម ឲ្យក្រុមកុមារទាំងនោះបានទៅរស់នៅជាមួយឪពុកម្តាយចិញ្ចឹមដោយស្របច្បាប់ ទទួលបានការមើលថែ សិក្សាអប់រំ និងមានអនាគតល្អ។

ទី៤ ដើម្បីទុកជាស្នាដៃសម្រាប់សិស្សនិស្សិតជំនាន់ក្រោយ គ្រាន់ជាផ្នែកមួយជំនួយក្នុងការសិក្សាស្រាវជាវដែលទាក់ទងជាមួយប្រធានបទខាងលើ ឲ្យកាន់តែមានភាពងាយស្រួលមួយកម្រិតទៀត។

ចំពោះប្រធានបទខាងលើនេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះសិស្សនិស្សិត អ្នកសិក្សាស្រាវជ្រាវ និងសាធារណៈជនគ្រប់រូប ដើម្បីជាជំនួយផ្នែកពុទ្ធិ ស្មារតីឲ្យកាន់តែច្បាស់ និងស៊ីជម្រៅថែមមួយកម្រិតទៀត។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ទំហំនៃការសិក្សាស្រាវជ្រាវនេះ វាទាក់ទងជាមួយនឹង ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ក្នុងគន្ថីទី៧ ជំពូកទី៤ ផ្នែកទី២ នៃមាត្រា១០០៧ ដល់មាត្រា១០១៩ ដែលស្តីអំពីសុំកូនពេញលេញ និងមាត្រា ១០២០ ដល់មាត្រា១០៣០ ស្តីអំពីសុំកូនធម្មតា ច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩ អង្គការសិទ្ធិកុមារយូនីសេហ្វ ( Unicef ) អង្គការការពារសិទ្ធិមនុស្សនៅកម្ពុជា (CCHR) អង្គការសិទ្ធិមនុស្សលីកាដូ(LICADHO) សមាគមអាដហុក(ADHOC) គណកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អង្គការតម្លាភាពកម្ពុជា និងអង្គការ សមាគមផងត្នោតជាដើម។ ដោយប្រធានបទខាងលើនេះមានភាពស៊ីជម្រៅនឹងការសុំកូន និងការការពារសិទ្ធិកុមារ ដូច្នេះខ្លឹមសារនៃប្រធានបទនេះផ្តោតសំខាន់ទៅលើ ៖

ទី១ ទាក់ទងទៅនឹងវិធានគតិយុត្តនៃការសុំកូន

ទី២ ទាក់ទងទៅនឹងលទ្ធផលនៃការស្រាវជ្រាវ

ទី៣ ការពិភាក្សាទៅលើប្រធានបទដែលបានស្រាវជ្រាវ

ចំពោះដែនកំណត់នៃការស្រាវជ្រាវលើប្រធានបទនេះ តើវិធានគតិយុត្តនៃការសុំកូនមានសារៈសំខាន់អ្វីខ្លះ តើមានអានុភាពគតិយុត្តយ៉ាងដូចម្តេច តើគួរពិភាក្សាដេញដោលគ្នាលើប្រធានបទនេះត្រង់ចំណុចណាខ្លះ និងផ្តល់ផលប្រយោជន៍អ្វីខ្លះ?

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃប្រធានបទដែលយើងខ្ញុំលើកមកសិក្សាស្រាវជ្រាវជាទូទៅ គឺគិតពិចារណាលើចំណុចមួយចំនួន៖

សារៈសំខាន់ចំពោះសង្គមជាតិ ពង្រឹងគោលនយោបាយរបស់រដ្ឋាភិបាលក្នុងគោលដៅមនុស្សធម៌សុទ្ធសាធ ដើម្បីរកគ្រួសារល្អឲ្យកុមារនិងធានាឧត្តមភាព ប្រយោជន៍របស់កុមារ ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាមួយប្រទេសនានាដើម្បីទប់ស្កាត់ការជួញដូរកុមារ ជួយសម្រាលបន្ទុកដល់អាជ្ញាធរសាធារណៈក្នុងការថែទាំចំពោះកុមារដែលគ្មានគ្រួសារ និងគ្មានមធ្យោបាយទ្រទ្រង់ជីវិត។ ម្យ៉ាងវិញទៀតក៏អាចជួយសម្រាលរដ្ឋចំពោះការចំណាយក៏ដូចជាការជួយឧបត្ថម្ភផ្សេងៗ ក្នុងការចិញ្ចឹមបីបាច់ទារក ឬកុមារកំព្រាដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា លើសពីនេះទៅទៀតប្រសិនបើទារក ឬកុមារកំព្រាទាំងនោះមិនថាស្រី ឬប្រុសឡើយចម្រើនវ័យធំធាត់ដែលមានអាយុ ១៧(ដប់ប្រាំពីរ) ឆ្នាំ ឡើងទៅពុំមានលទ្ធភាពសិក្សាទៅមុខទៀតបាន រដ្ឋត្រូវដោះស្រាយរកការងារឲ្យធ្វើតាមសមត្ថភាពជាក់ស្តែង។ ក្នុងករណីមានរៀបអាពាហ៍ពិពាហ៍ត្រូវបានអង្គភាពរដ្ឋអំណាច រាជធានី និងអង្គការមហាជនបង្កលក្ខណៈខាងស្មារតី និងសម្ភារៈ។

សារៈសំខាន់ចំពោះប្រព័ន្ធច្បាប់នៅកម្ពុជា ធ្វើឲ្យប្រព័ន្ធច្បាប់នៅកម្ពុជាកាន់តែមានលំនឹង ប្រជាពលរដ្ឋកាន់តែមានទំនុកចិត្ត ការអនុវត្តបានយ៉ាងខ្ជាប់ខ្ជួននិងកាន់តែមានភាពល្អប្រសើរ ប្រព័ន្ធច្បាប់កាន់តែមានភាពរីកចម្រើនដើរទាន់សម័យកាលសង្គមលោកដ៏ទំនើបមួយនេះ។

សារៈប្រយោជន៍ចំពោះការការពារសិទ្ធិ និងផលប្រយោជន៍របស់កុមារនៅកម្ពុជាតាមរយៈការបង្កើតឲ្យមានគ្រួសារនិម្មិតថ្មីមួយដែលមានលក្ខណៈដូចគ្រួសារពីធម្មជាតិ និងមានលក្ខខណ្ឌរស់នៅប្រសើរជាងគ្រួសារដើម ព្រមទាំងកាត់ផ្តាច់ទាំងស្រុងនូវទំនាក់ទំនងញាតិ អំណាចមេបា និងសិទ្ធិផ្សេងទៀតដែលកើតមានតាមទំនាក់ទំនងញាតិ។

សារៈសំខាន់ចំពោះរូបនាងខ្ញុំផ្ទាល់ បន្ថែមចំណេះដឹងដល់រូបនាងខ្ញុំទាំងពីរឲ្យកាន់តែទូលំទូលាយជាងមុន និងយល់កាន់តែច្បាស់អំពីដំណើរការនៃការសុំកូនថាតើយើងត្រូវប្រើនូវនីតិវិធីដូចម្តេចខ្លះ អាចឲ្យនាងខ្ញុំរកឃើញផលអវិជ្ជមានជាច្រើនដែលកើតមានឡើងពីការសុំកូនខុសច្បាប់ ហើយនឹងរិះរកមធ្យោបាយបែបណាដើម្បីកុំឲ្យមានករណីនេះកើតឡើងបន្តទៀត បន្ទាប់ពីបានធ្វើការស្រាវជ្រាវលើប្រធានបទនេះរួចមកនាងខ្ញុំសង្ឃឹមថានាងខ្ញុំទាំងពីរនាក់នឹងអាចយកចំណេះដឹងនេះទៅចែកជូនដល់ប្រជាពលរដ្ឋឲ្យបានកាន់តែទូលំទូលាយ និងចៀសផុតពីការចាញ់បោកគេ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ទិន្នន័យដែលបានស្រាវជ្រាវ គឺយកមកវិភាគតាមរយៈពិពណ៌នាបែបគុណភាព ដើម្បីទទួលបាននូវលទ្ធផលនៃការស្រាវជ្រាវនេះ មានលក្ខណៈវិទ្យាសាស្ត្រ និងកម្រិតនៃការជឿជាក់អាចទទួលយកបាន ដោយប្រើទិន្នន័យទីមួយ ( Primary Data ) និងទិន្នន័យទីពីរ ( Secondary Data ) បូករួមបញ្ចូលគ្នា។

- ទិន្នន័យទីមួយ ជាប្រភេទទិន្នន័យផ្ទាល់( Primary Data ) សាកសួរទៅកាន់សាស្ត្រាចារ្យជំនាញ តាមរយៈទូរស័ព្ទ និងបានសួរសំណួរដោយផ្ទាល់ទៅកាន់គ្រួសារជនជាតិខ្មែរពីរគ្រួសារ ដែលធ្លាប់បានសុំកូនក្នុងប្រទេសយកមកចិញ្ចឹម ។
- ទិន្នន័យទីពីរ ( Secondary Data ) បានមកពីការដកស្រង់ខ្លឹមសារសំខាន់ៗ ច្បាប់ និងបទដ្ឋានគតិយុត្តនានា សៀវភៅរបាយការណ៍របស់អង្គការលីកាដូ សៀវភៅសារណារបស់សិស្សច្បងមុនៗ សៀវភៅរបស់សាស្ត្រាចារ្យ យកមកពីបណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបណ្ណាល័យផ្សេងៗទៀត តាមរយ: Google Website និង Youtube ជាដើម។

បន្ទាប់ពីទទួលបានទិន្នន័យរួច យើងខ្ញុំបានយកមកធ្វើការវិភាគដោយស្វែងរកចំណុចដូច និងចំណុចផ្ទុយ រួចយកមកធ្វើការវែកញែកស្វែងរកចំណុចខ្លាំង ចំណុចខ្សោយ គុណសម្បត្តិ និងគុណវិបត្តិ រួចហើយចុងក្រោយ ទើបទទួលបាននូវទិន្នន័យរួមមួយដែលជាទិន្នន័យជាក់លាក់ យកមកធ្វើការពិពណ៌នា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះរចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះត្រូវបានចែកចេញជាសេចក្ដីផ្ដើម និង៣ជំពូកគឺ៖

សេចក្ដីផ្ដើមនិយាយអំពី ៖ លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ និងរចនាសម្ព័ននៃការស្រាវជ្រាវ។

ជំពូក១ ៖ មូលដ្ឋានច្បាប់នៃការសុំកូន បរិយាយអំពី ការគំណត់និយមន័យ ទិដ្ឋភាពទូទៅនៃការសុំកូន បទដ្ឋានគតិយុត្ត លក្ខខណ្ឌកំណត់ដើម្បីបង្កើតការសុំកូនពេញលេញ ការសុំកូនធម្មតា ការសុំកូនអន្តរប្រទេស អានុភាពនៃការសុំកូនពេញលេញ សុំកូនធម្មតា សុំអន្តរប្រទេស និងទោសបញ្ញត្តិ។

ជំពូក២ ៖ នីតិវិធីរដ្ឋបាលនៃការសុំកូន បរិយាយអំពីរចនាសម្ព័ន្ធតុលាការ នីតិវិធីតុលាការចំពោះការបង្កើតសុំកូនពេញលេញ សុំកូនធម្មតា នីតិវិធីនៃការកាត់កាល់សុំកូន នីតិវិធីសុំកូនអន្តរប្រទេស និងការសុំកូនក្រៅនីតិវិធី ។

ជំពូក៣ ៖ ការវិភាគទិន្នន័យ ពិភាក្សាលើ វិភាគលក្ខខណ្ឌច្បាប់ក្នុងករណីសុំកូន វិភាគនីតិវិធីនៅក្នុងការសុំកូន ចំណុចខ្លាំង និងចំណុចខ្សោយ។

# ជំពូក១

# មូលដ្ឋានច្បាប់នៃការសុំកូន

## ១.១ ការកំណត់និយមន័យ

**សុំកូន** គឺជាកិច្ចសន្យាដែលចងបុគ្គលពីរនាក់ ដែលម្នាក់ហៅថាឪពុក ឬម្ដាយចិញ្ចឹម ហើយម្នាក់ទៀតហៅថាកូនចិញ្ចឹម ឲ្យមានចំណងនឹងគ្នាដូចជាកូនដែលមានខាន់ស្លាដែរ។

**សុំកូនពេញលេញ** គឺជាការសុំកូនរបស់អ្នកដទៃយកមកចិញ្ចឹមដោយស្របច្បាប់ និងធ្វើឡើងតាមផ្លូវតុលាការដោយទាមទារឲ្យផ្ដាច់ទំនាក់ទំនងញាតិ និងទំនាក់ទំនងគតិយុត្ត រវាងឪពុកម្ដាយបង្កើត និងញាតិសន្ដានរបស់កូនសុំនោះទាំងស្រុង ដើម្បីបង្កើតឲ្យមាននូវទំនាក់ទំនងញាតិ និងទំនាក់ទំនងគតិយុត្ត រវាងឪពុកម្ដាយចិញ្ចឹម នឹងកូនសុំនោះវិញ។ ការដែលធ្វើបែបនេះ គឺដើម្បីឲ្យទំនាក់ទំនងរបស់ឪពុកម្ដាយចិញ្ចឹម និងកូនសុំនោះ ដូចគ្នាទៅនឹងទំនាក់ទំនងឪពុកម្ដាយ និងកូនបង្កើតដែលច្បាប់បានទទួលស្គាល់ ។ គោលបំណងនៃការសុំកូនពេញលេញខាងលើនេះ គឺធ្វើឡើងដើម្បីផ្ដល់នូវគ្រួសារមួយ ដែលមានឪពុកម្ដាយមានជីវភាពសមរម្យ និងអាចផ្គត់ផ្គង់គ្រប់គ្រាន់ដល់កុមារអភ័ព្វ (កូនសុំ) និងដើម្បីផលប្រយោជន៍កុមារដែលខ្វះការថែរក្សា ខ្វះការយកចិត្តទុកដាក់ពីឪពុកម្ដាយបង្កើត ឬឪពុកម្ដាយបង្កើតមានជីវភាពក្រីក្រ ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការមើលថែរក្សាកូនបាន ឬ ដោយសារស្ថានភាពណាមួយ ដូចជាបញ្ហាវិបល្លាសស្មារតី ឬ ពិការភាពជាដើម។

**សុំកូនធម្មតា** គឺជាការសុំកូនមួយប្រភេទ ដែលញាតិរវាងកូនសុំ និងឪពុកម្ដាយបង្កើតត្រូវបន្តអត្ថិភាព ហើយកូនសុំ និងឪពុកម្ដាយបង្កើតមានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក ហើយកូនសុំ និងឪពុកម្ដាយបង្កើតមានសិទ្ធិទាមទារ និងករណីយកិច្ច ផ្គត់ផ្គង់អាហារកិច្ច។ ម៉្យាងវិញទៀត កូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ឬនាមត្រកូលមុនសុំកូនបាន ហើយកូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម និងត្រូវទទួលបាននូវសិទ្ធិ និងករណីយកិច្ចដូចគ្នា នឹងកូនបង្កើតនៅក្នុងទំនាក់ទំនង ជាមួយនឹងឪពុកម្ដាយចិញ្ចឹម ។

**សុំកូនអន្តរប្រទេស** សុំកូនអន្តរប្រទេស គឺជាការសុំទារក ឬ កុមារកំព្រាដែលមានសញ្ជាតិខ្មែរ ដែលមានលំនៅឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្ដីប្រពន្ធដែលរស់នៅក្នុងប្រទេសផ្សេងទៀត ដើម្បីសុំយកទៅ ចិញ្ចឹមជាកូន ហើយនឹងត្រូវបានទទួលស្គាល់ដោយច្បាប់របស់ប្រទេសនោះ។ សុំកូនអន្តរប្រទេសអាចអនុញ្ញាតបានបន្ទាប់ពីអាជ្ញាធរកម្ពុជាបានប្រឹងប្រែងឲ្យអស់ពីលទ្ធភាពក្នុងការបញ្ជូនកុមារទៅគ្រួសារកំណើតវិញ ឬ ក៏លក្ខណៈសម្បត្តិសុំកូនក្នុងស្រុកជាមុនរួចហើយ។

## ១.២ និន្នាការទូទៅនៃការសុំកូន

ការគិតគូររបស់រដ្ឋាភិបាល ក៏ដូចជាទឹកចិត្តរបស់ប្រជាជន ក្នុងការជួយសង្គ្រោះ ការអាណិតដល់កុមារដែលមានឪពុកម្តាយក្រីក្រ ឬកុមារកំព្រា ទើបធ្វើឲ្យពលរដ្ឋខ្លះដែលគ្មានកូន សុំកុមារទាំងនោះមកធ្វើជាកូនចិញ្ចឹម។ មានកុមារមិនតិចទេដែលមានសំណាងដោយការសុំនេះ ពួកគេបានរស់នៅក្នុងគ្រួសារអ្នកមានស្តុកស្តម្ភ និងការថ្នាក់ថ្នមយ៉ាងកក់ក្តៅ ផ្ទុយមកវិញក៏មានកុមារមួយចំនួនតូចដែលគ្មានសំណាង ហើយត្រូវគេវាយធ្វើបាប ធ្វើអាជីវកម្មលើកំលាំងពលកម្ម ឬយកទៅជួញដូរជាដើម។ ដើម្បីជៀសវាងរាល់ការជួញដូរទាំងឡាយទៅលើកុមារ និងសម្រាប់តម្រង់ទិសទៅអ្នកដែលពាក់ព័ន្ធ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធលើវិស័យនេះ ឲ្យកាន់តែមានប្រសិទ្ធិភាពថែមទៀត ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្តិអំពីសុំកូនមាន២៧ មាត្រា ចាប់ពីមាត្រា១០០៧ ដល់មាត្រ១០៣៣ ។ ក្នុងនោះមាត្រា១០០៧ បានផ្តល់អំណាចពេញលេញដល់តុលាការក្នុងការពិចារណា និងសម្រេចឲ្យមានការសុំកូន ។ ដូចគ្នាផងដែរនៅប្រទេសដទៃទៀតដូចជានៅអឺរ៉ុបកំណត់ថា ការសុំកូនពេញលេញមានសុពលភាព លុះត្រាមានការសម្រេចរបស់តុលាការ ឬអាជ្ញាធររដ្ឋបាល។ អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា២១ ក៏បានទាមទារឲ្យមានការពិចារណាអតិបរមា ទៅលើផលប្រយោជន៍របស់កុមារ ដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចដែរ [២] ។ ដោយឡែកចាប់ពីចុងទសវត្សរ៍ឆ្នាំ១៩៨០ ដល់ ឆ្នាំ២០០៩ ប្រទេសកម្ពុជា បានអនុវត្តប្រព័ន្ធសុំកូនអន្តរប្រទេសដែល អនុញ្ញាតឲ្យមានកុមាររាប់ពាន់នាក់ ត្រូវបានគ្រួសារជាជនបរទេសសុំយកទៅចិញ្ចឹមនៅក្រៅប្រទេស។ ច្បាប់ស្តីពីការសុំកូនអន្តរប្រទេសឆ្នាំ២០០៩ បានបញ្ញត្តិចំនួន១០ ជំពូក និង៥៨ មាត្រា។ ការតាក់តែងច្បាប់នេះឡើងក៏អនុវត្តតាមវិធីនយោបាយ និងយុត្តិសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាដំណាក់កាលទី២ សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ដែលចែងជាអាទិ៍ថារាជរដ្ឋាភិបាលប្តូរផ្តាច់ដាក់ចេញនូវវិធានការគ្រប់បែបយ៉ាង ដើម្បីទប់ស្កាត់អំពើការគាបសង្កត់ អំពើពេស្យាចារលើកុមារ ការពង្រឹងការអនុវត្តច្បាប់ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

## ១.៣ បទដ្ឋានគតិយុត្តនៃការសុំកូន

ទំនាក់ទំនងបុត្តភាពតាមបែបធម្មជាតិ ក្រមរដ្ឋប្បវេណី ក៏ទទួលស្គាល់ការបង្កើតឲ្យមានទំនាក់ទំនងមានបុត្តភាព តាមរយៈសុំកូន ។ គោលបំណងនៃការបង្កើតឲ្យមានប្រព័ន្ធសុំកូន ដើម្បីបង្កើតឲ្យមានសន្តតិជន នៃទ្រព្យសម្បត្តិរបស់គ្រួសារឪពុកម្តាយចិញ្ចឹម ហេតុនេះ តាមរយៈសុំកូនគេអាចទទួលបាននូវសន្តតិជន ដែលជាអ្នកបន្តសន្តតិកម្មរបស់ឪពុកម្តាយចិញ្ចឹម។ សុំកូនក៏មានគោលបំណងបង្កើតអ្នកមានកម្លាំងការងារ និងមើលថែរក្សាគ្រួសារឪពុកម្តាយចិញ្ចឹមដែរ ហេតុនេះតាមរយៈសុំកូន ឪពុកម្តាយចិញ្ចឹមដែលពុំមានកូនអាចទទួលបានកូន ដើម្បីទទួលការមើលថែពីកូន។ លើសពីនេះទៅទៀត សុំកូនមានគោលបំណងបង្កើតឲ្យមានឪពុកម្តាយ ក្នុងការថែរក្សាកូនជាគោលបំណងគិតគូដល់ផលប្រយោជន៍របស់កុមារ ដែលពុំមានស្ថានភាពនៃការថែរក្សា ដោយសមរម្យពីឪពុកម្តាយបង្កើត។

[២] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មាត្រា១០០៧

គោលបំណងទាំងបីនេះត្រូវបានយកមកវិនិច្ឆ័យក្នុងការបង្កើតសុំកូន ប៉ុន្តែគោលបំណងដែលមានអាទិភាពជាងគេគឺផលប្រយោជន៍របស់កូនសុំ ហេតុនេះ ក្រមរដ្ឋប្បវេណី ក្រៅពីបញ្ញត្តិជាមូលដ្ឋាននៃលក្ខខណ្ឌនៅក្នុងការបង្កើតសុំកូនក៏មានបញ្ញត្តិជាមូលដ្ឋានដែលជាគោលការណ៍ទូទៅក្នុងការបង្កើតសុំកូនដូចមានចែងក្នុងមាត្រា១០១២ ១០១៣ និង ១០១៤។

### ១.៣.១ លក្ខខណ្ឌកំណត់ដើម្បីបង្កើតការសុំកូន

#### ១.៣.១.១ លក្ខខណ្ឌសុំកូនពេញលេញ

ការបង្កើតការសុំកូនពេញលេញបានលុះត្រាតែបានបំពេញតាមលក្ខខណ្ឌ និងនីតិវិធីដែលបានកំណត់ដោយច្បាប់ ហើយមានលក្ខខណ្ឌជាច្រើនសម្រាប់សុំកូនពេញលេញ ដែលលក្ខខណ្ឌទាំងនោះទាក់ទងទៅនឹងអាយុរបស់ឪពុកម្តាយចិញ្ចឹម និងកូនសុំ ការចូលរួមរបស់ភាគី ដែលមានផលប្រយោជន៍ពាក់ព័ន្ធ (សហព័ទ្ធរបស់ឪពុកម្តាយចិញ្ចឹម ឪពុកម្តាយរបស់កូនសុំ) កំឡុងពេលសាកល្បង និងមូលដ្ឋានវិនិច្ឆ័យដែលតុលាការនឹងពិចារណា ។

#### ក. អំពីអ្នកសុំ

១. ភាពមានសហព័ទ្ធ និងការសហការៈ បុគ្គលដែលនឹងក្លាយទៅជាឪពុក ឬម្តាយចិញ្ចឹមចាំបាច់ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ[៣]។ ដូចនេះចំពោះបុគ្គលដែលជាប្តី ឬប្រពន្ធតែម្ខាងមិនអាចក្លាយជាឪពុក ឬម្តាយចិញ្ចឹមបានឡើយ ដោយសារការបង្កើតសុំកូនពេញលេញធ្វើឡើងក្នុងគោលបំណងផ្តល់នូវគ្រួសារមួយដែលមានលំនឹងគ្រប់គ្រាន់សម្រាប់កុមារអភ័ព្វ ទើបទាមទាឲ្យមានការសហការរវាងសហព័ទ្ធ។ ប្រសិនបើមានតែសហព័ទ្ធតែម្ខាង ហើយខ្វះការចូលរួមពីសហព័ទ្ធម្ខាងទៀត នោះគោលបំណងដែលផ្តល់គ្រួសារមួយមានលំនឹងសម្រាប់កុមារអភ័ព្វនឹងមិនអាចសម្រេចបានឡើយ។ ហេតុនេះហើយទើបបញ្ញត្តិក្នុងមាត្រា១០០៨ ខាងលើកំណត់អំពីគោលការណ៍ សហការរវាងប្តីប្រពន្ធដែលនឹងក្លាយជាឪពុក ឬម្តាយចិញ្ចឹមនៃកូនសុំ។ ហើយបញ្ញត្តិនេះ ក៏ចេញមកដើម្បីបង្ការដល់ការបង្កើតសុំកូនរវាង បុគ្គលដែលមានភេទដូចគ្នានឹងសុំកូន ដោយគេគិតថាកម្ពុជាពុំទាន់អាចទទួលស្គាល់ភាពស្របច្បាប់នៅឡើយចំពោះអាពាហ៍ពិពាហ៍រវាងបុគ្គលដែលមានភេទដូចគ្នា ដោយផ្អែកលើប្រពៃណីទំនៀមទំលាប់ ដែលប្រកាន់តាំងពីដើមមកស្របពេលបណ្តាប្រទេសមួយចំនួនទទួលស្គាល់ការបង្កើតសុំកូនដល់បុគ្គលមានភេទដូចគ្នា (LGBT) ជាអាទិ៍ចក្រភពអង់គ្លេស និងអេស្ប៉ាញជាដើម។

---

[៣] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ១០០៨ កថាខណ្ឌទី១

នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បុគ្គលជាប្តី ឬ ប្រពន្ធតែម្ខាងអាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមបាន ប្រសិនបើកូនសុំនោះគឺជាកូនបង្កើតរបស់បុគ្គលជាប្តី ឬ ប្រពន្ធនេះ[៤]។ ចំពោះករណីខាងលើប្រសិនបើសហព័ទ្ធម្ខាងត្រូវជាឪពុក ឬម្តាយបង្កើតរបស់កូនសុំ នោះជាគោលការណ៍ សហការរវាងប្តីប្រពន្ធមិនចាំបាច់ឡើយ ហើយសហព័ទ្ធម្ខាងដែលត្រូវជាឪពុក ឬម្តាយចុងនៃកូនសុំ អាចបង្កើតស្មុំកូនពេញលេញបាន។

២. អាយុរបស់ឪពុកម្តាយចិញ្ចឹម៖ ឪពុកម្តាយចិញ្ចឹមត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ[៥] ទើបអាចបង្កើតស្មុំកូនពេញលេញបាន។ របបស្មុំកូនត្រូវតែធានាឲ្យបាននូវគ្រួសារថ្មីមួយសម្រាប់កុមារដែលជាកូនសុំ ហេតុនេះវាជាភាពចាំបាច់ដើម្បីឲ្យគ្រួសារថ្មីបង្កើតនូវស្ថានភាពឲ្យដូចទៅនឹងគ្រួសារធម្មតាដទៃទៀតដែរ។ ប្រសិនបើអាយុរបស់ឪពុកម្តាយចិញ្ចឹមតិចពេកលទ្ធភាព និងបទពិសោធន៍ក្នុងការថែទាំកូនសុំក៏មានកម្រិតដែរ វាអាចនឹងបណ្តាលឲ្យកូនសុំពុំអាចទទួលបានការថែទាំដែលត្រឹមត្រូវ។

៣. ភាពដែលអាចធ្វើឲ្យទុកចិត្តបាននូវការផ្តល់ការថែទាំកូនសុំ៖ ដោយសារតែបង្កើតរបបស្មុំកូន ត្រូវមានជាចាំបាច់នូវការត្រួតពិនិត្យរបស់តុលាការ[៦] ដើម្បីធានាឲ្យបាននូវផលប្រយោជន៍របស់កូនសុំ ហេតុនេះបុគ្គល ដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹមត្រូវបង្ហាញឲ្យតុលាការមានជំនឿទុកចិត្ត ការបង្កើត របបស្មុំកូនរវាងខ្លួន និងកូនសុំ អាចនឹងបញ្ចៀសស្ថានភាពពិបាកខ្លាំង ឬមិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកូនរបស់ឪពុកម្តាយបង្កើត ឬស្ថានភាពផ្សេងៗទៀត ដែលមានភាពចាំបាច់ដើម្បី ផលប្រយោជន៍របស់កូននោះ[៧]។ លក្ខខណ្ឌនេះអាចនឹងសម្រេចបាននៅពេលដែលតុលាការបង្គាប់ឲ្យបុគ្គលដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹមធ្វើការគ្រប់គ្រងថែរក្សា ក្នុងដំណាក់កាលគ្រប់គ្រងថែរក្សា ក្នុងដំណាក់កាលនៃអំឡុងពេលសាកល្បងចិញ្ចឹម[៨]។ ពាក្យសុំចាប់ផ្តើមរបបស្មុំកូនពេញលេញ ស្ថិតនៅក្នុងវិសាលភាពច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ យោងតាមច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង NSCC, (None Sult Civil Case) មាត្រា ៣ កថាខណ្ឌទី១ បានបង្ហាញថានីតិវិធីប្រភេទនេះ គឺជានីតិវិធីដែលការសម្រេចសេចក្តី ស្ថិតក្រោមសិទ្ធិអំណាចរបស់តុលាការ[៩]។ តុលាការមានឆន្ទានុសិទ្ធិ ក្នុងការបដិសេធអង្គហេតុដែលភាគីបានអះអាងនិងភស្តុតាងដែលភាគីបានដាក់ ហើយមានឆន្ទានុសិទ្ធិក្នុងការស្រាវជ្រាវអង្គហេតុនិងភស្តុតាង។

---

[៤] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មាត្រា១០០៨ កថាខណ្ឌទី២

[៥] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០០៩

[៦] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០០៧

[៧] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០១២

[៨] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០១៣

[៩] ច្បាប់ស្តីពី រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (NSCC) មាត្រា ៣

ហេតុនេះទោះបីជា ភាគីបានដាក់ភស្តុតាងដែលបញ្ជាក់ពីការចិញ្ចឹមថែរក្សាកូនសុំបានល្អនៅពេលកន្លងមកក៏ដោយ ក៏តុលាការមានឆន្ទានុសិទ្ធិក្នុងការដែលមិនទទួលយកអង្គហេតុ និងភស្តុតាងនោះជាមូលដ្ឋានក្នុងការចេញដីកាសម្រេចដែរ[១០]។

**ខ. អំពីកូនសុំ**

១. អាយុរបស់កូនសុំ៖ ជាគោលការណ៍កូនសុំ ត្រូវមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំ[១១]។ ចំណុចនេះក្រមរដ្ឋប្បវេណីជប៉ុនចែងថា ក្មេងដែលមានអាយុដល់ ៦ (ប្រាំមួយ) ឆ្នាំ នៅពេលដាក់ពាក្យសុំមិនអាចក្លាយកូនសុំបានទេ ប៉ុន្តែប្រសិនបើក្មេងដែលមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំ ហើយដែលត្រូវបានថែរក្សាដោយបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមជាបន្តបន្ទាប់តាំងពីមុនពេលក្មេងនោះ មានអាយុដល់៦ឆ្នាំអាចសុំបាន ។ មានន័យថាជាគោលការណ៍ សុំកូនពេញលេញអាចបង្កើតបានក្នុងករណីកូនសុំមានអាយុត្រឹម ៦ (ប្រាំមួយ) ឆ្នាំប៉ុណ្ណោះ ប៉ុន្តែក្នុងករណីកូនសុំនោះ មានអាយុច្រើនជាង ៦ (ប្រាំមួយ) ឆ្នាំ តែមិនលើសពី ៨ (ប្រាំបី) ឆ្នាំ និងត្រូវបានថែរក្សាដោយបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ( អង្គហេតុបានចិញ្ចឹមមុនពេលដាក់ពាក្យសុំ ) តុលាការអាចបង្កើតសុំកូចពេញលេញបាន ។

២. ស្ថានភាព៖ ចំពោះស្ថានភាពកុមារ គេនឹងពិនិត្យទៅលើទិដ្ឋភាពកុមារ ក្នុងករណីកុមារមានភាពលំបាកខ្លាំង ឪពុកម្តាយកុមារក្រីក្រខ្លាំង ឬ មានជម្ងឺផ្នែកស្មារតីធ្ងន់ធ្ងរ ឬ កំពុងបាត់ខ្លួនជាអាទិ៍។ ម្យ៉ាងវិញទៀតការគ្រប់គ្រងកុមារមិនសមរម្យពីសំណាក់ឪពុកម្តាយ អាចនឹងមានការបំពានផ្លូវចិត្ត ឬ ផ្លូវកាយ តាមរយៈពាក្យសម្តី ឬ អាចជាការមិនយកចិត្តទុកដាក់ក្នុងការមើលថែកុមារ។ លើសពីនេះដោយគិតដល់ភាពចាំបាច់ដើម្បីផលប្រយោជន៍កុមារ អាចឱ្យកុមារមានភាពល្អប្រសើរទាំងផ្លូវចិត្ត និងផ្លូវកាយ និងការផ្គត់ផ្គង់ចាំបាច់ដល់កុមារបានល្អជាងឪពុកម្តាយបង្កើត ។

មាត្រានេះ បញ្ញត្តិអំពីមូលដ្ឋានសារធាតុដ៏សំខាន់ ដើម្បីវិនិច្ឆ័យក្នុងករណីដែលតុលាការសម្រេចបង្កើតសុំកូន។ តុលាការនឹងពិនិត្យលើចំណុចទាំងនេះ ហើយបើយល់ឃើញថា មិនសមរម្យ ឲ្យឪពុកម្តាយបង្កើតគ្រប់គ្រងថែរក្សាកូន ដូចជាករណីដែលឪពុកម្តាយបាត់ខ្លួន ឬ មានវិបត្តិផ្នែករាងកាយ ដែលធ្វើឲ្យមានការពិបាកក្នុងការគ្រប់គ្រងថែរក្សាកុមារ ឪពុកម្តាយដែលធ្វើបាប ឬ បោះបង់កុមារចោល ដោយយល់ឃើញថា ដើម្បីផលប្រយោជន៍កុមារ ចាំបាច់ត្រូវបញ្ចប់ញាតិភាព ជាមួយឪពុកម្តាយនោះ ហើយបង្កើតសុំកូនជាមួយឪពុកម្តាយចិញ្ចឹម ទើបតុលាការអាចសម្រេចឲ្យបង្កើតសុំកូនបាន។

[១០] ច្បាប់ស្តីពី រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (NSCC) មាត្រា ២៧ និងមាត្រា ២៨

[១១] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ១០១០

**គ. អំពីឪពុកម្តាយបង្កើត**

ដើម្បីអាចបង្កើតសុំកូនពេញលេញបាន ត្រូវមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កូនសុំនោះ។ ប៉ុន្តែ ក្នុងករណីដែលឪពុកម្តាយបង្កើត របស់កូនសុំមិនអាចបង្ហាញឆន្ទៈបាន ឬករណីមានការធ្វើបាបដោយឪពុកម្តាយ ការបោះបង់កូន ចោលដោយគំនិតទុច្ចរិត ឬហេតុផ្សេងទៀត ដែលបំពានដល់ប្រយោជន៍របស់កុមារដែលនឹងក្លាយ ជាកូនសុំធ្ងន់ធ្ងរ។ ក្នុងករណីដែលមានស្ថានភាពពិបាកនឹងទទួលការយល់ព្រមពីឪពុកម្តាយបង្កើត ឬ ក្នុងករណីដែលមានការជំទាស់របស់ឪពុកម្តាយបង្កើតបំពានយ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍កុមារ ដែលនឹងក្លាយជាកូនសុំ ការយល់ព្រមពីឪពុកម្តាយបង្កើតមិនចាំបាច់ឡើយ។

**១.៣.១.២ លក្ខខណ្ឌសុំកូនធម្មតា**

ការបង្កើតសុំកូនធម្មតា ស្តាប់ទៅដូចជាសាមញ្ញ និងងាយស្រួស ក៏ប៉ុន្តែភាពពិតជាក់ស្តែង ការសុំកូនធម្មតាក៏ត្រូវតែបំពេញតាមលក្ខខណ្ឌកំណត់ដោយច្បាប់ និងនីតិវិធីតុលាការទៅតាមក្រឹត្យក្រមផងដែរដូចជា លក្ខខណ្ឌអាយុរបស់ឪពុកម្តាយចិញ្ចឹម អាយុរបស់កូនសុំ ការចូលរួមរបស់សហព័ទ្ធ ក្នុងករណីជនដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមមានសហព័ទ្ធ និងការចូលរួមរបស់ឪពុកម្តាយបង្កើតរបស់កូនសុំជាដើម។

**ក. អំពីអ្នកសុំ**

១. អាយុរបស់ឪពុកម្តាយចិញ្ចឹមៈ បុគ្គលដែលមានអាយុចាប់ពី ២៥ ឆ្នាំឡើងទៅ អាចបង្កើតសុំកូនធម្មតាបាន ប៉ុន្តែសុំកូន ធម្មតាមិនអាចបង្កើតបានឡើយក្នុងករណីបុគ្គលដែលនឹងក្លាយជាកូនចិញ្ចឹម មានអាយុច្រើនជាងបុគ្គល ដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម។ ម្យ៉ាងវិញទៀត ការបង្កើតសុំកូនធម្មតាមិនហាមឃាត់ ចំពោះបុគ្គលដែលជាញាតិនឹងគ្នានោះទេ ប៉ុន្តែសុំកូនមិនអាចបង្កើតបានឡើយ ក្នុងករណីបុគ្គល ដែលនឹងក្លាយជាកូនសុំជាបុព្វញាតិរបស់បុគ្គល ដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម។ តាមការបកស្រាយ ក្នុងក្រមរដ្ឋប្បវេណី អាយុ២៥ឆ្នាំ ត្រូវគិតចាប់ពីពេលដាក់ពាក្យសុំ ហេតុនេះករណីអ្នកដាក់ពាក្យសុំមានអាយុ ២៤ឆ្នាំ នៅពេលដាក់ពាក្យសុំ តុលាការមិនអាចបង្កើតសុំកូនធម្មតាបានទេ។

២. ការចូលរួមរបស់សហព័ទ្ធ ក្នុងករណីជនដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមមានសហព័ទ្ធៈ សុំកូនធម្មតាអាចបង្កើតបានទោះបីជាបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមមាន ឬ គ្មានសហព័ទ្ធក៏ដោយ។ ប៉ុន្តែក្នុងករណីបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមមានសហព័ទ្ធ ដើម្បីបង្កើតសុំកូនធម្មតាបានលុះត្រាតែមានការយល់ព្រមរបស់សហព័ទ្ធ។ ប៉ុន្តែប្រសិនបើសហព័ទ្ធម្ខាងបានដាក់ពាក្យ ជាមួយសហព័ទ្ធម្ខាងទៀត ឬសហព័ទ្ធម្ខាងមិនអាចបង្ហាញឆន្ទៈយល់ព្រមបាន សុំកូនធម្មតាអាចបង្កើតបាន។ ផ្ទុយទៅវិញ ក្នុងករណីកូនសុំជាអនីតិជន ហើយបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមមានសហព័ទ្ធ ការយល់ព្រមរបស់ភាគីម្ខាងមិនគ្រប់គ្រាន់ទេ ពោលគឺត្រូវដាក់ពាក្យសុំរួមគ្នា (សុំកូនដោយសហការ) ទើបអាចបង្កើតសុំកូនធម្មតាបាន។

ប៉ុន្តែ ក្នុងករណីយកកូនរបស់សហព័ទ្ធ មកធ្វើជាកូនសុំ ឬសហព័ទ្ធម្ខាងទៀតមិនអាចបង្ហាញឆន្ទៈបាន ស្មុំកូនអាចបង្កើតឡើង បានត្រឹមការដាក់ពាក្យសុំតែម្នាក់ឯងរបស់សហព័ទ្ធម្ខាង។

គួរបញ្ជាក់ថា ការដាក់ពាក្យសុំរួមគ្នា និងការដាក់ពាក្យសុំដោយមានការយល់ព្រមពីសហព័ទ្ធ មានភាពខុសគ្នាត្រង់ថា ការដាក់ពាក្យសុំរួមគ្នា[១២] (ដូចមានចែងក្នុងមាត្រា១០២១ ) សហព័ទ្ធទាំងពីរ នឹង ក្លាយជាឪពុកម្តាយចិញ្ចឹម ប៉ុន្តែក្នុងករណីពាក្យសុំត្រូវបានដាក់ដោយសហព័ទ្ធម្ខាង ដោយមានការយល់ព្រមរបស់សហព័ទ្ធម្ខាងទៀត អ្នកដែលក្លាយជា ឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម គឺសហព័ទ្ធម្ខាងដែលបានដាក់ពាក្យសុំ[១៣]។

**ខ. អំពីកូនសុំ**

១. អាយុរបស់កូនសុំ៖ អាយុរបស់កូនសុំពុំត្រូវបានកំណត់ឡើយ ប៉ុន្តែបុគ្គលដែលនឹងក្លាយទៅជាកូនសុំមិនអាចជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹម ឬ បុគ្គលដែលមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមឡើយ ។ កូនសុំអាចជាអនីតិជន ឬ នីតិជន ដោយមិនកម្រិតអាយុឡើយ លើកលែងតែបុគ្គលដែលជា កូនសុំមានអាយុច្រើនជាងឪពុកម្តាយចិញ្ចឹម ឬ ជាបុព្វញាតិរបស់ឪពុកម្តាយចិញ្ចឹម។

២. ស្ថានភាព៖ តុលាការអាចបង្កើតស្មុំកូនធម្មតាបាន លុះត្រាតែមានការបង្ហាញឆន្ទៈពិតប្រាកដរបស់ភាគីក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្តាយ និងកូន។ បើតុលាការយល់ឃើញថា ស្មុំកូនត្រូវបាន បំពានក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍រវាងភេទផ្សេងគ្នា ឬភេទដូចគ្នា ឬ គោលបំណងមិន ត្រឹមត្រូវផ្សេងទៀត ស្មុំកូននឹងមិនអាចបង្កើតបានឡើយ។ បើបុគ្គលដែលជាកូនសុំ ជាអនីតិជននោះតុលាការអាចឲ្យបង្កើតស្មុំកូនបាន លុះត្រាតែយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍អនីតិជននោះដោយមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ហើយអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវដាក់ពាក្យសុំទៅតុលាការជាមួយអ្នកសុំ[១៤]។ បើឪពុកម្តាយរបស់អនីតិជននោះបានលែងលះគ្នាតុលាការត្រូវសួរយោបល់របស់ឪពុក ឬម្តាយដែលមិនមែនជាអ្នកមានអំណាចមេបាដើម្បីវិនិច្ឆ័យ។ បើបុគ្គលជាកូនសុំជាអនីតិជនមានអាយុដល់១៥ឆ្នាំ គឺចាំបាច់ត្រូវមានការយល់ព្រមពីអនីតិជននោះ។ ប៉ុន្តែបើទោះបីជាបុគ្គលដែលជាកូនសុំ ជាអនីតិជនមិនទាន់ដល់អាយុ ១៥ឆ្នាំក៏ដោយ តែបុគ្គលដែលជាកូនសុំនោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន គឺតុលាការត្រូវសួរយោបល់របស់អនីតិជននោះដើម្បីវិនិច្ឆ័យ ។ បើបុគ្គលដែលជាកូនសុំ ជានីតិជន បុគ្គលនោះមានសិទ្ធិដាក់ពាក្យសុំកូនធម្មតាដោយខ្លួនឯង ហើយតុលាការនឹងចេញដីកាសម្រេចឲ្យបង្កើតទំនាក់ទំនងញាតិលោហិតជាមួយអ្នកសុំ ដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹម។

---

[១២] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ១០

[១៣] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ មាត្រា ១០២១ និង ១០២២

[១៤] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០២០

ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនដាក់ពាក្យសុំបង្កើតសុំកូន ដោយយកអនីតិជនដែលនៅក្រោមការមើលថែរបស់ខ្លួនមកធ្វើជាកូនសុំ ឬការដែលអាណាព្យាបាលទូទៅ អាចដាក់ពាក្យសុំបង្កើតសុំកូនបាន លុះត្រាតែក្នុងករណីដែលបានអនុវត្តត្រឹមត្រូវក្នុងការគ្រប់គ្រង ថែរក្សា និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះ។

**គ.អំពីឪពុកម្តាយបង្កើត**

ក្នុងករណីបុគ្គលដែលនឹងក្លាយជាកូនសុំជានីតិជន ការដាក់ពាក្យបង្កើតសុំកូនធ្វើឡើងត្រឹមតែបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម និងបុគ្គលដែលនឹងត្រូវក្លាយជាកូនសុំនោះមានភាពគ្រប់គ្រាន់ ដោយមិនពិចារណាអំពីឆន្ទៈរបស់ឪពុកម្តាយបង្កើតឡើយ។ ម្យ៉ាងវិញទៀត ទោះបីជាកូនសុំ មានសហព័ទ្ធក៏ដោយ សុំកូនត្រូវបានបង្កើតឡើងត្រឹមឆន្ទៈរបស់កូនសុំ ដោយមិនពិចារណាអំពីឆន្ទៈរបស់សហព័ទ្ធនៃកូនសុំឡើយ។ ក្នុងករណីកូនសុំជាអនីតិជន សុំកូនអាចបង្កើតបានលុះត្រាតែមានការចូលរួម ( ដាក់ពាក្យ) ពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កូនសុំ ក្នុងនាមជាអ្នកមានអំណាចមេបា។ បើកូនសុំជាអនីតិជនមានអាយុដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ដើម្បីបង្កើតសុំកូនបាន លុះត្រាតែ មានការយល់ព្រមពីអនីតិជននោះ ហេតុនេះក្នុងករណីអនីតិជនមិនយល់ព្រម សុំកូនមិនអាចបង្កើត ឡើងបានទេ។

**១.៣.១.៣ លក្ខខណ្ឌសុំកូនអន្តរប្រទេស**

លក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេសត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងច្បាប់ស្តីពីការសុំកូនអន្តរប្រទេស ដែលមានទាំងលក្ខខណ្ឌចំពោះអ្នកសុំកូន លក្ខខណ្ឌចំពោះកូនសុំ និង លក្ខខណ្ឌចំពោះឪពុកម្តាយបង្កើត ឬអាណាព្យាបាល ។

**ក. អំពីអ្នកសុំ**

ចំពោះជនបរទេសដែលអនុញ្ញាតឱ្យសុំទារក ឬកុមារកំព្រាយកទៅចិញ្ចឹមជាកូននៅឯបរទេសបានត្រូវឆ្លើយតបនឹងលក្ខខណ្ឌមួយចំនួនដូចជា៖

១. អ្នកសុំជាប្តីប្រពន្ធត្រូវមានអាយុចាប់ពី ៣០ ឆ្នាំ និងមានអាយុលើសកូនសុំយ៉ាងតិច ២២ ឆ្នាំ និងយ៉ាងច្រើនបំផុត ៤៥ឆ្នាំ ដោយគិតត្រឹមកាលបរិច្ឆេទដាក់ពាក្យសុំកូន។

២. ក្នុងករណីដែលអ្នកសុំមិនអាចបំពេញតាមចំណុច១ ដូចបានរៀបរាប់ខាងលើនេះ ហើយក្នុងករណីសុំកូនឆ្លើយតបទៅនឹងឧត្តមប្រយោជន៍របស់កុមារ សុំកូនអាចអនុញ្ញាតឲ្យបានក្នុងស្ថានភាពដែល អ្នកសុំមានដើមកំណើតជាជនជាតិខ្មែរ ដែលសុំកុមារដែលជាសាច់ញាតិរបស់ខ្លួន ឬអ្នកសុំជាសហព័ទ្ធដែលសុំកូននៃសហព័ទ្ធម្ខាងទៀត ហើយអ្នកសុំអាចសុំកុមារដែលត្រូវការថែទាំពិសេស ឬស្ថានភាពផ្សេងទៀតដែលបម្រើឧត្តមប្រយោជន៍របស់កុមារ។

៣. ក្នុងករណីអ្នកសុំមានប្តី ឬប្រពន្ធការសុំកូនត្រូវធ្វើដោយសហព័ទ្ធទាំងពីររួមគ្នាលើកលែងតែករណីដែលសហព័ទ្ធណាម្ខាងសុំកូនបង្កើតនៃសហព័ទ្ធម្ខាងទៀត។

៤. ច្បាប់ជាតិរបស់អ្នកស្នុំនីមួយៗ និងច្បាប់ប្រទេសនៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់អ្នកសុំ ដែលបានទទួលស្គាល់និងអនុញ្ញាតនូវបុគ្គភាពនៃស្នុំកូនពេញលេញ។

៥. ប្រទេសនៃសញ្ជាតិ ឬប្រទេសនៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់អ្នកស្នុំត្រូវតែជាប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា។

៦. អ្នកស្នុំត្រូវតែជាជនជាតិពុំធ្លាប់ត្រូវបានផ្តន្ទាទោស ឬត្រូវកំពុងបានប្តឹងអំពីកំហុសទាក់ទងទៅនឹងកិរិយាមាយាទ ឬការប្រព្រឹត្តបទឧក្រិដ្ឋមជ្ឈិមណាមួយនៅក្នុងប្រទេសនៃសញ្ជាតិរបស់ខ្លួន ឬប្រទេសលំនៅដ្ឋានអចិន្ត្រៃយ៍ ឬនៅក្នុងប្រទេសណាមួយដែលខ្លួនបានស្នាក់នៅចុងក្រោយ។

៧. អ្នកស្នុំត្រូវតែជាអ្នកមានសមត្ថភាពផ្តល់ការថែទាំសមស្របនឹងការគាំទ្រយ៉ាងចាំបាច់ដល់កូន។

៩. អ្នកស្នុំត្រូវបានអនុញ្ញាតឲ្យស្នុំកូនបានលុះត្រាតែអ្នកស្នុំកូនគ្មានកូន ឬមានកូនតែម្នាក់នៅក្នុងបន្ទុក គេអាចសុំបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែកុមារដែលមានបងប្អូនបង្កើតអាចអនុញ្ញាតឲ្យស្នុំច្រើននាក់បាន[១៥]។

### ខ. អំពីកូនសុំ

កុមារដែលជាកម្មវត្ថុនៃការសុំ គឺត្រូវតែជាកុមារដែលមានអត្តសញ្ញាណត្រឹមត្រូវ មានសញ្ជាតិខ្មែរដែលមានលំនៅដ្ឋានអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលកុមារត្រូវមានអាយុក្រោម ៨ (ប្រាំបី)ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំលើកលែងតែក្នុងករណីកុមារត្រូវការនូវការថែទាំពិសេសដែលអនុញ្ញាតបានដល់អាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ តែក្នុងករណីមានបងប្អូនបង្កើតច្រើននាក់ហើយម្នាក់មានអាយុក្រោម ៨ (ប្រាំបី) ឆ្នាំអាចអនុញ្ញាតឲ្យស្នុំកុមារនោះរួមជាមួយនឹងបងប្អូនបង្កើតដែលមានអាយុក្រោម ១៨ (ដប់ប្រែបី) ឆ្នាំបាន[១៦]។ ម្យ៉ាងវិញទៀតកុមារដែលស្ថិតនៅក្រោមអាណាព្យាបាលសម្រាប់អនីតិជន កុមារដែលស្ថិតនៅក្រោមអំណាចមេបាដែលមានស្ថានភាពលំបាកបំផុត កុមារដែលកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬរស់នៅក្រោមការទុកដាក់សមស្របផ្សេងៗ ដែលត្រូវពិនិត្យដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច កុមារទាំងអស់នោះគេត្រូវបានប្រកាសថាអាចសុំជាកូនចិញ្ចឹមបានដោយអនុលោមតាមមាត្រា ១៣ នៃច្បាប់ស្តីពីការស្នុំកូនអន្តរប្រទេស ចុះថ្ងៃទី ២៣ ខែតុលា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤។

### គ. អំពីឪពុកម្តាយបង្កើត ឬអាណាព្យាបាល

ការស្នុំកូនអន្តរប្រទេសអាចប្រព្រឹត្តទៅបានលុះត្រាតែមានការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីឪពុកម្តាយ ឬសាច់ញាតិ និងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារតាមករណីកុមារមានចំណងបុគ្គភាពជាមួយឪពុក និងម្តាយ ការយល់ព្រមត្រូវផ្តល់ដោយឪពុក និងម្តាយរបស់កុមារនោះ តែបើឪពុក ឬម្តាយណាមួយរបស់កុមារ

[១៥] ច្បាប់ស្តីពីស្នុំកូនអន្តរប្រទេស ឆ្នាំ២០០៩ មាត្រា ២១

[១៦] ក្នុងករណីស្នុំកូនដោយសាច់ញាតិស្នុំកូនអាចអនុញ្ញាតបានចំពោះកុមារមានអាយុក្រោម១៨ ឆ្នាំដែលរស់នៅក្នុង ឬក្រៅមណ្ឌលកុមារកំព្រា។

បានស្លាប់ ឬស្ថិតក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬត្រូវបានដកហូតអំណាចមេបានោះការយល់ព្រមត្រូវបានផ្តល់ដោយឪពុក ឬម្តាយតែម្ខាងដែលមានអំណាចមេបាជាការគ្រប់គ្រាន់ហើយ ដោយការយល់ព្រមនេះត្រូវផ្តល់ឲ្យ ដោយសេរីនិងច្បាស់លាស់ដោយមិនត្រូវមានវិការៈណាមួយដូចជា ការបង្ខិតបង្ខំ ការឆបោក ឬការបញ្ចុះបញ្ចូលតាមរយៈការផ្តល់ ឬការសន្យាផ្តល់ប្រាក់រង្វាន់សំណងផលប្រយោជន៍ណាមួយនិងដោយបានដឹងច្បាស់ពីផលវិបាកនៃការយល់ព្រមរបស់ខ្លួនចំពោះសុំកូនអន្តរប្រទេស។ ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារត្រូវទទួលនូវការពិគ្រោះយោបល់ពីភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចដែល បានទទួលការអនុញ្ញាតជាមុន មុននឹងផ្តល់ការយល់ព្រម។

ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អាចបញ្ឈប់ការយល់ព្រមរបស់ខ្លួនវិញបាន រហូតដល់មានសេចក្តីសម្រេចរបស់តុលាការស្តីអំពីការសុំកូនជាស្ថាពរ ។ ប៉ុន្តែការបដិសេធ ឬបញ្ឈប់ការយល់ព្រមនេះ មិនអាចធ្វើបានទេ ក្នុងករណីពិនិត្យឃើញថា ការបដិសេធ ឬបញ្ឈប់ការយល់ព្រមនេះ ធ្វើឲ្យប៉ះពាល់ផលប្រយោជន៍របស់កុមារ ឬបណ្តាលឲ្យប៉ះពាល់ដល់សុខភាព ឬសីលធម៌របស់កុមារ។

### ១.៣.២ អានុភាពនៃការសុំកូន

#### ១.៣.២.១ អានុភាពនៃការសុំកូនពេញលេញ

របបសុំកូន បង្កើតអានុភាពនៅពេលដីកាសម្រេចចាប់ផ្តើមរបបសុំកូនចូលជាស្ថាពរ។ ស្របពេលនឹងការចូលជាស្ថាពរនៃដីកាសម្រេចផ្តើមនេះ វាបានបង្កើតអោយមានអនុភាពគតិយុត្តមួយចំនួនដូចជា ៖

**ក.ការបង្កើតទំនាក់ទំនងញាតិជាមួយឪពុកម្តាយចិញ្ចឹម**

គោលបំណងសំខាន់បន្ទាប់ពីការផ្តល់នូវការថែទាំដូចនឹងគ្រួសាររបស់កូនសុំ គឺជាការបង្កើត អោយមានទំនាក់ទំនងញាតិថ្មីមួយក្នុងទំនាក់ទំនងរវាងកូនសុំ និងគ្រួសាររបស់ឪពុកម្តាយ។ នៅពេលដីការសម្រេច ចាប់ផ្តើមសុំកូនមានអនុភាព ត្រូវបង្កើតទំនាក់ទំនងញាតិដូចគ្នានឹងញាតិ លោហិតរវាងបុគ្គលជាកូនសុំ និង ឪពុកម្តាយចិញ្ចឹមព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយ[១៧]។ វិសាលភាពនៃទំនាក់ទំនងញាតិដែលត្រូវបង្កើតតាមរយៈសុំកូនមានត្រឹមត្រូវតែក្នុងទំនាក់ទំនង រវាងកូនសុំនិងឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិត របស់ឪពុកម្តាយចិញ្ចឹមតែប៉ុណ្ណោះ។ ញាតិលោហិត ឬញាតិពន្ធរបស់កូនសុំដែលបានកើតមុនទំនាក់ទំនងសុំកូន ពុំស្ថិតក្នុងវិសាលភាពអានុភាពសុំកូនឡើយ ។ ដូចនេះក្នុងទំនាក់ទំនងរវាង បុព្វញាតិរបស់កូនសុំ និងឪពុកម្តាយចិញ្ចឹមនិងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមពុំមានទំនាក់ទំនងញាតិនឹងគ្នាឡើយ។

[១៧] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៨០

ដីកាសម្រេចចាប់ផ្តើមសុំកូនពុំមានអានុភាពប្រតិសកម្ម នៅពេលដែលដីកាសម្រេចនេះ បង្កើតអានុភាពទាក់ទងនឹងញាតិកើតឡើងរាប់ចាប់ពីពេលដែលដីកាសម្រេចនេះចូលជាស្ថាពរ។ ហេតុនេះអានុភាពទំនាក់ទំនងញាតិចំពោះបច្ឆាញាតិ ឬសហព័ទ្ធរបស់កូនសុំវាអាស្រ័យថា តើទំនាក់ទំនងញាតិរវាងកូនសុំនិងបញ្ញតិនោះកើតឡើងមុន ឬក្រោយទំនាក់ទំនងសុំកូន។

**ខ.ការកាត់ផ្តាច់ទំនាក់ទំនងញាតិ**

តាមរយៈអានុភាពនៃដីកាសម្រេចចាប់ផ្តើមសុំកូនពេញលេញ ទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្តាយបង្កើតត្រូវបានកាត់ផ្តាច់ [១៨] វាស្របទៅនឹងគោលបំណងនៃការបង្កើតរបបសុំកូនពេញពេញដែលជាការបង្កើតគ្រួសារប្រឌិតមួយ និងបង្កើតស្ថានភាពដូចគ្រួសារពីធម្មជាតិរបស់កូនសុំ។ ការកាត់ផ្តាច់នេះ ក៏ធ្វើអោយកូនសុំបាត់បង់នូវលក្ខណៈសម្បត្តិជាសន្តតិជនក្នុងទំនាក់ទំនងរវាងឪពុកម្តាយបង្កើតផងដែរ។

ក្នុងករណីមួយចំនួនការផ្តាច់ទំនាក់ទំនងទាំងស្រុងរវាងឪពុកម្តាយបង្កើតរបស់កូនសុំអាចនឹងធ្វើឲ្យកូនសុំពុំសូវមានលទ្ធភាពអាចដឹងអំពីសាវតាជាតិពិតប្រាកដរបស់ខ្លួនដោយសារមូលហេតុ ការសុំកូនបង្កើតនៅពេលកូនសុំមានអាយុតិចពេក (១ឆ្នាំ ឬ២ឆ្នាំ) និងភាពថ្មីសន្លាងនៃសំបុត្រកំណើតរបស់កូនសុំ [១៩]។ ជាលក្ខណៈសីលធម៌ កូនសុំគប្បីមានសិទ្ធិអាចដឹងអំពីកំណើតរបស់ខ្លួនហេតុនេះច្បាប់បានអនុញ្ញាតអោយកូនសុំនៅពេលដល់នីតិភាពអាចដាក់ពាក្យសុំទៅតុលាការដែលរក្សាសំណុំរឿងដើម្បីផ្តល់នូវព័ត៌មានស្តីពីកំណើតរបស់ខ្លួន។ ប៉ុន្តែការស្នើសុំនេះពុំត្រូវអនុញ្ញាតឡើយប្រសិនបើពុំមានមូលហេតុត្រឹមត្រូវ [២០]។

**គ. ការផ្ទេរអំណាចមេបា**

អានុភាពនៃដីកាសម្រេចចាប់ផ្តើមសុំកូន ពុំត្រឹមតែកាត់ផ្តាច់ទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្តាយបង្កើតទេ ប៉ុន្តែវាថែមទាំងផ្ទេរអំណាចមេបាពីឪពុកម្តាយបង្កើតទៅឪពុកម្តាយចិញ្ចឹមផងដែរ [២១] ឪពុកម្តាយចិញ្ចឹមដែលជាអ្នកទទួលអំណាចមេបាតាមរយៈអានុភាពនៃដីកាសម្រេចខាងលើ ត្រូវមានសិទ្ធិ និងករណីកិច្ចបីបាច់ថែរក្សារូបកាយរបស់កូនសុំជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនដូចជា ការអប់រំ ផ្តល់ទីសំណាក់ ដាក់ ទណ្ឌកម្មកូន និងសិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ។

---

[១៨] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ១០១៤

[១៩] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០១៨

[២០] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ១០១៩

[២១] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ១០៣៥

ក្នុងករណីដែលដីកាសម្រេចចាប់ផ្តើមសុំកូនបង្កើតអានុភាព អំណាចមេបាត្រូវបានផ្ទេរ ហេតុនេះប្រសិនបើឪពុកម្តាយបង្កើត ពុំយល់ព្រមក្នុងការប្រគល់កូនអោយឪពុកម្តាយចិញ្ចឹម ឪពុកម្តាយចិញ្ចឹមអាចអនុវត្តសិទ្ធិទាមទារអោយប្រគល់កូនផ្អែកលើអំណាចមេបា [២២] ការទាមទារអោយប្រគល់កូន ជាប្រភេទបណ្តឹងទាមទារអោយផ្តល់តាវកាលិក ហើយការអនុវត្តដោយបង្ខំអោយប្រគល់កូនត្រូវអនុវត្តតាមវិធីបង្ខំដោយប្រយោល ស្រដៀងនឹងការទាមទារអោយប្រគល់កូនផ្អែកលើដីកាសម្រេច ឬ សាលក្រមលែងលះ ដែលកំណត់អំពីអំណាច មេបាដែរ ។

**ឃ.ការកាត់កាល់សុំកូនពេញលេញ**

ការកាត់កាល់ គឺជាការបញ្ចប់ទំនាក់ទំនងញាតិរវាងកូនសុំ បច្ឆាញាតិរបស់កូនសុំ ឬសហព័ទ្ធ របស់បច្ឆាញាតិនោះនិងឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម។ ការកាត់កាល់កូនសុំពេញលេញ ក៏ត្រូវបំពេញដូចគ្នានូវលក្ខខណ្ឌយ៉ាងតឹងរ៉ឹង ដើម្បីការពារផលប្រយោជន៍របស់កូនសុំ។

ចំណុចដែលសំខាន់ក្នុងការបង្កើតសុំកូនពេញលេញគឺផលប្រយោជន៍របស់កុមារ ចំណែកឯចំណុចសំខាន់ដើម្បីជាមូលហេតុក្នុងការកាត់កាល់ ក៏ត្រូវតែជាផលប្រយោជន៍របស់កុមារដែរ។ យោងតាមមាត្រា ១០១៦ នៃក្រមរដ្ឋប្បវេណី ដើម្បីអាចកាត់កាល់កូនសុំពេញលេញ លក្ខខណ្ឌខាងក្រោមត្រូវតែបំពេញៈ

១. បើមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹមបោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬហេតុផលផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ។

២. បើឪពុកម្តាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ។

៣. ការកាត់កាល់ត្រូវធ្វើឡើងតាមនីតិវិធីបណ្តឹងឋានៈបុគ្គលហើយតុលាការធ្វើការសម្រេចសេចក្តីដោយចេញសាលក្រម។

ប្រសិនបើការកាត់កាល់កូនសុំពេញលេញដែលជានីតិជនដោយយកមូលហេតុនៃការបោះបង់ចោលដោយគំនិតទុច្ចរិត ពុំត្រូវបានទទួលស្គាល់ថាសមស្របទេ ដោយសារតែមាត្រា ១០១៦ ចែងមកក្នុងស្ថានភាពដែលកូនសុំនៅត្រូវការចិញ្ចឹមកាន់តែថយ ករណីកិច្ចមើលថែរក្សាកាន់តែតិចដែរ។ ហេតុនេះស្ថានភាពដែលកូនជានីតិជនកាត់កាល់ឪពុកម្តាយ ត្រូវបានសន្មត់ថា ពុំអាចធ្វើទៅបានឡើយយោងតាមមាត្រា ១០១៦ កថាខណ្ឌទី២។

**១.៣.២.២ អានុភាពនៃការសុំកូនធម្មតា**

**ក. បង្កើតញាតិភាពជាមួយឪពុកម្តាយចិញ្ចឹម**

ក្រោយបង្កើតសុំកូន ញាតិភាពរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំត្រូវបានបង្កើតឡើង កូនសុំមានឋានៈដូចគ្នានឹងកូនបង្កើត មានសិទ្ធិធ្វើសន្តតិកម្មចំពោះគ្នាទៅវិញទៅមក និងកាតព្វកិច្ចចំពោះ គ្នាទៅវិញទៅមកផងដែរ ហើយកូនសុំអាចប្រើប្រាស់នាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលរបស់ខ្លួនមុនពេលបង្កើតសុំកូនបាន។ ក្នុងករណី

---

[២២] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ១០៤៧ កថាខណ្ឌទី១

កូនសុំជាអនីតិជន កូនសុំត្រូវស្ថិតក្រោម អំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ឬឪពុក ឬម្តាយចិញ្ចឹម ប៉ុន្តែក្នុងករណីយកកូនបង្កើតរបស់សហព័ទ្ធមកធ្វើជាកូនសុំ កូនសុំនោះត្រូវស្ថិតក្រោមអំណាចមេបារួមរបស់ឪពុក ឬម្តាយចិញ្ចឹម និងសហព័ទ្ធនោះ។

**ខ. ការបន្តញាតិភាពជាមួយឪពុកម្តាយបង្កើត**

ទោះបីជាសុំកូនត្រូវបានបង្កើតឡើងក៏ដោយ ញាតិភាពរវាងឪពុកម្តាយបង្កើត និងកូនសុំ នៅតែបន្ត ហេតុនេះ កូនសុំ និងឪពុកម្តាយបង្កើតមានសិទ្ធិធ្វើសន្តតិកម្មឲ្យគ្នាទៅវិញទៅមក ហើយក៏មានសិទ្ធិទាមទារ និងករណីកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកដែរ។

ជាទូទៅ សុំកូនធម្មតា កូនសុំនោះមានឪពុកម្តាយបង្កើតផង និងឪពុកម្តាយចិញ្ចឹមផង ហេតុនេះសិទ្ធិក្នុងការធ្វើសន្តតិកម្ម ក៏មានចំពោះគ្នាទៅវិញទៅមកដែរ មានន័យថា មានទាំងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម និងឪពុកម្តាយបង្កើត ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណីកូនសុំជាអនីតិជន អ្នកដែលមានអំណាចមេបាលើកូនសុំ គឺឪពុកម្តាយចិញ្ចឹម ។

**ឃ. លក្ខខណ្ឌនៃការកាត់កាល់សុំកូនធម្មតា**

ដើម្បីឲ្យការកាត់កាល់សុំកូនធម្មតាប្រព្រឹត្តទៅបានលុះត្រាតែមានមូលហេតុដូចខាងក្រោមៈ

១. ភាគីម្ខាងនៃសុំកូន អាចដាក់ពាក្យបណ្តឹងទាមទារ ឲ្យកាត់កាល់បាន លុះត្រាតែៈ

- បើត្រូវបានបោះបង់ចោលដោយភាគីម្ខាងទៀតដោយទុច្ចរិត
- បើមិនច្បាស់ ក្នុងអំឡុងពេលយ៉ាងតិច ១ (មួយ) ឆ្នាំ ថាភាគីម្ខាងទៀតនៅរស់ ឬទទួលមរណភាព។
- បើមានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលបណ្តាលឲ្យមានការពិបាកក្នុងការបន្តសុំកូន

២. ក្នុងអំឡុងពេលដែលកូនសុំពុំទាន់ក្លាយជានីតិជន ឪពុកម្តាយចិញ្ចឹមមិនអាចដាក់ពាក្យបណ្តឹង សុំកាត់កាល់ចំពោះកូនសុំបានឡើយ។

៣. ទោះបីក្នុងករណីកូនសុំជាអនីតិជនក៏ដោយ ក៏កូនសុំអាចដាក់ពាក្យបណ្តឹងចំពោះឪពុកម្តាយចិញ្ចឹមបានដែរ ឲ្យតែបានគោរពលក្ខខណ្ឌដូចដែលបានកំណត់ខាងលើ។

**១.៣.២.៣ អានុភាពនៃការសុំកូនអន្តរប្រទេស**

សុំកូនអន្តរប្រទេស ត្រូវតែជាសុំកូនពេញលេញ។ សុំកូនអន្តរប្រទេសមានអានុភាពបង្កើត នូវទំនាក់ទំនងញាតិរវាងឪពុកម្តាយ និងកូនជាអចិន្ត្រៃយ៍ ដោយផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និងកាតព្វកិច្ច ដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម ហើយវាបញ្ចប់ញាតិភាពរវាងកុមារនិងឪពុក ម្តាយបង្កើតរបស់ខ្លួន ។ ចំពោះអានុភាពផ្សេងទៀតនៃសុំកូនអន្តរប្រទេស ត្រូវគ្រប់គ្រងដោយ ច្បាប់ជាតិរបស់អ្នកសុំ ឬប្រសិនបើគ្មានច្បាប់រួមទេ ត្រូវគ្រប់គ្រងដោយច្បាប់ នៃប្រទេសលំនៅអចិន្ត្រៃយ៍របស់អ្នកសុំ។

## ១.៤ ទោសបញ្ញត្តិ

ជាគោលការណ៍ទោស សំដៅទៅលើទណ្ឌកម្មដែលត្រូវផ្តន្ទាទោសតាមច្បាប់ ដោយតុលាការ ទៅលើបុគ្គលទាំងឡាយណាដែលប្រព្រឹត្តបទល្មើស[២៣] ហើយទោសដែលមានចែងក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេសនេះ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទមានការផ្តន្ទាទោស ចំពោះអំពើល្មើស ពាក់ព័ន្ធនឹងការសុំកូនជាអាទិ៍ ទោសជាការពិន័យអន្តរការណ៍ និង ទោសដាក់ពន្ធនាគារ។

១. ការពិន័យអន្តរការណ៍ៈ ដោយមិនទាន់គិតដល់ទោសប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ជាធរមានមាន ក្រសួងទទួលបន្ទុកវិស័យ សង្គមកិច្ចអាចព្យួរ ឬដកហូតការទទួលស្គាល់ ឬបដិសេធការទទួលស្គាល់ទីភ្នាក់ងារសុំកូនអន្តរប្រទេសសាជាថ្មី ប្រសិនបើមានភស្តុតាងបង្ហាញឱ្យឃើញថា ទីភ្នាក់ងារសុំកូនអន្តរប្រទេសជាប់ពាក់ព័ន្ធនឹងអំពើណាមួយដូចជា អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ឲ្យឪពុកម្តាយ ឬឪពុក ឬម្តាយបោះបង់ ទារកដែលកើតហើយ ឬដែលនឹងកើត ដោយអំពើក្លែងបន្លំ ឬសមគំនិតក្លែងបន្លំស្ថានភាពលំបាកបំផុត ការបង្ខិតបង្ខំ ការគំរាមគំហែង ការឆបោក ឬសន្យាផ្តល់ប្រាក់រង្វាន់ សំណង ឬផលប្រយោជន៍ណាមួយ ។ ការបញ្ចេញសំណុំឯកសារ និងកំណត់ហេតុទាំងអស់ ឬមួយផ្នែកទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ដោយគ្មានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ឬតុលាការមានសមត្ថកិច្ចជាដើម។

គ្មាននរណាម្នាក់អាចទាញយកផលកម្រៃផ្នែកហិរញ្ញវត្ថុ ឬផលកម្រៃដទៃទៀតពីសុំកូនអន្តរប្រទេសនោះទេ មិនថាតែនាយកអភិបាល និងនិយោជិតនៃអង្គការដែលពាក់ព័ន្ធក្នុងរឿងសុំកូនមិនត្រូវទទួលលាភ ដែលខ្ពស់មិនសមរម្យទាក់ទងនឹងសេវាកម្មដែលខ្លួនបានផ្តល់ទេ មានតែសោហ៊ុយ និងប្រាក់ចំណាយ រួមមានប្រាក់ឈ្នួល វិជ្ជាជីវៈសមរម្យរបស់ជន ដែលពាក់ព័ន្ធក្នុងរឿងសុំកូនប៉ុណ្ណោះ ទើបអាចយកបាន ឬចំណាយបាន[២៤]។

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមិនបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល ដែលមានសិទ្ធិធ្វើប្រតិបត្តិការក្នុងនីតិវិធីសុំកូនអន្តរប្រទេស ឬមិនត្រូវអនុញ្ញាត ឱ្យបើក ឬយកមណ្ឌលកុមារកំព្រាជាប្រភពដើម្បីផ្គត់ផ្គង់ទារក និងកុមារកំព្រានៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បើមិនដូច្នោះទេ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀល។ ការដាក់ពិន័យជាអន្តរការណ៍ ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។ ប្រាក់ពិន័យ អន្តរការណ៍នេះ ត្រូវបង់ចូលក្នុងមូលនិធិសម្រាប់ទ្រទ្រង់វិស័យសុខុមាលកុមារ។

---

[២៣] ស្តាយមេរៀន សាស្ត្រាចារ្យ លោកស្រី សាត ធីតា ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តសៀមរាប

[២៤] អនុសញ្ញាទីក្រុងឡាអេស្តីពីការការពារកុមារ និសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ១៩៩៣, មាត្រា៣២

ក្នុងករណី ទីភ្នាក់ងារមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍នេះទេ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចបញ្ជូនសំណុំរឿងទៅតុលាការ[២៥]។

២. ទោសដាក់ពន្ធនាគារៈ ការផ្តន្ទាទោសលើបុគ្គលណាដែលប្រព្រឹត្តអំពើជាបទល្មើស ដោយអនុលោមតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានចូលជាធរមាននៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៨ លើទង្វើដែលមិនស្របច្បាប់ផ្ទុយពីគោលបំណងនៃការសុំកូនអន្តរប្រទេសដូចជា ការនាំយកកុមារចេញដោយខុសច្បាប់ អំពើលក់-ដូរមនុស្ស ក្នុងគោលដៅស្វែងរកផលប្រយោជន៍ផ្សេងៗ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ក្នុងករណីដែលជនរងគ្រោះជាអនីតិជន[២៦] ។ មួយវិញទៀតអំពើសញ្ជារកម្មកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧(ប្រាំពីរ) ឆ្នាំ ដល់ ១៥(ដប់ប្រាំ) ឆ្នាំ កាលបើបុគ្គលដែលធ្វើពេស្យាចារនោះ ជាអនីតិជន លើសពីនេះជនណាដែលផលិតរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ។

[២៥] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា៥៥

[២៦] ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ, នស/រកម/០២០៨/០០៥, ១៥ កុម្ភៈ ២០០៨ , មាត្រា១០

# ជំពូក២

# នីតិវិធីរដ្ឋបាលនៃការស្នុំកូន

## ២.១ រចនាសម្ព័ន្ធនៃស្ថាប័នតុលាការ

ប្រព័ន្ធតុលាការ គឺជាប្រព័ន្ធស្មុគស្មាញមួយ ដោយរួមមានទំនាក់ទំនងរវាងអំណាចរដ្ឋ ស្ថាប័ន និងតួអង្គជាច្រើន។ ការមកដល់របស់អ៊ុនតាក់ (UNTAC) នៅក្នុងឆ្នាំ ១៩៩២ បាននាំមកនូវការផ្លាស់ប្តូរដ៏សំខាន់នៅក្នុងប្រព័ន្ធតុលាការកម្ពុជា។ ប្រព័ន្ធតុលាការត្រូវបានចែកចេញជាបីថ្នាក់គឺៈ

១. សាលាតំបូង (តុលាការថ្នាក់ទី១)

២. សាលាឧទ្ធរណ៍ (តុលាការថ្នាក់ទី២)

៣. តុលាការកំពូល (តុលាការថ្នាក់ទី ៣ និងជាថ្នាក់ចុងក្រោយ) [២៧]។

### ១. សាលាដំបូង

សាលាដំបូង គឺជាតុលាការជាន់ទាបបំផុត ដែលរួមមាន តុលាការខេត្ត ក្រុង និងតុលាការយោធា។ យុត្តាធិការ របស់តុលាការនីមួយៗគ្របដណ្តប់លើតំបន់ភូមិសាស្ត្រជាក់លាក់ណាមួយ ដែលតុលាការស្ថិតនៅ ។ លើកលែងតែតុលាការយោធាមួយប៉ុណ្ណោះ ដែលមានយុត្តាធិការគ្របដណ្តប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល ។

នៅក្នុងតុលាការទទួលពាក្យបណ្តឹងលើកទី១ មានតែចៅក្រមតែម្នាក់ប៉ុណ្ណោះដែលជាអ្នកវិនិច្ឆ័យគ្រប់គ្រងពាក្យបណ្តឹង ។ ប្រព័ន្ធតុលាការជាច្រើននៅក្នុងពិភពលោក បានបង្កើតគណៈកម្មាធិការតុលាការ ដែលមានចៅក្រមចំនួន បីរូប ឬច្រើនជាងនេះ។ ប្រព័ន្ធតុលាការមួយចំនួនទៀតបញ្ចូលឲ្យមានការចូលរួមពីសំណាក់ប្រជាជនសាមញ្ញដែលត្រូវបានជ្រើសតាំងចេញពីសាធារណជនឲ្យមកអង្គុយធ្វើការ និងធ្វើសេចក្តីសម្រេចជាមួយចៅក្រមអាជីព ។

ចៅក្រមត្រូវតែប្រមូលអង្គហេតុ និងភស្តុតាងនានា រួចហើយយកច្បាប់មកប្រើចំពោះអង្គហេតុទាំងនោះ ដំណើររឿងទាំងមូលត្រូវតែគោរពតាមគោលការណ៍នៃការកាត់ក្តីដ៏ត្រឹមត្រូវ [២៨]។

### ២. សាលាឧទ្ធរណ៍

យុត្តាធិការនៃសាលាឧទ្ធរណ៍ គ្របដណ្តប់លើដែនដីទាំងមូលនៃប្រទេសកម្ពុជា ។ តុលាការនេះ មានទីតាំងនៅរាជធានីភ្នំពេញ តុលាការនេះ ជំនុំជំរះរាល់ករណីទាំងអស់ដែលត្រូវបានប្តឹងឧទ្ធរណ៍មកពីសាលាដំបូង គឺតុលាការខេត្ត-ក្រុង និងតុលាការយោធា សាលាឧទ្ធរណ៍ ពិនិត្យទាំង អង្គច្បាប់ និងអង្គហេតុផង ។ ដូច្នេះ ប្រសិនបើ

[២៧]ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៣ ។

[២៨] ពង្រាងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌត្រូវសរសេរឡើងដោយមានជំនួយពីប្រទេសបារាំង ហើយការធ្វើពង្រាងច្បាប់ស្តីពីតិវិធីរដ្ឋប្បវេណី ធ្វើឡើងដោយមានជំនួយមកពីប្រទេសជប៉ុន។ ក្រមនីតិវិធីទាំងពីរនេះត្រូវផ្តល់ការណែនាំដល់ចៅក្រមអំពីរបៀបរៀបចំការកាត់ក្តីប្រកបដោយភាពត្រឹមត្រូវ។

ភាគីណាមួយ មិនពេញចិត្តចំពោះសាលក្រម ឬសេចក្ដីសម្រេច របស់សាលាដំបូង គេនោះមានសិទ្ធិដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ទៅសាលាឧទ្ធរណ៍តាមរយៈការិយាល័យក្រឡាបញ្ជីនៃតុលាការនេះ ដែលកាត់សេចក្ដីលើសាលក្រម ឬសេចក្ដីសម្រេចនោះ ។ នៅពេលនោះ សាលាឧទ្ធរណ៍ នឹងធ្វើការវិនិច្ឆ័យទោសថ្មីមួយ ដែលអាចគោរពតាម កែប្រែ ឬទុកជាមោឃភាពលើសាលក្រម ឬ សេចក្ដីសម្រេចរបស់តុលាការជាន់ទាប ។ សាលាឧទ្ធរណ៍ប្រើនីតិវិធីកាត់ក្ដី ស្រដៀងទៅនឹងនីតិវិធីរបស់តុលាការជាន់ទាបដែរ អ្វីដែលខុសគ្នានោះគឺ ករណីនោះ ត្រូវបានជំនុំជំរះដោយចៅក្រមចំនួនបីរូប ដែលហៅថា " ក្រុមប្រឹក្សាវិនិច្ឆ័យទោស" ហើយគេអាចធ្វើ ការស៊ើបអង្កេតបន្ថែម ដើម្បីរកដំណោះស្រាយចំពោះគម្លាតកត្តានានាដែលតុលាការថ្នាក់ទាបបានបន្សល់ទុក ។ ការប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមរបស់តុលាការថ្នាក់ទាប មិនកំណត់លក្ខខណ្ឌទេ ពុំមានច្បាប់ណាមួយ ចែងអំពីមូលបទដែលគេត្រូវការដើម្បីប្ដឹងឧទ្ធរណ៍ ឬដាក់ពិន័យចំពោះការប្ដឹងឧទ្ធរណ៍មិនសមហេតុផលឡើយ ។

### ៣. តុលាការកំពូល

តុលាការកំពូលមានទីតាំងនៅក្នុងរាជធានីភ្នំពេញ តុលាការនេះគឺជាសាលាឧទ្ធរណ៍ខ្ពស់ជាងគេបំផុត នៅក្នុងប្រទេស ហើយយុត្តាធិការរបស់តុលាការនេះគ្របដណ្ដប់លើដែនដីនៃប្រទេសកម្ពុជាទាំងមូល ។ ចាប់តាំងពីឆ្នាំ ១៩៩៤ តុលាការកំពូលដែលមានក្រុមចៅក្រមចំនួន ៥រូប បានវិនិច្ឆ័យទោសនូវបញ្ហាច្បាប់ លើករណីទាំងអស់ដែលសាលាឧទ្ធរណ៍បានបញ្ជូនទៅ ។ នៅពេលបានទទួលបណ្ដឹងសារទុក្ខលើកទី២ ពីសាលាឧទ្ធរណ៍ដែលតុលាការនោះមិនគោរពតាមសាលក្រមរបស់តុលាការកំពូល នោះក្រុមចៅក្រមចំនួន៩ រូប ត្រូវវិនិច្ឆ័យទោសទាំងលើអង្គច្បាប់ និងអង្គហេតុផង ។

បច្ចុប្បន្ន តុលាការកំពូលត្រូវបានដឹកនាំដោយប្រធានមួយរូប ហើយមានពីរផ្នែកគឺ ផ្នែករដ្ឋប្បវេណី និងសង្គម និងផ្នែកព្រហ្មទណ្ឌ។ ផ្នែករដ្ឋប្បវេណី និងសង្គម ដោះស្រាយទំនាស់រដ្ឋប្បវេណីបញ្ហាអាពាហ៍ពិពាហ៍ គ្រួសារ និងបញ្ហារដ្ឋបាល ព្រមទាំងទំនាស់ការងារ និងពាណិជ្ជកម្ម ផ្នែកព្រហ្មទណ្ឌ ដោះស្រាយតែបញ្ហា ព្រហ្មទណ្ឌប៉ុណ្ណោះ ។ តុលាការកំពូល ពុំមានអំណាចដើម្បីពិនិត្យលើច្បាប់នីតិបញ្ញត្តិ បទបញ្ញានីតិប្រតិបត្តិ ឬអំណាចដើម្បីធ្វើច្បាប់ផ្ទាល់ខ្លួនឡើយ ។ តុលាការនេះមានសិទ្ធិត្រឹមតែអនុវត្តច្បាប់ដែលផ្នែកនីតិបញ្ញត្តិបានតាក់តែងឡើង តែប៉ុណ្ណោះ តុលាការកំពូលកំពុងបោះពុម្ពផ្សាយនូវទស្សនាវដ្ដីប្រចាំត្រីមាសឈ្មោះព្រឹត្តិប័ត្រសាលក្រម របស់តុលាការកំពូល ដែលមានបំណងដើម្បីប្រើប្រាស់ ជាគំរូសាលដីកាដែលតុលាការថ្នាក់ក្រោមត្រូវយកទៅ អនុវត្តតាម ។ ប៉ុន្តែវាមិនទាន់ច្បាស់ថាតើសាលក្រមរបស់តុលាការមុនៗ អាចមានភ្ជាប់ទៅលើករណីស្រដៀងគ្នា នៅពេលក្រោយមែន ដែរ ឬក៏អត់។

# តុលាការ និងសភាជំនាញ
# នៅសាលាដំបូងរាជធានី-ខេត្ត និងសាលាជម្រះក្តីជាន់ខ្ពស់

**សាលាដំបូងរាជធានី-ខេត្ត**

- តុលាការរដ្ឋប្បវេណី
- តុលាការព្រហ្មទណ្ឌ
- តុលាការពាណិជ្ជកម្ម
- តុលាការការងារ
- តុលាការជំនាញផ្សេងទៀត

**សាលាឧទ្ធរណ៍**

- សភារដ្ឋប្បវេណី
- សភាព្រហ្មទណ្ឌ
- សភាការងារ
- សភាពាណិជ្ជកម្ម
- សភាស៊ើបសួរ
- សភាជំនាញផ្សេងទៀត
- សភារួមក្រុម

| ១.សមាសភាព (លើកលែងសភារួមក្រុម) | ២.ការសម្រេចសេចក្តី |
|---|---|
| - ប្រធានសភា | - សភានីមួយៗសម្រេចសេចក្តីដោយចៅក្រម៣ រូប |
| - ចៅក្រម និង | - រឿងក្តីដែលតុលាការបង្វិលមកវិញ ជម្រះដោយចៅក្រម៥ រូប |
| - ក្រឡាបញ្ជី | - កាលបើត្រូវបង្កើតសភារួមក្រុម នោះសមាសភាពចៅក្រមមានចំនួន៥ រូប |

**តុលាការកំពូល**

- សភារដ្ឋប្បវេណី
- សភាព្រហ្មទណ្ឌ
- សភាការងារ
- សភាពាណិជ្ជកម្ម
- សភាជំនាញផ្សេងទៀត
- សភាពេញអង្គ
- សភារួមក្រុម

| ១.សមាសភាព (លើកលែងសភាពេញអង្គ និងសភារួមក្រុម) | ២.ការសម្រេចសេចក្តី |
|---|---|
| - ប្រធានសភា | - សភានីមួយៗសម្រេចសេចក្តីដោយចៅក្រម៥ រូប(សាទុក្ខលើកទី១) |
| - ចៅក្រម និង | - សភាពេញអង្គបង្កើតដំណើរការជំនុំជម្រះ សភាជុំនុំជម្រះចៅក្រម៩ រូប |
| - ក្រឡាបញ្ជី | - ការបង្កើតសភារួមក្រុម ចៅក្រមមានយ៉ាងតិចចំនួន៩ រូប |

## ២.២ នីតិវិធីនៃការសុំកូន

### ២.២.១ នីតិវិធីតុលាការចំពោះការបង្កើតសុំកូនពេញលេញ

ដំណើរការនីតិវីធីនៃការសុំកូននេះ យើងអាចនិយាយបានថាជាលក្ខខណ្ឌទម្រង់នៃការសុំកូន។ ដែលមានន័យថាជានីតិវីធីក្នុងការដាក់ពាក្យសុំទៅតុលាការ និងការទទួលដីការសម្រេចពីតុលាការ ក្នុងការអនុញ្ញាតអោយសុំកូន។ ការតម្រូវអោយឆ្លងកាត់តុលាការវាជាភាពចាំបាច់ ព្រោះកម្មវត្ថុនៃសុំកូនពេញលេញគឺកំណត់យកអនីតិជន ហើយការកំណត់បែបនេះដើម្បីអោយមានការស្រាវជ្រាវ និងវិនិច្ឆ័យដោយប្រុងប្រយ័ត្នអំពីផលប្រយោជន៍របស់កុមារ។

**១. អ្នកមាសិទ្ធិដាក់ពាក្យសុំ:** យោងតាមមាត្រា ១៦ នៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (NSCC) បុគ្គលដែលអាចដាក់ពាក្យសុំ ត្រូវតែជាជនពាក់ព័ន្ធ ដែលអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមគឺជាបុគ្គលដែលមានសិទ្ធិតាមបញ្ញត្តិសារជាតុក្នុងការដាក់ពាក្យសុំ [២៩] ។ នៅក្នុងពាក្យសុំ ចាប់ផ្តើមរបបសុំកូនពុំចាំបាច់មានការដាក់ពាក្យរួមគ្នាជាមួយឪពុកម្តាយបង្កើតរបស់កូនសុំទេ។ ចំណែកឯលក្ខខណ្ឌនៃការព្រមព្រៀងតាមមាត្រា ១០១១ (ការយល់ព្រមរបស់ឪពុកម្តាយ) នៃក្រមនេះនៅក្នុងដំណើរការនៃការជំនុំជម្រះលើពាក្យសុំ តុលាការនឹងសាកសួរឪពុកម្តាយបង្កើត ក្នុងនាមជាជនពាក់ព័ន្ធ អំពីការឯកភាពអោយបង្កើតរបបសុំកូនពេញលេញ[៣០]។

ជាគោលលការណ៍របបសុំកូន មិនអាចបង្កើតបានឡើយប្រសិនបើពុំមានការឯកភាពពី ឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កូនសុំ[៣១]។ ជាវិធានសីលធម៌ការយកកុមារចេញពីគ្រួសារបង្កើតរបស់ពួកគេ ត្រូវមានការឯកភាពពីបុគ្គល ដែលមានករណីកិច្ចត្រួតពិនិត្យ។ ប៉ុន្តែដើម្បីការពារឧត្តមប្រយោជន៍របស់កុមារ កាលបើឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ពុំមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ ឬ បានធ្វើបាប ឬបោះបង់កុមារចោលដោយគំនិតទុច្ចរិត ឬមូលហេតុផ្សេងទៀត របបសុំកូនពេញលេញត្រូវបង្កើតឡើងដោយពុំចាំបាច់មានការឯកភាពពីជនទាំងនោះឡើយ។

សកម្មភាពដាក់ពាក្យសុំក៏តម្រូវអោយអ្នកដាក់ពាក្យមានសមត្ថភាពនៅក្នុងការធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងដែរ។ ក្នុងករណីដែលសហព័ទ្ធណាម្ខាង គឺជាជនដែលស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅ សកម្មភាពដាក់ពាក្យសុំរបស់សហព័ទ្ធនោះក៏ត្រូវបានទទួលស្គាល់ដែរ [៣២] ។ ប៉ុន្តែប្រសិនបើនៅពេលដាក់ពាក្យសុំ សហព័ទ្ធនោះពុំមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈទេ [៣៣] ពោលគឺ ពុំអាចយល់ដឹង

[២៩] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០០៧

[៣០] ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង មាត្រា ២៩

[៣១] ក្រមរដ្ឋប្បវេណី មាត្រា ១០១១ វាក្យខណ្ឌ១

[៣២] ច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង មាត្រា១៧

[៣៣] ក្រមរដ្ឋប្បវេណី មាត្រា ១៤

បានអំពីលទ្ធផលតាមផ្លូវច្បាប់នៃអំពើរបស់ខ្លួន សហព័ន្ធនោះពុំមាន លក្ខណៈសម្បត្តិជាអ្នកដាក់ពាក្យសុំឡើយ ហើយវិធានការតំណាងពិសេសមិនអាចយកមកអនុវត្តឡើយក្នុងនីតិវិធីនេះព្រោះរបបអ្នកតំណាងពិសេសអនុវត្តតែចំពោះជនដែលខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាព។

**២. ទម្រង់ពាក្យសុំ:** នីតិវិធីសុំកូន ត្រូវធ្វើដោយអនុទ្បោមតាមច្បាប់ស្តីពីនីតិវិធីរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ ពាក្យសុំអោយតុលាការចេញដីកាសម្រេចចាប់ផ្តើមសុំកូនត្រូវសរសេរចំណុចនីមួយៗដូចខាងក្រោម ៖

- អត្តសញ្ញាណជនពាក់ព័ន្ធ៖ ឈ្មោះ និងអាសយដ្ឋានអ្នកដាក់ពាក្យសុំ (របស់ឪពុកម្តាយចិញ្ចឹម) និងភាគីម្ខាងទៀត (ឪពុកម្តាយបង្កើត និងកូនសុំ)
- ខ្លឹមសារនៃដីការសម្រេច៖ សុំឲ្យតុលាការចេញដីការសម្រេចចាប់ផ្តើមរបបសុំកូនឪពុកម្តាយចិញ្ចឹមឈ្មោះ ...............និង កូនសុំឈ្មោះ.............
- អង្គហេតុដែលជាមូលហេតុនៃការទាមទារ៖ ត្រូវបង្ហាញអោយតុលាការយល់អំពីស្ថានភាពលំបាករបស់កុមារនៅក្នុងគ្រួសារបង្កើត របបសុំកូនពិតជាអាចធ្វើអោយស្ថានភាពរស់នៅរបស់កុមារមានភាពល្អប្រសើរជាងមុន
- ឧបសម្ព័ន្ធពាក្យសុំ៖ សេចក្តីចម្លងសំបុត្រកំណើតរបស់ឈ្មោះ អ្នកដាក់ពាក្យសុំ និងកូនសុំ។

**៣.ទីកន្លែងនៃការដាក់ពាក្យសុំ:** ពាក្យសុំត្រូវដាក់នៅតុលាការខាងលំនៅឋានរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម[៣៤] ។ ក្នុងករណីដែលបុគ្គលដែលជាអ្នកសុំមិនមានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ដូច្នេះគេនឹងកំណត់យកទីសំណាក់របស់បុគ្គលនោះដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាធ្វើជាលំនៅឋាន[៣៥]។

**៤. ពន្ធដែលត្រូវបង់នៅពេលដាក់ពាក្យសុំ:** តាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង អ្នកដាក់ពាក្យសុំត្រូវបង់ ពន្ធចំនួន ៥០០០(ប្រាំពាន់) រៀល[៣៦] ។

**៥. មូលដ្ឋានវិនិច្ឆ័យដែលតុលាការនឹងពិចារណា:** ក្នុងករណីលក្ខខណ្ឌផ្សេងៗខាងលើត្រូវបានបំពេញក៏ដោយតុលាការនឹងត្រូវពិនិត្យលើស្ថានភាពផ្សេងទៀតដែលមានឥទ្ធិពលក្នុងការសម្រេចបង្កើតសុំកូនពេញលេញដែលស្ថានភាពទាំងនោះរួមមានដូចជា ការលំបាកក្នុងការគ្រប់គ្រងថែរក្សាកូន ដោយសារតែឪពុកម្តាយបង្កើតក្រីក្រខ្លាំង មានជំងឺផ្លូវកាយ វិបត្តិស្មារតីធ្ងន់ធ្ងរ កំពុងបាត់ខ្លួនជាអាទិ៍។ ភាពមិនសមស្របក្នុងការថែរក្សាកូន មានជាការបំពាន ឬធ្វើបាបផ្លូវកាយ ឬតាមរយៈពាក្យសំដី ការធ្វេសប្រហែសក្នុងការមិនអើពើថែរក្សាកូនជាដើម។ មួយវិញទៀតភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍កូន ដោយតុលាការមើលទៅលើភាពល្អប្រសើរសម្រាប់កូននោះទាំងផ្នែកស្មារតី

---

[៣៤] ច្បាប់ស្តីអំពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឧបសម្ព័ន្ធទី៤ ចំណុចទី៧

[៣៥] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មាត្រា៣៦

[៣៦] ច្បាប់ស្តីអំពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១១ មាត្រា២២ កថាខណ្ឌទី១

និងសម្ភារៈក្នុងការរស់នៅជាមួយបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមជាងរស់នៅជាមួយឪពុកម្តាយបង្កើត [៣៧] ។ ស្មុំកូនពេញលេញមានអានុភាពតាមផ្លូវច្បាប់ លុះត្រាតែបានបង្កើតតាមផ្លូវតុលាការ មានន័យថាបុគ្គលដែលមានបំណងបង្កើតស្មុំកូនពេញលេញ ត្រូវដាក់ពាក្យសុំទៅតុលាការ។

**៦. ការចេញដីកាសម្រេចរបស់តុលាការ:** យោងតាមមាត្រា១០០៧ នៃក្រមរដ្ឋប្បវេណី ដើម្បីចេញសេចក្តីសម្រេចចាប់ផ្តើមពីរបបស្មុំកូនតុលាការត្រូវធ្វើការវិនិច្ឆ័យអំពីៈ

១.ឆន្ទៈព្រមព្រៀងរវាងសហព័ទ្ធជាឪពុកម្តាយចិញ្ចឹម

២.អាយុរបស់កូនសុំ និងឪពុកម្តាយចិញ្ចឹម

៣.ឯកភាពរបស់ឪពុកម្តាយបង្កើត

៤.លទ្ធភាពដែលអាចធ្វើអោយកុមារមានការថែទាំប្រសើរជាងមុន។

ដើម្បីអាចចេញដីកាសម្រេចចាប់ផ្តើមស្មុំកូន ចាំបាច់ឆ្លងកាត់ការចិញ្ចឹមសាកល្បង [៣៨] ។ ប៉ុន្តែប្រសិនបើអ្នកដាក់ពាក្យសុំបានធ្វើការចិញ្ចឹមកូនមុនពេលដាក់ពាក្យសុំកន្លងមក ហើយបើយល់ឃើញថាគ្មានភាពចាំបាច់ក្នុងការចិញ្ចឹមសាកល្បងទេ តុលាការអាចចេញសេចក្តីសម្រេចចាប់ផ្តើម របបសុំកូនដោយសរសេរបន្ថែមត្រង់ផ្នែកសំអាងហេតុថាអ្នកដាក់ពាក្យសុំបានចិញ្ចឹមកូនសុំពេលកន្លងមកហើយតុលាការទទួលស្គាល់ការចិញ្ចឹមនេះ។ ហើយបើយល់ឃើញថាគ្មានភាពចាំបាច់ក្នុង ការចិញ្ចឹមសាកល្បងទេ តុលាការអាចចេញដីកាក្នុងករណីដែលឪពុកម្តាយចិញ្ចឹមមានបំណងដកពាក្យសុំ មុនពេលដែលតុលាការចេញសេចក្តីសម្រេចការធ្វើនេះអាចត្រូវបានអនុញ្ញាត ដោយសារមូលហេតុ បុគ្គលដែលបានដាក់ពាក្យសុំបាត់បង់ឆន្ទៈក្នុងការស្មុំកូនពេញលេញ។ ប៉ុន្តែបើការធ្វើនេះនៅក្រោយពេលតុលាការចេញដីកាសម្រេច ពោលគឺអំឡុងពេលបណ្តឹងជំទាស់ ជាចំណុចដែលចាំបាច់ត្រូវធ្វើការបកស្រាយ ព្រោះច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ពុំបានចែងពីបញ្ហានេះ។ តាមច្បាប់ស្តីពីនីតិវិធីទាក់ទងនឹងទំនាក់ទំនងគ្រួសាររបស់ប្រទេសជប៉ុនមានតែដីការសម្រេចច្រានចោលពាក្យសុំទេ ដែលភាគីដាក់ពាក្យសុំអាចប្តឹងជំទាស់។ បន្ថែមពីនេះទៀត មាត្រា៨២ នៃច្បាប់ដដែលបានសម្តែងថា ៖ «លើកលែងតែមានបទបញ្ញត្តិពិសេសចែងផ្ទុយពីនេះ អ្នកដាក់ពាក្យសុំអាចដកពាក្យសុំមួយផ្នែក ឬទាំងមូល មុនពេលតុលាការចេញដីកាសម្រេចលើពាក្យសុំ។» យោងតាមគោលគំនិតនៃមាត្រានេះ រាល់ការដកពាក្យសុំ ក្រោយពេលតុលាការចេញដីកាសម្រេចចាប់ផ្តើមស្មុំកូនពេញលេញ មិនត្រូវអនុញ្ញាតអោយធ្វើឡើយ។ ដោយឡែកច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង របស់កម្ពុជាវិញ ការដកពាក្យបណ្តឹង និងបណ្តឹងឧបាស្រ័យចំពោះដីកាសម្រេចច្រានចោលពាក្យសុំ ពុំមានចែងទេ ហើយវាអាស្រ័យលើការបកស្រាយរបស់ភាគី កម្ពុជាចំពោះបញ្ហាខាងលើនេះ។

---

[៣៧] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មាត្រា១០១២

[៣៨] ក្រមរដ្ឋប្បវេណីមាត្រា ១០១៣

### ២.២.២ នីតិវិធីតុលាការចំពោះការបង្កើតសុំកូនធម្មតា

នីតិវិធីក្នុងការបង្កើតសុំកូនធម្មតា គឺមានចំណុចភាគច្រើនដូចគ្នាទៅនឹងនីតិវិធីតុលាការចំពោះការបង្កើតសុំកូនពេញលេញ វាមានភាពខុសគ្នាបន្តិចបន្តួចត្រង់ចំណុចខ្លះ។ ការតម្រូវឲ្យឆ្លងកាត់តុលាការ វាជាភាពចាំបាច់ ព្រោះកម្មវត្ថុនៃសុំកូនធម្មតា អាចជានីតិជន ឬ អនីតិជន ហើយការកំណត់បែបនេះ ដើម្បីឱ្យមានការស្រាវជ្រាវ និងវិនិច្ឆ័យដោយប្រុងប្រយ័ត្នអំពីផលប្រយោជន៍របស់កុមារ ។

**១. អ្នកមានសិទ្ធិដាក់ពាក្យសុំ:** ក្នុងករណីដែលកូនសុំជានីតិជន បុគ្គលដែលក្លាយជាឪពុកម្តាយចិញ្ចឹម ត្រូវដាក់ពាក្យសុំរួម គ្នាជាមួយបុគ្គលដែលនឹងក្លាយជាកូនសុំ។ បើបុគ្គលដែលជាកូនសុំ ជាបុគ្គលដែលមានសហព័ទ្ធ មិនចាំបាច់មានការយល់ព្រមពីសហព័ទ្ធនៃបុគ្គលដែលជាកូនសុំនោះទេព្រោះសុំកូនធម្មតា បង្កើតឡើងដោយឆន្ទៈរបស់ភាគីផ្ទាល់ តែបើកូនសុំជាអនីតិជន បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ត្រូវដាក់ពាក្យ សុំរួមជាមួយអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កូនសុំ ក្នុងនាមជាអ្នកមានអំណាចមេបា [៣៩] ម្យ៉ាងវិញទៀតបើកូនសុំជាអនីតិជនដែលមានអាយុដល់ ១៥ឆ្នាំ គឺការដាក់ពាក្យសុំត្រូវមានការយល់ព្រមពី អនីតិជននោះដោយមានន័យថា បើអនីតិជននោះបដិសេធ សុំកូននឹងមិនអាចបង្កើតបានឡើយ [៤០]។

**២. មូលដ្ឋានវិនិច្ឆ័យដែលតុលាការនឹងពិចារណា:** តុលាការធ្វើការវិនិច្ឆ័យ អំពីការបង្កើតសុំកូនធម្មតា ដោយផ្អែកលើមូលដ្ឋានដូចជា មានការបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ភាគី ក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្តាយ និងកូន។ សុំកូនត្រូវបានបំពេញក្នុងគោលបំណង អាពាហ៍ពិពាហ៍រវាងភេទដូចគ្នា ឬផ្សេងគ្នា ឬក្នុងគោលបំណង មិនត្រឹមត្រូវផ្សេងទៀត។ ក្នុងករណីកូនសុំជាអនីតិជន តុលាការអាចឲ្យបង្កើតសុំកូនបានលុះត្រាតែយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូនសុំដែលជាអនីតិជននោះ។ តុលាការត្រូវពិចារណាអំពីឆន្ទៈរបស់អនីតិជន កាលបើអនីតិជនមានអាយុដល់១៥ ឆ្នាំ ហើយទោះបីជាពុំមានអាយុដល់១៥ ឆ្នាំក៏ដោយ ក៏តុលាការអាចសួរយោបល់ពីអនីតិជនបានដែរ។ ម្យ៉ាងទៀតក្នុងករណីឪពុកម្តាយបង្កើតលែងលះគ្នា មុននឹងសម្រេចបង្កើតសុំកូនធម្មតា តុលាការក៏ត្រូវសួរយោបល់ពីឪពុក ឬម្តាយបង្កើតដែលមិនមែនជាអ្នកមានអំណាចមេបារ។

ទីកន្លែងនៃការដាក់ពាក្យសុំត្រូវដាក់នៅតុលាការខាងលំនៅឋានរបស់បុគ្គលដែលនឹងក្លាយជាកូនសុំ [៤១] ។ ចំពោះទម្រង់នៃពាក្យសុំ និងពន្ធដែលត្រូវបង់នៅពេលដាក់ពាក្យសុំកូនធម្មតា គឺដូចគ្នាទៅនឹងនីតិវិធីសុំកូនពេញលេញដែរ។

---

[៣៩] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មាត្រា១០២០ កថាខណ្ឌទី២

[៤០] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មាត្រា១០២៨ កថាខណ្ឌទី៣

[៤១] ច្បាប់ស្តីអំពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឧបសម្ព័ន្ធទី៤ ចំណុចទី៩

### ២.២.៣ នីតិវិធីនៃការកាត់កាល់ស្មុំកូន

#### ក. ការដាក់ពាក្យបណ្តឹង និងចំណុចដែលត្រូវសរសេរ

ក្រៅពីការកាត់កាល់ស្មុំកូនធម្មតាដោយការព្រមព្រៀង ការកាត់កាល់ក៏អាចធ្វើទៅតាមការកំណត់របស់ច្បាប់ផងដែរ។ ការកាត់កាល់ដែលធ្វើឡើងដោយច្បាប់កំណត់ ភាគីនៃស្មុំកូនដែលមានបំណងចង់កាត់កាល់ ត្រូវធ្វើពាក្យបណ្តឹងទៅតុលាការ ដោយមានមូលហេតុត្រឹមត្រូវតាមច្បាប់កំណត់។ របៀបនៃការធ្វើពាក្យបណ្តឹងគឺមានកំណត់នៅក្នុងមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានបញ្ញត្តិថា "ពាក្យបណ្តឹងអាចធ្វើឡើងជាលាយល័ក្ខអក្សរ បានលើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ឬច្បាប់ផ្សេងទៀត" ។ នៅក្នុងពាក្យបណ្តឹង ត្រូវសរសេរបញ្ជាក់អំពី ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ ឬអាសយដ្ឋានរបស់អ្នកតំណាងស្របច្បាប់ បានកំណត់ ( ករណីកូនសុំជាអនីតិជន ) ខ្លឹមសារនៃសាលក្រម ឬសកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យបណ្តឹងទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ។ ហើយដើម្បីដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់ អ្នកដាក់ពាក្យបណ្តឹងត្រូវធ្វើសេចក្តីថ្លែងការណ៍ នៅចំពោះមុខក្រឡាបញ្ជី ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និងចុះហត្ថលេខា ដែលកំណត់ហេតុនោះត្រូវបានចាត់ទុកជា ពាក្យបណ្តឹង។ ក្នុងករណីដែលមានឯកសារជាភស្តុតាង អ្នកដាក់ពាក្យបណ្តឹងត្រូវភ្ជាប់មកជាមួយនូវឯកសារដើម ឬឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិត នៃពាក្យបណ្តឹង ឬដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យបណ្តឹ។

#### ខ. ការវិនិច្ឆ័យលើបណ្តឹងកាត់កាល់

នីតិវិធីឋានៈបុគ្គល និងនីតិវិធីរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងមានលក្ខណៈដូចគ្នា ជារួមមួយគឺ ការជំនុំជម្រះក្តីដោយឆន្ទានុសិទ្ធិ។ តុលាការនៅក្នុងរឿងក្តីបណ្តឹងឋានៈបុគ្គល មានឆន្ទានុសិទ្ធិក្នុងការស្រាវជ្រាវអង្គហេតុ និងភស្តុតាង និងយកអង្គហេតុដែលភាគីមិនអះអាងធ្វើជាមូលដ្ឋានក្នុងការចេញសាលក្រម[៤២]។ គោលការណ៍ជម្រះក្តីផ្អែកលើអង្គហេតុដែលបានលើកឡើង ពុំត្រូវយកមកអនុវត្តឡើយ។ លក្ខណៈដូចគ្នាអាចស្តែងចេញជាការមិនគោរពគោលការណ៍សេរីភាពក្នុងការចាត់ចែងសិទ្ធិ និងគោលការណ៍ចំពោះមុខ ប៉ុន្តែយ៉ាងនេះក្តីនីតិវិធីកាត់កាល់តុលាការត្រូវធ្វើការទាញយកហេតុផលដោយផ្ទាល់មាត់។ ការទាញហេតុផល ពុំមែនជាការទទួលស្គាល់ទាំងស្រុងនូវសិទ្ធិចាត់ចែងរបស់ភាគី ជាអាទិ៍ការសារភាព ការទទួលស្គាល់ការទាមទារ ឬការផ្សះផ្សារបស់ភាគីទេ[៤៣]។ តុលាការមិនចង់អោយករណីទទួលស្គាល់អង្គហេតុតាមរយៈភស្តុតាង[៤៤] ដូចនីតិវិធីបណ្តឹងធម្មតាទ។

---

[៤២] ក្រមរដ្ឋប្បវេណីមាត្រា៩៤ និងច្បាប់ស្តីពីនីតិវិធីបណ្តឹងឋានៈបុគ្គលមាត្រា១៤

[៤៣] ក្រមនីតិរដ្ឋប្បវេណីមាត្រា១៣

[៤៤] ក្រមនីតិរដ្ឋប្បវេណីមាត្រា១២៣ វាក្យខណ្ឌទី១

ក្នុងរឿងក្តីកាត់កាល់ តុលាការប្រើអំណាចឆន្ទានុសិទ្ធិគ្រប់មធ្យោបាយនៅក្នុងការទទួលបាន ធនធានភស្តុតាង ដើម្បីធ្វើការវិនិច្ឆ័យ គឺជាអង្គហេតុដែលមានចែងក្នុងមាត្រា១០១៦។

**គ. ការសម្រេចសេចក្តីកាត់កាល់ដោយសាលក្រម ឬ សាលដីកា**

នៅក្នុងរឿងក្តីកាត់កាល់តាមរយៈពាក្យបណ្តឹង តុលាការត្រូវសម្រេចសេចក្តីដោយចេញ នូវសាលក្រម ចំពោះតុលាការជាន់ទាប និង សាលដីកា ចំពោះតុលាការជាន់ខ្ពស់ ។ ចំពោះរឿងក្តី កាត់កាល់តាមរយៈបណ្តឹង តុលាការពុំអាចចេញសាលក្រមកំបាំងមុខលើដើមចោទ ឬសាលក្រម កំបាំងមុខចុងចម្លើយតាមក្រមនីតិវិធីរដ្ឋប្បវេណីបានទេ ដោយហេតុថា ចំពោះរឿងក្តីកាត់កាល់ វាធ្វើឲ្យប៉ះពាល់ទៅដល់ផលប្រយោជន៍របស់ភាគីយ៉ាងខ្លាំង ទើបមានការហាមឃាត់ចំពោះការអនុវត្តនៃការចេញនូវសាលក្រមកំបាំងមុខ ។

ហេតុដូចនេះមុននឹងតុលាការចេញសេចក្តីសម្រេចចាំបាច់ត្រូវមានវត្តមានរបស់គូភាគី ដើម្បីធានានូវសិទ្ធិក្នុងការបញ្ចេញមតិយោបល់ សំណូមពរ ក៏ដូចជាដំណាក់កាលចុងក្រោយនៃការ ទាមទាររបស់ខ្លួនចំពោះមុខចៅក្រមជំនុំជម្រះ ក្រុមប្រឹក្សាជំនុំជម្រះ ។ ម្យ៉ាងទៀត តុលាការក៏អាចពិចារណាបន្ថែមទៀត ទៅលើការអះអាងនោះដើម្បីចេញនៅសាលក្រមចុងក្រោយឲ្យមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ដល់ភាគីផ្អែកលើការស្រាវជ្រាវ និងការពិតជាក់ស្តែង។ ជាពិសេសនៅក្នុង កាលបរិច្ឆេទលើកទី១នៃនីតិវិធីទាញហេតុផល តុលាការមិនអាចចេញសាលក្រមកំបាំងមុខ ហើយច្រានចោលការទាមទាររបស់ដើមចោទនរឿងក្តីកាត់កាល់បានឡើយ។

**២.២.៤ នីតិវិធីសុំកូនអន្តរប្រទេស**

នីតិវិធីសុំកូនអន្តរប្រទេសមាន២ ដំណាក់កាលគឺ នីតិវិធីរដ្ឋបាលនៃការសុំកូនអន្តរប្រទេស និងនីតិវិធីតុលាការ ។

**ក. នីតិវិធីរដ្ឋបាលសុំកូនអន្តរប្រទេស**

ក្នុងដំណាក់កាលនៃនីតិវិធីរដ្ឋបាលក្នុងការសុំកូន ត្រូវឆ្លងកាត់ការដាក់ពាក្យសុំរបស់អ្នកសុំ ហើយត្រូវបានពិនិត្យយ៉ាងហ្មត់ចត់ជាមុន ដើម្បីសម្រេចលើពាក្យសុំថាត្រឹមត្រូវ និងគ្រប់គ្រាន់ចំពោះសំណុំឯកសារស្នើសុំ។

**១. ការដាក់ពាក្យ៖** អ្នកសុំត្រូវដាក់ពាក្យសុំកូនទៅអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាដោយភ្ជាប់មកជាមួយនូវឯកសាររួមមានដូចជា ភស្តុតាងដែលបញ្ជាក់ថា អាជ្ញាធរនៃប្រទេសដើមរបស់ខ្លួន ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ចាត់ទុកថា អ្នកសុំមានលក្ខណសម្បត្តិ និងមានភាពសមស្របសម្រាប់សុំកូនដោយផ្អែកលើការវាយតំលៃលើជីវប្រវត្តិផ្ទាល់ខ្លួន ប្រវត្តិគ្រួសារ ប្រវត្តិសុខភាព បរិយាកាសគ្រួសារ បរិយាកាសសង្គម មូលហេតុសុំកូន និងលទ្ធភាពនៃការទទួលបន្ទុករ៉ាប់រងចំពោះសុំកូនអន្តរប្រទេស។ មួយវិញទៀតព័ត៌មានចាំបាច់ទាក់ទងនឹងការឆ្លើយតបទៅនឹងលក្ខខណ្ឌនានាដែលមានចែងក្នុងមាត្រា២១ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស។ ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកសុំដែលក្នុងនោះរួមមាន ឯកសារទាក់ទងនឹងអត្រានុកូលដ្ឋាន។ ព័ត៌មានទាក់ទងនឹងលក្ខណសម្បត្តិផ្សេងៗរបស់កុមារដែល

អ្នកសុំអាចនឹងមានលក្ខណសម្បត្តិថៃទាំបាន។ ភស្តុតាងទទួលបានពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលដែលបញ្ជាក់ថា នៅពេលពាក្យសុំកូនរបស់ខ្លួនត្រូវបានយល់ព្រម ហើយកូនសុំនោះត្រូវបានអនុញ្ញាតឲ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសទទួល។

ឯកសារទាំងអស់ ត្រូវបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ។ ឯកសារច្បាប់ដើមទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេស ឬ ភាសាបារាំង ដែលមានការបញ្ជាក់ត្រឹមត្រូវ[៩៥]។. ចំពោះពាក្យសុំបង្កើតស្មុំកូនអន្តរប្រទេស អាចធ្វើទៅបានទាំងក្នុងករណីដែលកុមារនោះ ជាសាច់ញាតិ ឬ មិនមែនជាសាច់ញាតិរបស់អ្នកសុំក៏ដោយ គឺត្រូវប្រព្រឹត្តទៅតាមបញ្ញាត្តិនៃច្បាប់ស្តីពី ស្មុំកូនអន្តរប្រទេសដូចគ្នា[៩៦]។

ពាក្យសុំដែលមានភ្ជាប់រួចជាស្រេចនូវភស្តុតាងដែលតម្រូវ បានដាក់រួចរាល់រួចហើយនោះ ត្រូវបញ្ជូនមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមរយៈអាជ្ញាធរកណ្តាល ស្ថានទូត ឬស្ថានតំណាងនៃប្រទេសទទួលប្រចាំនៃព្រះរាជាណាចក្រកម្ពុជាដែលបានបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារនោះ។ ក្រសួងការបរទេស និងការសហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យផ្តល់យោបល់ និងត្រូវបញ្ជូនសំណុំឯកសារស្មុំកូនអន្តរប្រទេសទៅក្រសួងបន្ទុកវិស័យសង្គមកិច្ចក្នុងរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលបានពាក្យសុំ។ ក្នុងរយៈពេលយ៉ាងយូរបំផុត ១៥(ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលបានពាក្យសុំពី ក្រសួងការបរទេស និងការសហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលស្មុំកូនអន្តរប្រទេសត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកបានសុំកូនដោយបញ្ជាក់ថាខ្លួនបានទទួលពាក្យសុំកូននេះ តាមរយៈអាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់អ្នកសុំ ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកស្មុំកូនអន្តរប្រទេស ឬតាមរយៈទីភ្នាក់ងារស្មុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍[៩៧]។

**២. ការពិនិត្យពាក្យសុំ៖** បន្ទាប់ពីបានទទួលពាក្យសុំរដ្ឋបាលស្មុំកូនអន្តរប្រទេស[៩៨] អនុវត្តភារកិច្ចត្រួតពិនិត្យពីភាពត្រឹមត្រូវ និង ភាពគ្រប់គ្រាន់នៃសំណុំលិខិតស្នើសុំក្នុងរយៈពេល ៦០(ហុកសិប) (បន្ទាប់ពីថ្ងៃដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចទទួលសំណុំលិខិតឯកសារ។ ប្រសិនបើសំណុំលិខិតឯកសារនៅមិនទាន់គ្រប់គ្រាន់ ឬមិនទាន់ត្រឹមត្រូវរដ្ឋបាលស្មុំកូនអន្តរប្រទេស ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអ្នកសុំតាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកស្មុំកូនអន្តរប្រទេស ឬទីភ្នាក់ងារស្មុំកូនអន្តរប្រទេស ត្រូវត្រួតពិនិត្យឯកសារដែលស្នើសុំឲ្យកែតម្រូវ ស្មើគ្នានឹងអំឡុងពេលខាងលើគឺ ៦០ថ្ងៃដែរ។

---

[៩៥] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស មាត្រា២៣ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

[៩៦]ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស មាត្រា៣១ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

[៩៧] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស មាត្រា២៤ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

[៩៨] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស មាត្រា២៦ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

អំឡុងពេលដែលបានកំណត់ខាងលើ ក្រោយពីមានការជូនដំណឹងពីរដ្ឋបាលកណ្ដាលសុំកូន អន្តរប្រទេសឲ្យកែតម្រូវអ្នកសុំបានធ្វើឲ្យមានភាពយឺតយ៉ាវ នោះពាក្យសុំត្រូវចាត់ទុកជាមោឃៈ[៤៩]។

**៣. ការសម្រេចលើពាក្យសុំ៖** ក្នុងករណីដែលសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ[៥០] ហើយអ្នកសុំបានបំពេញលក្ខខណ្ឌច្បាប់សុំកូនអន្តរប្រទេស រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យពិចារណាទៅលើសំណុំឯកសាររបស់កុមារ ទាំងឡាយ ដែលមានលក្ខណសម្បត្តិសុំកូនអន្តរប្រទេសបាន និងផ្គូផ្គងលក្ខណសម្បត្តិដែលត្រូវគ្នាល្អបំផុតនិងលក្ខណសម្បត្តិកុមារ[៥១]។

ភារកិច្ចបន្តរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវផ្ញើសំណុំឯកសាររបស់កុមារដែលបានផ្គូផ្គងរួចហើយនោះដោយរួមទាំងភស្តុតាងដែលបង្ហាញថា រាល់ការយល់ព្រមចាំបាច់នានា និងអំពីមូលហេតុដែលខ្លួនកំណត់ ទុកដាក់កុមារជាមួយអ្នកសុំទៅអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសដើម្បីពិនិត្យ និងបញ្ជូនទៅអ្នកសុំដោយមិនចាំបាច់ជូនដំណឹងអំពី អត្តសញ្ញាណរបស់ឪពុកម្ដាយ ឬឪពុក ឬម្ដាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនឡើយ វៀរលែងតែការសុំកូនដោយសាច់ញាតិ[៥២]។

ជាគោលការណ៍ អ្នកសុំត្រូវធ្វើការឆ្លើយតបវិញជាលាយលក្ខណ៍អក្សរអំពីការយល់ព្រមសុំកុមារដែលខាង រដ្ឋបាលសុំកូនបានផ្គូផ្គងឲ្យ ទៅកាន់រដ្ឋបាលសុំកូនអន្តរប្រទេសវិញ តាមរយៈអាជ្ញាធរកណ្ដាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារ សុំកូនអន្តរប្រទេសនៃប្រទេសទទួល ដោយកំណត់អំឡុងពេល ៦០ ថ្ងៃ (ថ្ងៃធ្វើការ រាប់ចាប់ពីពេលរដ្ឋបាលសុំកូនបានផ្ញើសំណុំឯកសារទៅកាន់អ្នកសុំ)។ ក្នុងករណី អ្នកសុំមិនបានឆ្លើយតបទាន់ក្នុងរយៈពេលខាងលើទេ ត្រូវចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន។ តែមិនយកមកអនុវត្តឡើយ ក្នុងករណីដែលមានការខកខាននោះមានមូលហេតុត្រឹមត្រូវ ដោយរដ្ឋបាលសុំកូនអន្តរប្រទេសជាអ្នកមានសមត្ថកិច្ចក្នុងសម្រេចថា តើឲ្យមានការផ្គូផ្គងសារជាថ្មី ឬការទទួលពាក្យសុំកូនសារជាថ្មី[៥៣]។

---

[៤៩] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស មាត្រា២៤ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

[៥០] ក្នុងការផ្គូផ្គងដោយគិតគូរដល់ឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវគិតពិចារណាឲ្យបានសមស្របទៅលើអត្តប្រយោជន៍នៃការបន្តឲ្យមានការបីបាច់ថែរក្សា ដូចពេលកន្លងមក ព្រមទាំពិចារណាទៅលើសាវតា ជាតិពន្ធ សាសនា និងវប្បធម៌របស់កុមារ

[៥១] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស មាត្រា២៧ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

[៥២] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស មាត្រា២៨ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

[៥៣] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស មាត្រា២៩ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

ករណីរដ្ឋបាលសុំកូនអាចផ្គូរផ្គងកុមារនោះអោយអ្នកសុំផ្សេងទៀត ចំណែកឯប្រាក់ចំណាយសោហ៊ុយ និងវិភាគទានទាក់ទងនឹងការដាក់ពាក្យសុំមិនត្រូវបានបង្វិលអោយវិញឡើយ។

ដោយឡែក បើអ្នកសុំធ្វើការឆ្លើយតបថាមិនទទួលយកកុមារដែលបានផ្គូរផ្គងឱ្យខ្លួននោះទេ អ្នកសុំអាចស្នើសុំឱ្យរដ្ឋបាលស្មុំកូនអន្តរប្រទេសផ្គូផ្គងកុមារជាលើកទីពីរបាន។ តែការផ្គូផ្គងនេះមិនអនុញ្ញាតឱ្យមានធ្វើជាលើកទីបីឡើយ[៥៤]។

ផ្ទុយទៅវិញ បើអ្នកសុំបានឆ្លើយតបយល់ព្រមលើការសម្រេចរបស់រដ្ឋបាលស្មុំកូនអន្តរប្រទេសចំពោះការផ្គូផ្គងរវាងអ្នកសុំ និងកូនសុំនោះ។ រដ្ឋបាលស្មុំកូនអន្តរប្រទេសត្រូវរៀបចំឲ្យមានការជួបគ្នារវាងអ្នកសុំ និងកុមារ ដែលបានផ្គូផ្គងរួចហើយនោះ ក្នុងកាលបរិច្ឆេទមួយដែលសមស្របសម្រាប់អ្នកសុំ រួមទាំងរដ្ឋបាលស្មុំកូនអន្តរប្រទេស និងមន្ត្រីសង្គមកិច្ចមានសមត្ថកិច្ចមួយរូបផង ក្នុងរយៈពេល ៦០ថ្ងៃ (នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលការយល់ព្រមពីអ្នកសុំ)។ មុនមានការជួបគ្នារវាងអ្នកសុំ និងកូនសុំ រដ្ឋបាលស្មុំកូនអន្តរប្រទេសត្រូវធ្វើការសម្ភាសន៍អ្នកសុំ និងត្រូវធានាថា អ្នកសុំនិងកុមារបានរៀបចំខ្លួនជាស្រេចតាមរយៈការពិគ្រោះយោបល់ ការផ្លាស់ប្តូរព័ត៌មាន ការផ្លាស់ប្តូររូបថត និងវិធានការណ៍ផ្សេងៗទៀតដើម្បីការជួបគ្នានេះ [៥៥]។ នៅក្នុងកាលបរិច្ឆេទ នៃការជួបគ្នាលើកដំបូងនេះ បើមានសហព័ទ្ធណាម្ខាងអវត្តមាន ចាំបាច់ត្រូវមានលិខិតប្រគល់សិទ្ធិឱ្យសហព័ទ្ធម្ខាងទៀត ដែលមានការបញ្ជាក់ពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសទទួលធ្វើជាអ្នកតំណាងខ្លួនបាន។ ប្រសិនបើអ្នកសុំមិនបានជួបក្នុងរយៈពេលខាងលើដោយគ្មានមូលហេតុត្រឹមត្រូវ ចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន។ បន្ទាប់មករដ្ឋបាលស្មុំកូនអន្តរប្រទេស ត្រូវសាកសួរយោបល់របស់កុមារដែលអាចដឹងខុសត្រូវបាន ព្រមទាំងប្រាប់កុមារឲ្យដឹងអំពីអានុភាពដែលកើតចេញពីស្មុំកូនអន្តរប្រទេសនេះ[៥៦] ដោយត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីកាសម្ភាសន៍ និងការជួបគ្នាខាងលើនេះ។

រដ្ឋបាលស្មុំកូនអន្តរប្រទេស ធ្វើការពិនិត្យបើយល់ឃើញថា រវាងអ្នកសុំ និងកូនសុំបានបំពេញនូវលក្ខខណ្ឌវិនិច្ឆ័យ និងលក្ខខណ្ឌសម្រាប់ស្មុំកូនអន្តរប្រទេស ហើយឆ្លើយតបនឹងឧត្តមប្រយោជន៍របស់កុមារ ហើយត្រូវផ្តល់មតិយោបល់ជាវិជ្ជមានក្នុងរយៈពេល ៧ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការជួបគ្នា។ រួចដាក់សំណុំឯកសារជូនរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍លើដំណើរការស្មុំកូន[៥៧] ។ ក្រោយពីបានពិនិត្យ និងផ្តល់អនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចរួចមក អ្នកសុំត្រូវសហការជាមួយអាជ្ញាធរណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកស្មុំកូនអន្តរប្រទេស ឬទីភ្នាក់ងារ ស្មុំកូនអន្តរប្រទេសនៃប្រទេសទទួលដាក់ពាក្យសុំកូនដែលបាន

---

[៥៤] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស មាត្រា២៣៩ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

[៥៥] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស មាត្រា៣០ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

[៥៦] ត្រូវស្តាប់កុមារបញ្ចេញមតិយោបល់របស់ខ្លួនដោយគ្មានវត្តមានរបស់ភាគីផ្សេងទៀតឡើយ។ រដ្ឋបាលស្មុំកូនអន្តរប្រទេសត្រូវយល់ដឹងអោយបានច្បាស់អំពីទស្សនៈកុមារលើរាល់បញ្ហាដែលពាក់ព័ន្ធដល់ស្មុំកូន ក្នុងនោះជាអាទិ៍ ការជ្រើសរើសអ្នកសុំ ហើយមតិយោបល់របស់កុមារត្រូវយកទៅគិតគូរពិចារណា ដោយផ្អែកទៅតាមវ័យ និងកម្រិតយល់ដឹងរបស់កុមារ។

[៥៧] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស មាត្រា៣២ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

ផ្លូវផ្តងរួចតាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេសនៅសាលាដំបូងរាជធានីភ្នំពេញ។ រដ្ឋបាលសុំកូនអន្តរប្រទេសមានកាតព្វកិច្ចបញ្ជូនពាក្យសុំ រួមជាមួយសំណុំឯកសាររបស់អ្នកសុំ និងកូនសុំ ព្រមទាំងអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដោយមានបកប្រែជាភាសាខ្មែរ និងមានការបញ្ជាក់ពីរដ្ឋបាលសុំកូនអន្តរប្រទេសផង ដើម្បីសុំដីកាសម្រេចសុំកូនក្នុងរយៈពេល ៧ថ្ងៃ។ ផ្ទុយទៅវិញ បើអ្នកសុំមិនបានដាក់ពាក្យសុំក្នុងរយៈពេល ៦០ (ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលអនុសាសន៍របស់រដ្ឋមន្ត្រី ត្រូវបានចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំដោយខ្លួនឯង[៥៨]។

**ខ. នីតិវិធីតុលាការ**

ក្រៅពីកិច្ចនីតិវិធីផ្នែករដ្ឋបាលដែលបានអនុវត្តដោយអនុលោមបទបញ្ញតិនៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសរួចមក គឺត្រូវមានការវិលចូលក្នុងកិច្ចនីតិវិធីរបស់តុលាការ ដើម្បីទទួលបានដីកាសម្រេចសុំកូនអន្តរប្រទេស។ ដីកាសម្រេចប្រភេទនេះ គឺត្រូវស្ថិតក្នុងប្រភេទបណ្តឹងទាមទារឲ្យបង្កើត ផ្លាស់ប្តូរ និងរំលត់នៃសិទ្ធិ និងទំនាក់ទំនងគតិយុត្ត ដូចមានចែងក្នុងមាត្រា៣៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសបានចង្អុលបង្ហាញថា "តុលាការដែលមានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស ត្រូវយកបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងមកអនុវត្តចំពោះនីតិវិធីតុលាការទាក់ទងនឹងសុំកូនអន្តរប្រទេស។

**១. សមត្ថកិច្ចផ្តាច់មុខ៖** សាលាដំបូងរាជធានីភ្នំពេញ មានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស[៥៩]។ អ្នកសុំត្រូវបង់ប្រាក់សរុប ចំនួន ១.០០០.០០០(មួយលាន)រៀល ដើម្បីទ្រទ្រង់សោហ៊ុយដាក់ពាក្យបណ្តឹង ការពិនិត្យភស្តុតាង ការចេញដីកាសម្រេច ការបញ្ចូលឯកសារ ការផ្សព្វផ្សាយ ការជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និងសកម្មភាពនីតិវិធីផ្សេងៗទៀតដែលទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស។ តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែម និងបង្គាប់ឱ្យអ្នកសុំបង់សោហ៊ុយបន្ថែមជាមុនបានក្នុងករណីដែលសោហ៊ុយចាំបាច់មានចំនួនលើសពីការកំណត់ខាងលើ[៦០]។

**២. ការពិនិត្យភស្តុតាង៖** ជាគោលការណ៍ សំណុំឯកសារ និងរបាយការណ៍ដែលដាក់ជូនតុលាការដោយក្រសួងទទួលបន្ទុកវិស័យ សង្គមកិច្ច ត្រូវសន្មតថាជាភស្តុតាងនៃអង្គហេតុពិតទាក់ទងនឹងលក្ខណសម្បត្តិ សុំកូនរបស់កុមារ និងភាពសមស្របសម្រាប់សុំកូនរបស់អ្នកសុំ លើកលែងណាតែមានភស្តុតាងផ្ទុយមកបញ្ជាក់។[៦១] បើមានភាព

---

[៥៨] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស មាត្រា៣៣ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

[៥៩] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស មាត្រា៣៤ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវជូនដំណឹងអំពីការប្រព្រឹត្តទៅនៃនីតិវិធីសុំកូន វិធានការដែលអាជ្ញាធរមានសមត្ថកិច្ចចាត់ការ និងការវិវត្តនៃសុំកូននៅគ្រប់ដំណាក់កាលរបស់នីតិវិធីសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតតាមបទបញ្ញត្តិនៃមាត្រា៤៣។

[៦០] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស មាត្រា៣៥ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

[៦១] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស មាត្រា៣៦ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

ចាំបាច់ តុលាការអាចបង្គាប់ឲ្យអ្នកតំណាងរដ្ឋបាលសុំកូនអន្តរប្រទេសមកធ្វើការបំភ្លឺបន្ថែម អំពីលទ្ធផលនៃការស្រាវជ្រាវ និងអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកសង្គមកិច្ចទាក់ទងនឹងករណីសុំកូនអន្តរប្រទេសរួមទាំងឯកសាររបាយការណ៍ និងភស្តុតាងជាឯកសារពាក់ព័ន្ធដែលគាំទ្រលទ្ធផលនៃការស្រាវជ្រាវដែលដាក់ចូលទៅតុលាការ [៦២] ។

តុលាការត្រូវពិនិត្យផ្ទៀងផ្ទាត់ថាៈ

- លក្ខណវិនិច្ឆ័យ ឬលក្ខខណ្ឌទាំងអស់នៃសុំកូនអន្តរប្រទេសត្រូវបានបំពេញ។
- ការពិគ្រោះយោបល់ជាចាំបាច់នានាត្រូវបានធ្វើមុននឹងការផ្តល់យល់ព្រម។
- ការយល់ព្រមចាំបាច់នានាត្រូវបានផ្តល់ ដោយគោរពតាមខ្លឹមសារតាមផ្នែកទី២ ជំពូកទី៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស។
- មានការពិចារណាត្រឹមត្រូវលើគ្រប់លទ្ធភាពក្នុងការទុកដាក់កុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- អាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ច ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួល ការអនុញ្ញាតនៃប្រទេសទទួល យល់ព្រមលើការទុកដាក់កុមារ។
- កុមារនឹងត្រូវអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសទទួល។
- សុំកូនអន្តរប្រទេសពិតជាឧត្តមប្រយោជន៍របស់កុមារ។[៦៣]

**៣. ដីកាសម្រេចៈ** ការសម្រេចសេចក្តីលើការសុំកូនអន្តរប្រទេសរបស់តុលាការ មិនចាំបាច់ឆ្លងកាត់ការទាញហេតុផលផ្ទាល់មាត់ឡើយ[៦៤]។ ការចេញដីកាសម្រេចលើសំណុំរឿងសុំកូនអន្តរប្រទេស តុលាការត្រូវធ្វើការវិនិច្ឆ័យ និងចេញសេចក្តីសម្រេចក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ។ ដីកាសម្រេចមិនត្រូវបានចូលជាស្ថាពរនៅមុនផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ដែលបានកំណត់នៅក្នុងមាត្រា៤០ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស។ ក្នុងករណីមានការប្តឹងជំទាស់ចំពោះដីកាសម្រេចនេះ នឹងមិនត្រូវចូលជាស្ថាពរទេ[៦៥]។

បុគ្គលដែលមានសិទ្ធិ ឬផលប្រយោជន៍របស់ខ្លួនត្រូវបានបំពានដោយដីកាសម្រេចលើពាក្យសុំកូនអន្តរប្រទេស អាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ចំពោះដីកានោះបាន។ ក្នុងករណីដែលបុគ្គលអាចប្តឹងទាស់ជាជន ដែលបានទទួលការជូនដំណឹងអំពីដីកាសម្រេចខាងលើ ក្នុងអំឡុងពេល ១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃដែលត្រូវទទួលដំ

---

[៦២] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស មាត្រា៣៦ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

[៦៣] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស មាត្រា២៧ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

[៦៤] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស មាត្រា៣៨ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

[៦៥] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស មាត្រា៣៩ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

ណឹង។ ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់មិនមែនជាជនដែលត្រូវទទួលបានការជូនដំណឹង អំពីដីកាសម្រេចនោះ បណ្តឹងជំទាស់នោះត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ)ថ្ងៃដូចចិរវេលាខាងលើ គិតចាប់ពីថ្ងៃដែលអ្នកសុំទទួលដំណឹងពីដីកាសម្រេច [៦៦] ដោយមិនអាចពន្យាបានតទៅទៀតទេ។ សាលាឧទ្ធរណ៍ត្រូវធ្វើការវិនិច្ឆ័យ និងចេញដីកាសម្រេចក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីទទួលពាក្យបណ្តឹងហើយដីកាសម្រេចនេះបិទផ្លូវតវ៉ា។[៦៧]

**៤. សោហ៊ុយលើការសុំកូនៈ**

អ្នកសុំត្រូវបង់ប្រាក់ចំណាយសោហ៊ុយ និងវិភាគទាននានាជូនរដ្ឋបាលសុំកូនអន្តរប្រទេស សម្រាប់ជួយឧបត្ថម្ភជម្រើសនានានៃការថែទាំជំនួស ក្នុងការជួយឧបត្ថម្ភទៅដល់មណ្ឌល កុមារកំព្រារបស់រដ្ឋទូទាំងប្រទេស និងកម្រៃសេវាចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសដែលត្រូវបានកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អ្នកសុំកូនត្រូវបង់ចំនួន ៥.០០០ USD (ប្រាំពាន់ដុល្លាអាមេរិក) សម្រាប់ការសុំកុមារ ០១ នាក់ ដែលទុកជាថវិកាវិភាគទានមនុស្សធម៌។

លើកទី១៖ អ្នកសុំត្រូវបង់ប្រាក់ចំនួន ១.៥០០ USD (មួយពាន់ប្រាំរយដុល្លាអាមេរិក) នៅពេលដែលសំណុំឯកសារសុំកូន ត្រូវបានបញ្ជូនមកដល់រដ្ឋបាលសុំកូនអន្តរប្រទេសនៃអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។ ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញទេ។

លើកទី២៖ អ្នកសុំត្រូវបង់ប្រាក់ចំនួន ៣.៥០០ USD (បីពាន់ប្រាំរយដុល្លាអាមេរិក) មុនពេលធ្វើការប្រគល់កុមារជាផ្លូវការ[៦៨]។

ក្រៅពីនេះ មិនត្រូវយកប្រាក់សោហ៊ុយសុំកូនពីអ្នកសុំ ឬទីភ្នាក់ងាររបស់អ្នកសុំកូន។ មិនអនុញ្ញាតឲ្យអ្នកសុំកូន ឬទីភ្នាក់ងាររបស់អ្នកសុំកូន បង់ថ្លៃសោហ៊ុយសុំកូនទៅតាមកុមារម្នាក់ៗ ឬទៅតាមសោហ៊ុយសុំកូនមួយ ដែលនឹងត្រូវបញ្ជូនទៅឲ្យមណ្ឌលកុមារកំព្រាណាមួយ ឬមិនអនុញ្ញាតឲ្យអ្នកសុំកូន ឬទីភ្នាក់ងាររបស់អ្នកសុំកូន ធ្វើការផ្តល់សោហ៊ុយ អំណោយ ឬការទូទាត់ទោះបី ក្នុងរូបភាពណាក៏ដោយ ទៅឲ្យមណ្ឌលកុមារកំព្រា ដែលកុមារកំព្រានៅទីនោះត្រូវបានសុំយកទៅចិញ្ចឹម ឬទៅឲ្យមណ្ឌលកុមារកំព្រាដែលកុមារកំព្រានៅទីនោះ ត្រូវបានសុំយកទៅចិញ្ចឹម ឬទៅឲ្យបុគ្គលិកនាយក ឬសមាជិកនៃគណៈគ្រប់គ្រង ទោះបីជាដោយផ្ទាល់ ឬដោយប្រយោលក្តី។

[៦៦] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស មាត្រា៤០ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

[៦៧] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស មាត្រា៤០ នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩

[៦៨] ប្រកាសរួមលេខ ៤៤៨សហវ.ប្រក ស្តីពីការកំណត់ចំនួនប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាសម្រាប់សុំកូនអន្តរប្រទេស, ១០ មេសា ២០១៣, ប្រការ១ និងប្រការ២

**៥. កុមារក្រោយពេលទៅដល់ប្រទេសសុំ៖** ក្រោយពីដីកាសម្រេចរបស់តុលាការចូលជាស្ថាពរ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវជូនដំណឹងទៅក្រសួងការបរទេស និងសហប្រតិបត្តិការអំពីដីកាសម្រេចនេះ។ នៅពេលដែលនីតិវិធីសុំកូនអន្តរប្រទេស ត្រូវបានបញ្ចប់ដោយអនុលោមទៅតាមអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវចេញលិខិតបញ្ជាក់អនុលោមតាមមាត្រា២៣ នៃអនុសញ្ញានេះ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវរៀបចំពិធីប្រគល់កុមារ និងលិខិតបញ្ជាក់ស្តីពីការប្រគល់កូនជាផ្លូវការទៅអ្នកសុំ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវជួយសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការរៀបចំ និងការផ្តល់លិខិតឆ្លងដែន ទិដ្ឋាការ និងឯកសារចាំបាច់នានាដើម្បីឲ្យកុមារធ្វើដំណើរចូលទៅប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ។ ការធ្វើដំណើររបស់កុមារទៅកាន់ប្រទេសទទួលត្រូវអមដំណើរដោយរដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា ការបញ្ជូនកុមារទៅកាន់ប្រទេសទទួល ប្រព្រឹត្តទៅក្នុងកាលៈទេសៈមានសុវត្ថិភាពដោយមានការគិតគូដល់សេចក្តីត្រូវការនានារបស់កុមារ។ មួយផ្នែកទៀត រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវសម្របសម្រួលជាមួយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួលដើម្បីផ្តល់ ឬសម្របសម្រួលដល់កុមារគ្រួសារចិញ្ចឹម និងគ្រួសារបង្កើតតាមការចាំបាច់។ ក្រោយពីកុមារត្រូវបានទទួលអនុញ្ញាតឲ្យធ្វើជាកូន នោះឪពុកម្តាយចិញ្ចឹមត្រូវផ្តល់របាយការណ៍អំពីស្ថានភាពវិវត្តន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសជារៀងរាល់ ៦ (ប្រាំមួយ) ខែម្តងក្នុងរយៈពេល ៣ឆ្នាំ បន្ទាប់មកត្រូវផ្តល់ជារបាយការណ៍ ១ ឆ្នាំម្តងរហូតដល់កុមារមានអាយុ ១៨ឆ្នាំ។ ឪពុកម្តាយចិញ្ចឹមត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលសុំកូនអន្តរប្រទេសដោយផ្ទាល់ ឬតាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេស ឬប្រទេសជាលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួនទៅតាមស្ថានភាពសមស្រប។ រដ្ឋបាលសុំកូនអន្តរប្រទេស និងសាលាដំបូងរាជធានីភ្នំពេញត្រូវរក្សាទុកសំណុំឯកសារ សុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ឆ្នាំគិតពីកាលបរិច្ឆេទដែលដីកាសម្រេចសុំកូនអន្តរប្រទេសនោះ ចូលជាស្ថាពរ។ សំណុំឯកសារ និងកំណត់ហេតុទាំងអស់ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយទោះជារក្សាទុកនៅតុលាការក៏ដោយរដ្ឋបាលសុំកូនអន្តរប្រទេស ទីភ្នាក់ងារសុំកូនអន្តរប្រទេស មណ្ឌលកុមារកំព្រា និងអ្នកជំនាញផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងនីតិវិធីសុំកូនអន្តរប្រទេសត្រូវរក្សាជាការសម្ងាត់។ ក៏ប៉ុន្តែសំណុំឯកសារ និងកំណត់ហេតុ ឬព័ត៌មានទាំងឡាយដែលមាននៅក្នុងសំណុំឯកសារអាចនឹងត្រូវបានបញ្ចេញទៅ តាមការស្នើសុំការបង្គាប់ជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរមានសមត្ថកិច្ចនៅក្នុង ឬក្រៅព្រះរាជាណាចក្រ កម្ពុជាក្នុងករណីមានតម្រូវការទាក់ទងទៅនឹងករណី ឬនីតិវិធីតុលាការដែលកំពុងតែប្រព្រឹត្តទៅក្នុងកាលៈទេសៈ ពិសេសទៃទៀត។ ឪពុកម្តាយចិញ្ចឹមអាចដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំច្បាប់ចម្លងនៃសំណុំ លិខិតដែលរួមមាន អត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតរបស់កូនសុំក្រោយពីដីកាសម្រេចសុំកូនរបស់តុលាការ ចូលជាស្ថាពរនៅពេលដែលមានផលវិបាកនៃការដឹងអត្តសញ្ញាណកូនសុំដែលដល់អាយុដឹងខុសត្រូវគ្រប់គ្រាន់អាចត្រូវបាន

អនុញ្ញាតឲ្យមើលសំណុំលិខិតរបស់ខ្លួនរួមទាំងអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតបាន ដោយធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា។ កូនដែលឈានចូលអាយុនីតិភាពមានសិទ្ធិមើលសំណុំឯកសារ និងកំណត់ហេតុទាក់ទងរបស់ខ្លួនដោយមានការពិគ្រោះយោបល់សមស្របមុននឹងមើលព័ត៌មាននៅក្នុងសំណុំលិខិតរបស់ខ្លួន។

## ២.៣. ការសុំកូនក្រៅនីតិវិធី

ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ និងបានប្រកាសអោយប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ក្នុងនោះបានបញ្ជាក់យ៉ាងច្បាស់អំពីលក្ខខណ្ឌ និងនីតិវិធីនៃការសុំកូន។ ក៏ប៉ុន្តែដោយសារមធ្យោបាយនៃការផ្សព្វផ្សាយនូវប្រព័ន្ធច្បាប់ ក៏ដូចជាកម្រិតយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត ទើបតែងតែធ្វើអោយកើតមានមានឡើងនូវការអនុវត្តផ្ទុយ និងខុសពីនីតិវិធី។

បើចង់ដឹងថាការសុំកូនក្រៅនីតិវិធីច្បាប់ដែលកើតមានជាក់ស្តែងយ៉ាងណានោះសូមមើលករណីដែលកើតឡើងមួយចំនួនដូចខាងក្រោម៖

ករណីទី១៖ បទសម្ភាស៍ជាមួយគ្រួសារមួយស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ ដែលគាត់បានសុំកូនគេយកមកចិញ្ចឹមចំនួនពីរករណីកាលពីឆ្នាំ២០០៥ មួយករណី និងឆ្នាំ២០០១៥ មួយករណី[៦៩]។ ពេលដែលគាត់យកកូននោះមកចិញ្ចឹមទាំងពីរករណីនោះ គឺក្មេងមានអាយុ១៣ ឆ្នាំដូចគ្នា ។ ការសុំកូនគឺធ្វើឡើងតាមរយៈកិច្ចសន្យាផ្ទាល់មាត់ រវាងបុគ្គល និងបុគ្គល គ្មានការដឹងលឺពីអាជ្ញាធរមានសមត្ថកិច្ច និងគ្មានសំបុត្រស្នាមអ្វីទាំងអស់។ ក្រោយពីទទួលបានកូនយកមកចិញ្ចឹមហើយគ្រួសារថ្មីនោះចាត់ទុកកុមារដូចជាកូនបង្កើតអញ្ចឹង ដោយផ្តល់ការយកចិត្តទុកដាក់ និងការរៀនសូត្រ។ កន្លងផុតទៅរយៈពេលប្រាំឆ្នាំ កុមារនោះក៏បានលួចទៅរស់នៅជាមួយគ្រួសារដើមវិញ ហើយឪពុកម្តាយចិញ្ចឹមនោះបានទៅសុំកុមារមកវិញដែរ តែត្រូវទទួលបានការបដិសេធពីឪពុកម្តាយបង្កើតរបស់កុមារ គ្រួសារនោះគ្មានមធ្យោបាយនឹងយកកុមារត្រឡប់មកវិញបានទេ ព្រោះពួកគេគ្មានលិខិតស្នាមណាមួយបញ្ជាក់អំពីការសុំកូននេះ។

នេះបានបញ្ជាក់អោយឃើញផងដែរថា គ្រួសារនេះសុំកូនដោយមិនបានគោរពតាមនីតិវិធីក្រមរដ្ឋប្បវេណីមាត្រា១០០៧ ដែលតម្រូវឲ្យឪពុកម្តាយចិញ្ចឹមដាក់ពាក្យសុំទៅតុលាការ មាត្រា១០១០ តម្រូវឲ្យកូនសុំត្រូវមានអាយុតិចជាង៨ ឆ្នាំ និងមាត្រា១០១៤ ដែលតម្រូវអោយបញ្ចប់ញាតិភាពជាមួយឪពុកម្តាយបង្កើត និងលក្ខខណ្ឌតម្រូវជាច្រើនផ្សេងទៀតផងដែរដែលមិនបានបំពេញ។

ករណីជាច្រើន ដែលត្រូវបានឃ្លាំមើលដោយ អង្គការលីកាដូ កាលពីចុងទសវត្សរ៍ឆ្នាំ១៩៩០ និងដើមទសវត្សរ៍ឆ្នាំ២០០០ បានលាតត្រដាង ពីភ័ស្តុតាងនៃការ ទិញទារក និងការក្លែងបន្លំឯកសារ ដែលចាំបាច់ ដើម្បីអាច

[៦៩] ការផ្តល់បទសម្ភាស៍ដោយផ្ទាល់នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១

ធ្វើសកម្មភាពសុំកូនអន្តរប្រទេសបាន។ ករណីភាគច្រើនកើតឡើងចំពោះស្ត្រីក្រីក្រ ដែលភាគច្រើននៃស្ត្រីទាំង នោះជាស្ត្រីមេម៉ាយ ឬលែងលះស្វាមី និងរស់នៅយ៉ាងលំបាក ក្នុងការចិញ្ចឹមបីបាច់ទារក ឬកុមារតូចៗ។

ករណីទី២៖ កិច្ចសម្ភាស៍ជាមួយស្ត្រីមេម៉ាយម្នាក់ក្នុងឆ្នាំ២០០១ ដែលនាងមានកូនអាយុ៩ខែម្នាក់មានជំងឺត្រូវការការព្យាបាល នាងគ្មានលទ្ធភាពក៏បានយកកូនទៅផ្ញើរ មណ្ឌលកុមារកំព្រាអោយជួយមើលថែ។ រយៈពេលមួយកន្លងផុតទៅ នាងបានមករកកូនរបស់នាង តែត្រូវបានប្រធានមណ្ឌលប្រាប់ថា គេបានយកកូនរបស់នាងទៅព្យាបាលនៅអាមេរិច តែតាមពិតប្រធានមណ្ឌលបានបន្លំឯកសារ ដូរថ្ងៃខែឆ្នាំកំណើតរបស់ទារក ហើយបានផ្តល់ទារកអោយជនបរទេសតាមរយៈសុំកូនអន្តរប្រទេស ដោយបានសរសេរក្នុងឯកសារថា ទារកនេះត្រូវបានឪពុកម្តាយបោះបង់ចោល។

ករណីនេះបានប្រព្រឹត្តផ្ទុយនឹងច្បាប់សុំកូនអន្តរប្រទេស ដែលនៅក្នុងមាត្រា១៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសបានកំណត់ថា ដំណើរការសុំកូនអន្តរប្រទេសអាចប្រព្រឹត្តទៅបានលុះត្រាតែមានការយល់ព្រមពីឪពុកម្តាយ ឬឪពុក ឬ ម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អានីតិជន ។

# ជំពូក៣
# ការវិភាគទិន្នន័យ

## ៣.១ វិភាគលក្ខខណ្ឌច្បាប់ក្នុងករណីសុំកូន

### ៣.១.១. សុំកូនពេញលេញ

នៅក្នុងមាត្រា១០០៨ នៃក្រមរដ្ឋប្បវេណីបានកំណត់ថា បុគ្គលដែលនឹងក្លាយជាឪពុក ឬម្ដាយចិញ្ចឹមត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ។ តែបើយើងក្រលេកមកមើលការអនុវត្តជាក់ស្ដែងវិញ បុគ្គលខ្លះ នៅលីវ ខ្លះជាស្ត្រីមេម៉ាយ ឬបុរសពោះម៉ាយ គ្មានសហព័ទ្ធ បានសុំកូនគេយកមកចិញ្ចឹម ដែលវាបង្ហាញពីភាពផ្ទុយគ្នាជាមួយនិងក្រមរដ្ឋប្បវេណី ព្រោះគោលបំណងនៅក្នុងមាត្រា១០០៨ ដែលកំណត់ថា ឪពុកម្ដាយចិញ្ចឹមត្រូវតែជាបុគ្គលមានសហព័ទ្ធ គឺដើម្បីឲ្យបុគ្គលនោះអាចផ្ដល់ឲ្យកូនសុំនូវគ្រួសាថ្មីមួយ មានភាពកក់ក្ដៅ និងជាគ្រួសារដែលពេញលេញបរិបូរណ៍ អោយដូចជាគ្រួសារបង្កើតដែរ។ ផ្ទុយមកវិញបើអ្នកសុំកូនគ្មានសហព័ទ្ធ តើកូនចិញ្ចឹមនោះមានអ្វីដែលខុសប្លែកគ្នាពីក្មេងកំព្រាឪពុក ឬម្ដាយទៅ ? ហើយបើដូច្នេះ តើកូនចិញ្ចឹមនោះអាចទទួលបានភាពកក់ក្ដៅពេញលេញបរិបូរណ៍ពីគ្រួសារថ្មីនោះបានដោយរបៀបណា?

ដូចជាបទបញ្ញត្តិនៅក្នុនមាត្រា១០១១ បានចែងថា ដើម្បីបង្កើតសុំកូនពេញលេញបានត្រូវមានការយល់ព្រមពីឪពុកម្ដាយបង្កើត ឬអាណាព្យាបាលសម្រាប់អនីតិជន របស់កុមារដែលជាកូនសុំនោះ។ ជាការពិតណាស់ បើយើងចង់បានរបស់អ្វីមួយត្រូវទៅសុំម្ចាស់ជាមុនសិន ហើយមានការយល់ព្រមពីម្ចាស់ទើបយើងអាចយកបាន ដូចគ្នាជាមួយការសុំកូនដែរ លុះត្រាតែមានការយល់ព្រមពីឪពុកម្ដាយបង្កើត ឬអ្នកអាណាព្យាបាលជាមុនសិន បើពុំដូច្នេះទេគេនឹងចាត់ទុកថា ជាទង្វើនៃការលួចយកកូនទៅចិញ្ចឹម។ បើទោះបីជា នៅក្នុងមាត្រា១០១១ នេះចែងច្បាស់យ៉ាងណាក៏ដោយ ក៏យើងនៅតែមានការសង្កេតឃើញថា ក្នុងសង្គមបច្ចុប្បន្នមាននូវសកម្មភាពលួចលាក់កុមារយកទៅចិញ្ចឹម ដូចជាករណីកើតមាន ដែលបានរៀបរាប់នៅក្នុងជំពូក២ ចំណុច២.៣ ដោយការផ្ដល់ទារកដែលនៅក្នុងមណ្ឌលកុមារកំព្រា ឲ្យទៅជនបរទេសយកទៅចិញ្ចឹម ដោយមិនសុំការអនុញ្ញាតយល់ព្រមពីម្ដាយបង្កើតរបស់ទារកឡើយ។

### ៣.១.២ សុំកូនធម្មតា

ក្រមរដ្ឋប្បវេណី បានកំណត់នៅក្នុងមាត្រា១០២៦ ថា ទោះបីជាមានការបង្កើតសុំកូនធម្មតាក៏ដោយ ញាតិភាពរវាងកូនសុំ និងឪពុកម្ដាយបង្កើត ត្រូវបន្តអត្ថិភាព ហើយកូនសុំ និងឪពុកម្ដាយបង្កើត មានសិទ្ធិធ្វើសន្តិកម្មគ្នាទៅវិញទៅមក ។ ថ្វីត្បិតថាក្រមរដ្ឋប្បវេណីបានចែងបែបនេះក៏ពិតមែន តែយើងនៅតែសង្កេតឃើញថានៅក្នុងសង្គមមានការសុំកូនយកមកចិញ្ចឹមដោយលាក់បាំងកុមារ មិនអោយដឹងពីប្រវត្តិដើម សូម្បីតែឪពុកម្ដាយបង្កើតក៏ឪពុកម្ដាយចិញ្ចឹមលាក់បាំងមិនអោយកូនសុំស្គាល់ដែរ ដោយសារតែពេលឪពុកម្ដាយចិញ្ចឹមយកកូនមកចិញ្ចឹម គឺកូននោះនៅជាទារក ឬជាកុមារតូចដែលមិនទាន់អាចចងចាំឬអាចបង្ហាញឆន្ទៈបាននៅឡើយ។ តើកូនសុំអាចបន្តទំនាក់ទំនងញាតិជាមួយឪពុកម្ដាយបង្កើតបានដោយរបៀបណាទៅ?

ចំពោះមាត្រា១០២៣ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី បានកំហិតមកថា តុលាការមិនត្រូវអោយបង្កើតសុំកូនឡើយបើយល់ឃើញថា សុំកូនត្រូវបានបំពានក្នុងគោលបំណងអាពាហ៍ពាហ៍ រវាងភេទផ្សេងគ្នា ឬភេទដូចគ្នា ឬក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត។ បើច្បាប់បានចងយ៉ាងនេះទៅហើយ រឿងអីដែលថាជនខិលខូចមួយចំនួនដែលចង់បានកូនយកទៅចិញ្ចឹមដើម្បីទាញយកប្រយោជន៍ សុខចិត្តធ្វើតាមនីតិវិធីច្បាប់នោះ វាមិនអាចទៅរួចនោះទេ ទើបយើងឃើញថាមានករណីសុំកូនដើម្បីទាញយកប្រយោជន៍កើតមានច្រើន ដោយអ្នកសុំទាំងនោះសម្លឹងឃើញថាកូនចិញ្ចឹមនោះពេលធំឡើងអាចជួយធ្វើការ រកលុយបានច្រើន លក់កម្លាំងពលកម្មរបស់កុមារ ហើយទុកកូននោះ ឲ្យជួយបំរើពួកគេពេលចាស់ទៅ ឬអាចជាករណីយកកូនសុំមកបម្រើផ្លូវភេទរបស់គេ ឬក៏លក់កូននោះទៅអោយជនទីបីបន្តទៀតជាដើម។ ទាំងអស់នេះហើយគឺជាការសុំកូនក្នុងគោលបំណងមិនត្រឹមត្រូវ ដែលក្នុងមាត្រា១០២៣ បានហាមជាដាច់ខាត ចុះហេតុអ្វីនៅតែបន្តឃើញរឿងនេះកើតមានជាហូរហែទៀត? នេះបង្ហាញថាប្រជាជនមិនបានយល់ពីច្បាប់ ឬអាជ្ញាធរមិនសូវយកចិត្តទុកដាក់ ឬយ៉ាងណា?

## ៣.២ វិភាគនីតិវិធីនៅក្នុងការសុំកូន

នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានក្រមរដ្ឋប្បវេណី ដែលបានចែងយ៉ាងច្បាស់អំពីលក្ខខណ្ឌ និងនីតិវិធីនៃការសុំកូន ដោយនៅក្នុងមាត្រានីមួយៗ បានរៀបរាប់យ៉ាងលម្អិត និងច្បាស់លាស់។ តួយ៉ាងនៅក្នុងមាត្រា១០២០ ស្តីអំពីលក្ខខណ្ឌនៃការដាក់ពាក្យសុំកូនទៅតុលាការអោយបង្កើតសុំកូនធម្មតា ជាមួយគ្នាដែរក្រមរដ្ឋប្បវេណី មិនមានលក្ខខណ្ឌកំណត់ឲ្យបានច្បាស់ពីអាយុរបស់កូនសុំធម្មតានោះទេ បើទោះបីជាយ៉ាងនេះក៏ដោយ ក៏នៅក្នុងមាត្រា១០២៤ កថាខណ្ឌទី៣ បានចែងថា អនីតិជនដែលដល់អាយុ ១៥(ដប់ប្រាំ)ឆ្នាំ ដើម្បីបង្កើតសុំកូនត្រូវទទួលការយល់ព្រមពីអនីតិជននោះ។ ហើយនៅក្នុងមាត្រា១០២៦ ក៏បន្ថែមទៀតថា ទោះបីជាសុំកូនធម្មតាបានបង្កើតក៏ដោយ ក៏ញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើត មានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក ។ មានន័យថា កូនសុំគឺមានអាយុច្រើន អាចជានីតិជន ឬអនីតិជន ដែលដល់អាយុ១៥ (ដប់ប្រាំ)ឆ្នាំ អាចបង្ហាញឆន្ទៈ និងមានសិទ្ធិស្គាល់ពីកំណើតខ្លួន ដូច្នេះគេមិនបានផ្តាច់ចំណងទំនាក់ទំនងញាតិជាមួយឪពុកម្តាយបង្កើតទេ។

បើយើងបកមកមើលសង្គមជាក់ស្តែងវិញ មានបុគ្គលមួយចំនួនបានសុំកូនគេយកមកចិញ្ចឹមដោយបានបំពេញលក្ខខណ្ឌកំណត់ដូចជា បុគ្គលនោះមានសហព័ទ្ធ មានការសហការយល់ព្រមពីសហព័ទ្ធ ពីឪពុកម្តាយ ឬឪពុក ឬ ម្តាយ ឬអាណាព្យាបាលរបស់កុមារ និងបានបំពេញនូវលក្ខខណ្ឌអាយុផ្សេងៗ ជាពិសេសដូចបានចែងនៅក្នុងមាត្រា១០២៤ និង១០២៦បានចែងជាដើម។ ក៏ប៉ុន្តែអ្វីដែលជាបញ្ហាចោទនោះគឺ បុគ្គលនោះមិនបានអនុវត្តតាមនីតិវិធីរបស់តុលាកា ដោយពួកគេមិនបានដាក់ពាក្យសុំទៅតុលាការ[៣០] និងមិនបានជម្រាបទៅអាជ្ញាធរមានសមត្ថកិច្ចអោយបានជ្រាបឡើយ។ វាជារឿងដែលគួរឲ្យសោកស្តាយខ្លាំងណាស់ ដូចជានៅក្នុងករណីសិក្សាជំពូក២ ចំណុច

[៣០] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មាត្រា១០២០

២.៣ បានបង្ហាញអោយឃើញពីគ្រួសារដែលបានសុំកូនគេយកមកចិញ្ចឹមក្រៅនីតិវិធី ដោយកុមារនោះជាអនីតិជន មានអាយុ១៥ (ដប់ប្រាំ)ឆ្នាំ តែនៅពេលកុមារធំពេញរូបរាង កុមារនោះក៏ត្រឡប់ទៅរកគ្រួសារដើមរបស់គេវិញ។ នេះសរបញ្ជាក់អោយឃើញថា ការសុំកូនក្រៅនីតិវិធីគឺប្រឈមនិងបញ្ហានូវការបាត់បង់កុមារខ្លាំងណាស់ ជាពិសេសដូចជាករណីកូនសុំជានីតិជន ឬអនីតិជន ព្រោះពួកគេមានសមត្ថភាពដឹងលឺ ស្គាល់គ្រួសារសាច់ញាតិដើមរបស់គេ និងពួកគេអាចបង្ហាញឆន្ទៈបាន ហើយអាចនឹងត្រឡប់ទៅរកសាច់ញាតិបង្កើតរបស់គេវិញ ។

សិទ្ធិដឹងអំពីកំណើតខ្លួនរបស់កូនសុំពេញលេញ ដែលមានចែងក្នុងមាត្រា១០១៩ កាលណាកូនសុំដល់នីតិភាពអាចស្នើសុំទៅតុលាការដែលរក្សាទុកសំណុំរឿងស្តីពីការសុំកូន អំពីព័ត៌មានរបស់ខ្លួនបាន។ ក៏ប៉ុន្តែជាក់ស្តែងមានករណីជាច្រើនកើតឡើង នៃការសុំកូនដោយក្លែងបន្លំឯកសារ សំបុត្រកំណើត ឈ្មោះ និងថ្ងៃខែឆ្នាំកំណើតជាដើម ហើយបញ្ជូនកុមារនោះទៅរស់នៅឯបរទេស តាមរយៈការសុំកូនអន្តរប្រទេស តែនៅពេលដែលកុមារដល់នីតិភាព តើកុមារនឹងអាចដឹងពីកំណើតរបស់ខ្លួនដោយរបៀបណា បើឯកសារទាំងនោះត្រូវបានកែប្រែទាំងស្រុងទៅហើយ។

## ៣.៣ ចំណុចខ្លាំង និងចំណុចខ្សោយ

### ក. ចំណុចខ្លាំង

ការសុំកូនសុទ្ធតែកើតចេញពី ឆន្ទៈរបស់ឪពុកម្តាយចិញ្ចឹម ដែលចង់បានកូនយកមកចិញ្ចឹម ថ្នាក់ថ្នមថែរក្សា និងអាចផ្តល់ឲ្យពួកគេនូវគ្រួសារដ៏កក់ក្តៅមួយ ហើយអ្វីដែលសំខាន់មួយទៀតនោះគឺ ចង់បានកូនមកចិញ្ចឹមដែលអាចភ្ជាប់ទំនាក់ទំនងញាតិឲ្យដូចគ្នាទៅនឹងកូនបង្កើតដែរ ដោយអនាគតកូនៗទាំងនោះអាច ទទួលបានសន្តតិកម្ម អាចបន្តពូជពង្សវង្សត្រកូល និងមើលថៃពួកគេនៅពេលចាស់ទៅតាមរបៀបនៃការកត្តញ្ញូដែលជាកាតព្វកិច្ចរបស់កូនៗគ្រប់រូប។ ជាការពិតណាស់ មានតែការសុំកូនដែលឆ្លងកាត់តាមនីតិវិធីច្បាប់តែប៉ុណ្ណោះ ដែលអាចធានាបានថា កូនសុំត្រូវបានចង និងទទួលបានការការពារដោយច្បាប់ ដែលឪពុកម្តាយចិញ្ចឹមនៅតែអាចរក្សាកូនចិញ្ចឹមជាកូនរបស់ខ្លួនជារៀងរហូត លើសពីនេះទៅទៀតច្បាប់បានរឹតចំណងញាតិរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំឲ្យកាន់តែមានភាពស្អិតរមួតថែមទៀតផង។

បើមើលទៅលើកូនសុំ ដែលបានឆ្លងកាត់នីតិវិធីវិញ ពួកគេហាក់បីដូចជាមានសុវត្ថិភាពទាំងផ្លូវកាយ និងផ្លូវចិត្ត ដូចជាទទួលបានជីវិតថ្មីអញ្ចឹង ។ ពួកគេត្រូវបានរស់នៅក្រោមការការពារឃ្លាំមើលនៃច្បាប់ អាចរកឃើញអនាគតថ្មីមួយដ៏ភ្លឺស្វាង ដោយរស់នៅជាមួយនឹងជីវភាពល្អប្រសើ និងសុខុមាលភាព។

ជារឿងដែលល្អខ្លាំងណាស់ សម្រាប់ឪពុកម្តាយគ្រប់រូប នៅពេលដែលឃើញកូនរបស់ខ្លួនត្រូវបានទៅរស់នៅកន្លែងល្អ មានសុវត្ថិភាព ទទួលបានការស្រលាញ់មើលថែ ពីសំណាក់គ្រួសារថ្មី និងឃើញការយកចិត្តទុកដាក់ពីអាជ្ញាធរមានសមត្ថកិច្ច ក៏ដូចជារាជរដ្ឋាភិបាលទាក់ទងនឹងរឿងនេះ។

**ខ. ចំណុចខ្សោយ**

ទោះបីជាគ្រប់យ៉ាងមើលទៅហាក់បីជារលូនយ៉ាងណាក៏ដោយ ក៏វាចៀសមិនផុតទេពីចន្លោះខ្វះខាតមួយចំនួន ។ ថ្វីត្បិតថា នីតិវិធីនៃការសុំកូនអាចទទួលបានការការពារច្រើនក៏ពិតមែន តែវានៅតែមានចំណុចប្រហោងដោយសារការមិនសូវយកចិត្តទុកដាក់ របស់ភ្នាក់ងារមានសមត្ថកិច្ច ក្នុងការដាស់តឿន ពន្យល់ណែនាំដល់ប្រជាពលរដ្ឋអោយយល់ដឹងកាន់តែច្បាស់ តែកាលណាប្រជាពលរដ្ឋគ្មានចំណេះដឹង គាត់សុំកូន ឬផ្តល់កូនសុំដោយអ្នកដទៃដោយខុសនីតិវិធី ហើយវានឹងបង្ករជាហានិភ័យជាខ្លាំងចំពោះកុមារទៅថ្ងៃអនាគត។ ការព្រងើយកន្តើយរបស់ភ្នាក់ងារមានសមត្ថកិច្ច នៅពេលមានការសុំកូនខុសច្បាប់ ដោយគ្មានច្បាប់ចែងអោយច្បាស់ពីការដាក់ទោសជនល្មើសដោយមធ្យោបាយសាកសមណាមួយនៅឡើយទេ។

នីតិវិធីនៃការសុំកូន មានភាពសុាំញ៉ាំ និងស្មុគស្មាញ ដែលពិបាកដល់ប្រជាពលរដ្ឋគ្មានចំណេះដឹងពិបាកនឹងការស្វែងយល់ ពិបាកនឹងការភ្ជាប់ទំនាក់ទំនងញាតិជាមួយឪពុកម្តាយចិញ្ចឹម និងកូនសុំ។ លក្ខខណ្ឌច្បាប់ច្រើន ងាយនឹងធ្វើឲ្យមានការយល់ច្រឡំ ដែលបង្ករជាការអនុវត្តខុសច្បាប់ ។

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក ការសិក្សាស្រាវជ្រាវចំពោះប្រធានបទ "**នីតិវិធីនៃការសុំកូននៅកម្ពុជា**" ខាងលើ គឺពិតជាមានអត្ថប្រយោជន៍ណាស់ ព្រោះការសិក្សានេះបានផ្តល់នូវពុទ្ធិផ្នែកច្បាប់ ក៏ដូចជារំលេចឲ្យឃើញពីបញ្ហាតូចធំជាច្រើន។ គោលគំនិតសំខាន់គឺ យុត្តិសាស្ត្រក្នុងការស្វែងរកគ្រួសារមួយដែលមានលក្ខណៈសម្បត្តិពេញលេញដែលអាចផ្តល់ការមើលថែ ការស្រលាញ់ថ្នាក់ថ្នម អប់រំទូន្មាន ប្រៀនប្រដៅ និងផ្តល់នូវភាពកក់ក្តៅដល់កូនចិញ្ចឹម ក្នុងនាមអ្នកជាឪពុកម្តាយ ឬអាណាព្យាបាល។

បើក្រលេកមើលបច្ចុប្បន្នភាព ដោយឃើញថាមានការយកចិត្តទុកដាក់ទៅលើកុមារពីសំណាក់ប្រជាជនខ្មែរជាពិសេសគឺ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នកាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ ក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ និងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ។ ជាមួយគ្នានេះដែរ ដោយយល់ឃើញថា កុមារ គឺពិតជាមានសារៈសំខាន់ ជាទំពាំងស្នងឫស្សី ពាក់ព័ន្ធនឹងសុំកូននេះ រដ្ឋបានចងក្រងច្បាប់ស្តីពី សុំកូនធម្មតា សុំកូនពេញលេញ (ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧) និង ច្បាប់ស្តីពីសុំកូនអន្តរប្រទេស (២០០៩) ដែលចែងពីសិទ្ធិរបស់កូនសុំ ពោលគឺបញ្ញត្តិអំពីលទ្ធភាពរបស់អ្នកសុំ ដើម្បីថែរក្សាកូនសុំនេះឲ្យបានត្រឹមត្រូវ ។

តាមការស្រាវជ្រាវនេះ ធ្វើឲ្យយើងបានយល់ដឹងពីការបង្កើតបុត្តភាពមួយតាមរយៈសុំកូនដើម្បីឲ្យមានទំនាក់ទំនងញាតិរវាងកូនសុំនិងឪពុកម្តាយចិញ្ចឹម ដូចជាញាតិនៃឪពុកម្តាយបង្កើតដែរ។ នៅក្នុងនេះយើងបានដឹងអំពីប្រភេទនៃសុំកូន ដែលបានកំណត់អំពីលក្ខខណ្ឌនៃការសុំដែលមានទាក់ទងនឹង លក្ខខណ្ឌអាយុរបស់ឪពុកម្តាយ លក្ខខណ្ឌអាយុរបស់កូន និងការយល់ព្រមរបស់ឪពុកម្តាយបង្កើត។ មួយទៀតគឺបានដឹងអំពីករណីណា ឬស្ថានភាពណា ដែលអាចសុំកូនបានពីឪពុកម្តាយបង្កើត ដូចជាឪពុកម្តាយពិបាកយ៉ាងខ្លាំង ក្នុងការចិញ្ចឹមកូនដោយសារភាពក្រីក្រ និងមូលហេតុផ្សេងៗទៀតដែលចាំបាច់ហើយដើម្បីផលប្រយោជន៍កុមារ ទើបនាំឲ្យមានការសុំកុនបាន ។ នៅក្នុងនេះដែរ ក៏បានដឹងអំពីការវិនិច្ឆ័យរបស់តុលាការទាក់ទងនឹងសុំកូននេះ ថាតើមូលហេតុ ឬស្ថានភាពបែបណា ដែលអាចឲ្យឪពុកម្តាយចិញ្ចឹមសុំកូនមកចិញ្ចឹមបាន ។ កាលណាដែលសុំកូនបានហើយ គឺយើងក៏បានដឹងពីអានុភាពនៃសុំកូន ហើយក៏បានដឹងអំពីមូលហេតុដែលបង្កឲ្យមានការកាត់កាល់កូនសុំផងដែរ ។

ប្រធានបទខាងលើពិតជាមានសារៈសំខាន់ខ្លាំងណាស់ដែលបានបង្ហាញអោយយើងឃើញអំពីនីតិវិធីនៃការសុំកូនពីមួយដំណាក់កាលទៅមួយដំណាក់កាល និងការគោរពទៅតាមលក្ខន្តិកផ្សេងៗយ៉ាងល្អិតល្អន់ និងស៊ីជម្រៅថែមមួយកម្រិតទៀត។ មិនត្រឹមតែប៉ុណ្ណោះថែមទាំងកំណត់អំពីទោសបញ្ញត្តិប្រសិនបើបុគ្គលណាហ៊ានប្រព្រឹត្តិខុសពីច្បាប់កំណត់ និងត្រូវផ្តន្ទាទោសថែមទៀតផង។ និងរួមចំណែកជាច្រើនសម្រាប់សាធារណៈជនអោយបានយល់កាន់តែច្បាស់ និងដើម្បីចៀសវាងការបោកបន្លំពីសំណាក់ជនឆបោក ។

ជាចុងបញ្ចប់ ក្នុងនាមយើងទាំងអស់គ្នាជាប្រជាពលរដ្ឋខ្មែរគ្រប់រូប ត្រូវខិតខំប្រឹងប្រែងរៀនសូត្រ ស្វែងយល់អំពីច្បាប់ជាតិ អន្តរជាតិអោយកាន់តែទូលំទូលាយ ត្រូវចេះគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិកុមារ ។ ត្រូវចូលរួមបញ្ចៀស និងលុបបំបាត់ជាដាច់ខាតនូវអំពើរជួញដូរកុមារ តាមគ្រប់រូបភាពនិងគ្រប់មធ្យោបាយ ដោយបុគ្គលដែលពាក់ព័ន្ធនឹងបញ្ហាសុំកូនទាំងអស់ត្រូវយកចិត្តទុកដាក់អនុវត្តនីតិវិធីនីមួយៗឲ្យបានល្អ ម៉ត់ចត់ ជាពិសេសការត្រួតពិនិត្យសំណុំឯកសារអ្នកសុំឲ្យបានល្អិតល្អន់ គ្រប់ជ្រុងជ្រោយ មុននឹងឈានទៅរកការសម្រេចចិត្តមួយដែលល្អត្រឹមត្រូវ និងយុត្តិធម៌។ ដូច្នេះការដែលបានយល់ដឹងអំពីបញ្ហាទាំងអស់នេះបាន គឺដោយមានការបង្រៀនពីលោកគ្រូ អ្នកគ្រូ គួបផ្សំនឹងកិច្ចការស្រាវជ្រាវនេះទើបមានការយល់ដឹងកាន់តែច្បាស់ ហេតុនេះសង្ឃឹមថាបងប្អូននិស្សិតនិងអ្នកសិក្សាទាំងឡាយយកចិត្តទុកដាក់ក្នុងកិច្ចការស្រាវជ្រាវរបស់ខ្លួនទោះជាមុខវិជ្ជាណាក៏ដោយ ទើបធ្វើឲ្យយើងមាននូវចំណេះដ៏ពិតប្រាកដបាន នោះជាអ្វីដែលល្អពិត៕

# អនុសាសន៍

ក្រោយពីបានធ្វើការបំភ្លឺ បកស្រាយវែកញែក និងការសន្និដ្ឋានរួចមក ក្នុងនាមយើងខ្ញុំជានិស្សិត ជាទំពាំងស្នងឫស្សី ក៏ជាធនធានមនុស្សសម្រាប់ប្រទេសជាតិ យើងខ្ញុំក៏សូមផ្តល់នូវអនុសាស៍ ដែលជាគោលគំនិតតូចមួយក្នុងការចូលរួមដើម្បីការពារទៅដល់ការសុំកូន និងការពារកុំអោយមានការរំលោភបំពានលើកុមារដូចខាងក្រោមៈ

- ឪពុកម្តាយ ឬអាណាព្យាបាលកូន គួរយល់ថាកូនម្នាក់ដែលខ្លួនបង្កើតចេញពីសាច់ ធ្លាប់ចិញ្ចឹមបីបាច់ បើទោះបីខ្លួនគ្មានលទ្ធភាពចិញ្ចឹម ហើយចង់ផ្តល់កូនឲ្យទៅនរណាម្នាក់គឺតែងចង់ឲ្យកូនបាននៅជាមួយមនុស្សល្អ ដូច្នេះហើយគួរតែផ្តល់កូនតាមផ្លូវច្បាប់ ទើបមានច្បាប់ជួយការពារបាននៅពេលមានការឆបោក ឬធ្វើបាបទៅលើកុមារ។
- គួយកចិត្តទុកដាក់ លើក្របខណ្ឌគតិយុត្តដែលនៅមានចន្លោះខ្វះខាត ជាអាទិ៍ ពុំទាន់មានបញ្ញត្តិស្តីពីការកាត់កាល់នៃសុំកូនអន្តរប្រទេស ឬការទទួលយកកុមារត្រឡប់មកវិញសោះឡើយ ក្នុងករណីណាមួយ មានបទល្មើសកើតឡើងចំពោះកុមារដែលបានសុំយកទៅចិញ្ចឹមនៅប្រទេសអចិន្ត្រៃយ៍។
- អាជ្ញាធរមានសមត្ថកិច្ច គួរតែចុះផ្សព្វផ្សាយអំពីរច្បាប់ ការការពារ ដល់ប្រជាពលរដ្ឋតាមតំបន់អោយបានទូលាយ និងដាក់ទោសជាកំហិតចំពោះជនល្មើសកុំឲ្យរួចខ្លួន។
- រាជរដ្ឋាភិបាលកម្ពុជា គួតែនឹងចេញនូវលិខិតទទួលស្គាល់ជាសាធារណៈ ចំពោះកំហុសឆ្គងដែលអាជ្ញាធររដ្ឋបាលបានប្រព្រឹត្តពីអតីតកាល ការទទួលស្គាល់កំហុសចំពោះជនរងគ្រោះទាំងអស់ និងការអញ្ជើញក្រុមគ្រួសារដែលប៉ះពាល់ ឲ្យមកប្រាប់ពីរឿងរ៉ាវរបស់អ្នកទាំងនោះ និងស្វែងរកសំណងការខូចខាត។
- រាជរដ្ឋាភិបាលកម្ពុជា ដោយមានការគាំទ្រពីរាជរដ្ឋាភិបាលនៃប្រទេសដែលទទួលកុមារ គួរតែបង្កើតគណៈកម្មាធិការស៊ើបអង្កេតពិសេសមួយ ដើម្បីជួយដល់ក្រុមគ្រួសារកម្ពុជា ដែលរងគ្រោះដោយសកម្មភាពសុំកូនក្លែងបន្លំ ក្នុងការស្វែងរកទីតាំងរស់នៅ របស់កូនៗទាំងនោះ និងជួយភ្ជាប់ទំនាក់ទំនងឡើងវិញរវាងឪពុកម្តាយ និងកូន។

យោងតាមគំនិតស្តួចស្តើងខាងលើ យើងខ្ញុំទាំងពីរនាក់សង្ឃឹមថាអាចជាចំណែកតូចមួយក្នុងការជួយដល់សិស្សនិស្សិតដែលសិក្សាស្វែងយល់ អោយកាន់តែមានការយល់ច្បាស់និងកាន់ស៊ីជម្រៅថែមមួយកម្រិតទៀត ក៏ដូចជាជួយដល់ប្រជាជនឲ្យកាន់តែមានការយល់ដឹង និងប្រុងប្រយ័ត្នលើការផ្តល់ ឬការសុំកូន។

# ឯកសារយោង


១. វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត

២. ច្បាប់រដ្ឋធម្មនុញ្ញ

៣. ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

៤. ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

៥. ច្បាប់ស្តីពី "នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង" ឆ្នាំ២០១០

៦. ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ

៧. នីតិបេតិកភណ្ឌ និងគ្រួសារ

៨. ច្បាប់ស្តីពី "សុំកូនអន្តរប្រទេស" ឆ្នាំ២០០៩

៩. អនុសញ្ញាក្រុងឡាអេស្តីពី ការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសត្រូវបានផ្តល់សច្ចាប័នយល់ព្រមដោយព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧

១០. អនុសញ្ញាស្តីពី "សិទ្ធិកុមារ" និងពិធីសារបន្ថែម( ២០០៩)

១១. អនុសញ្ញាស្តីពី "សិទ្ធិកុមារ" ឆ្នាំ១៩៨៩

១២. អង្គការសិទ្ធិមនុស្សលីកាដូ(LICADHO)

១៣. អង្គការសិទ្ធិកុមារអន្តរជាតិយូនីសេហ្វ Unicef

១៤. អង្គការការពារសិទ្ធិមនុស្សកម្ពុជា(CCHR)

១៥. សិក្ខាសាលាស្តីពីបុគ្គភាព និងអំណាចមេបា មេធាវី ទេព បូផល( ២០១៥)

១៦. កញ្ញា រិន បូរី, សារណាបញ្ចប់ឆ្នាំសិក្សា ស្តីពី សុំកូននៅកម្ពុជា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ២០១៧

១៧. ហ៊ុយ សុខលីន, សារណាបញ្ចប់ឆ្នាំសិក្សា ស្តីពី សុំកូនអន្តរប្រទេស, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ២០២០

file:///C:/Users/Admin/AppData/Local/Temp/226kLICADHOAdoptionReport30March2018_Kh.pdf

https://batheouse.ru/km/narushenie-nacionalnymi-sudami-nailuchshih-interesov.html

file:///C:/Users/Admin/AppData/Local/Temp/CountryProgramme_CHILD%20PROTECTION_25x25_090219_KH_0.pdf%20-1.pdf

# ឧបសម្ព័ន្ធ១

ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ក្រមរដ្ឋប្បវេណី

# ផ្នែកទី ២

# សុំកូន

## កថាភាគទី ១

## សុំកូនពេញលេញ

**មាត្រា ១០០៧.–** ទម្រង់នៃការបង្កើតសុំកូនពេញលេញ

បើយល់ឃើញថា មានល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិចាប់ពីមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្ដីប្រពន្ធ) ដល់មាត្រា ១០១២ (មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ) ខាងក្រោមនេះ តុលាការអាចបង្កើតសុំកូនពេញលេញ ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្ដាយបង្កើត តាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមបាន ។

**មាត្រា ១០០៨.–** សុំកូនដោយសហការរវាងប្ដីប្រពន្ធ

១-បុគ្គលដែលក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ ។

២-ប្ដី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀត មិនក្លាយជាម្ដាយ ឬ ឪពុកចិញ្ចឹម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្ដីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹម របស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

**មាត្រា ១០០៩.–** អាយុរបស់ឪពុកម្ដាយចិញ្ចឹម

ឪពុកម្ដាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ)ឆ្នាំ ឡើងទៅ ហើយត្រូវមាន

អាយុច្រើនជាងកូនសុំយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ១០១០.–** អាយុរបស់កូនសុំ

ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំ ។

**មាត្រា ១០១១.–** ការយល់ព្រមរបស់ឪពុកម្ដាយ

ដើម្បីបង្កើតសុំកូនពេញលេញ ត្រូវមានការយល់ព្រមពីឪពុកម្ដាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កុមារដែលនឹងក្លាយជាកូនសុំនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលឪពុកម្ដាយនោះ មិនអាចបង្ហាញឆន្ទៈបាន ឬ ករណីដែលមានការធ្វើបាបដោយឪពុកម្ដាយ ការបោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀត ដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំនោះ យ៉ាងធ្ងន់ធ្ងរ ។

**មាត្រា ១០១២.–** មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ

សុំកូនពេញលេញ ត្រូវបានបង្កើតឡើង នៅក្នុងករណីដែលមានការពិបាកយ៉ាងខ្លាំង ឬ មិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុកម្ដាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងៗទៀត ហើយយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូននោះ ។

**មាត្រា ១០១៣.–** អំឡុងពេលសាកល្បងចិញ្ចឹម

ដើម្បីបង្កើតសុំកូនពេញលេញ តុលាការត្រូវពិចារណាលើស្ថានភាពដែលបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម បានធ្វើ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ជាគោលការណ៍ យ៉ាងតិច ៦ (ប្រាំមួយ) ខែ ។

**មាត្រា ១០១៤.–** ការបញ្ចប់ទំនាក់ញាតិភាពជាមួយនឹងឪពុកម្ដាយបង្កើត

ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះ ត្រូវបញ្ចប់ ដោយសុំកូនពេញលេញ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមក

អនុវត្តឡើយ ចំពោះញាតិភាពជាមួយនឹងឪពុកម្ដាយម្ខាងទៀត និង ញាតិលោហិតរបស់ឪពុកម្ដាយម្ខាងទៀតនោះ ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ២ នៃមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្ដីប្រពន្ធ) នៃក្រមនេះ ។

**មាត្រា ១០១៥.-** អានុភាពនៃសុំកូនពេញលេញ

១-ដោយបង្កើតសុំកូនពេញលេញ កូនសុំត្រូវទទួលបានឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម និង ត្រូវទទួលបាននូវសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្ដាយចិញ្ចឹម ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-កូនសុំ ត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលប្ដីប្រពន្ធណាម្ខាង ក្លាយជាឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម របស់កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬ ម្ដាយបង្កើត និង ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ។

**មាត្រា ១០១៦.-** ការកាត់កាល់នៃសុំកូនពេញលេញ

១-បើយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូនសុំ តុលាការអាចកាត់កាល់ភាពនៃសុំកូនបាន តាមពាក្យសុំរបស់កូនសុំ ឪពុកម្ដាយបង្កើត ឬ តំណាងអយ្យការ លុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុចទាំងអស់ ដែលកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-បើមានការធ្វើបាបដោយឪពុកម្ដាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ ។

ខ-បើឪពុកម្ដាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ ។

២-ការកាត់កាល់ ពុំអាចធ្វើបានឡើយ ក្រៅពីយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០១៧.-** អានុភាពនៃការកាត់កាល់សុំកូនពេញលេញ

ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះ ដែលត្រូវបានបញ្ចប់ ដោយសុំកូនពេញលេញ ត្រូវកើតឡើងវិញ គិតចាប់ពីថ្ងៃកាត់កាល់ ។

**មាត្រា ១០១៨.-** ការចុះបញ្ជី និង ការរក្សាការសម្ងាត់នៃសុំកូនពេញលេញ

ប្រសិនបើបានបង្កើតសុំកូនពេញលេញ បញ្ជីកំណើតរបស់កូនសុំ ត្រូវធ្វើជាថ្មី ។ ប៉ុន្តែ នៅក្នុងសំបុត្រកំណើត ឬ សេចក្ដីចម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃបញ្ជីកំណើត មិនត្រូវសរសេរចំណុចស្ដីពីសុំកូនឡើយ ។

**មាត្រា ១០១៩.-** សិទ្ធិដឹងអំពីកំណើតខ្លួនរបស់កូនសុំពេញលេញ

កូនសុំពេញលេញ ដែលបានក្លាយជានីតិជន អាចទាមទារឱ្យបង្ហាញនូវព័ត៌មានក្នុងទំហំដែលចាំបាច់ ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងស្ដីពីសុំកូនបាន ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានគោលបំណងមិនត្រឹមត្រូវ ។ ចំពោះការរក្សាទុកសំណុំរឿង និង វិធីទាមទារឱ្យបង្ហាញ ជាអាទិ៍ ត្រូវកំណត់នៅក្នុងបទ-ប្បញ្ញត្តិរបស់តុលាការ ។

## កថាភាគទី ២

## សុំកូនធម្មតា

**មាត្រា ១០២០.-** ពាក្យសុំនៃសុំកូនធម្មតា

១-បុគ្គលដែលមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ អាចដាក់ពាក្យសុំជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនសុំ ទៅតុលាការ ឱ្យបង្កើតសុំកូនធម្មតាបាន ។ ប៉ុន្តែ បុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ឬ បុគ្គលដែលមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមឡើយ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន អ្នកមានអំណាច

មេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ ។

**មាត្រា ១០២១.–** ករណីដែលបុគ្គលដែលនឹងក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹមមានសហព័ទ្ធ

បើបុគ្គលដែលមានសហព័ទ្ធ សុំកូនដែលជាអនីតិជន បុគ្គលនោះត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ១០២០ (ពាក្យសុំនៃសុំកូនធម្មតា) ខាងលើនេះ ជាមួយនឹងសហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលយកកូនរបស់សហព័ទ្ធ មកធ្វើជាកូនសុំ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ។

**មាត្រា ១០២២.–** ការយល់ព្រមរបស់សហព័ទ្ធ

ចំពោះបុគ្គលដែលមានសហព័ទ្ធ ដើម្បីដាក់ពាក្យសុំនៃសុំកូនធម្មតា ត្រូវទទួលការយល់ព្រមពីសហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ១០២០ (ពាក្យសុំនៃសុំកូនធម្មតា) ខាងលើនេះ ជាមួយនឹងសហព័ទ្ធ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ។

**មាត្រា ១០២៣.–** មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនធម្មតា

១-តុលាការ អាចឱ្យបង្កើតសុំកូនបាន លុះត្រាតែករណីដែលអាចបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ភាគី ក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្ដាយ និង កូន ។

២-តុលាការមិនត្រូវឱ្យបង្កើតសុំកូនឡើយ បើយល់ឃើញថា សុំកូនត្រូវបានបំពានក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍ រវាងភេទផ្សេងគ្នា ឬ ភេទដូចគ្នា ឬ ក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត ។

**មាត្រា ១០២៤.–** ករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន

១-បើបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន តុលាការអាចឱ្យបង្កើតសុំកូនបាន លុះត្រាតែយល់ឃើញថា មានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់អនីតិជន

នោះ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន បើឪពុកម្ដាយបង្កើតរបស់បុគ្គលនោះបានលែងលះហើយ តុលាការត្រូវសួរយោបល់របស់ឪពុក ឬ ម្ដាយដែលមិនមែនជាអ្នកមានអំណាចមេបា ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣-បើអនីតិជនបានដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ដើម្បីបង្កើតសុំកូន ត្រូវទទួលការយល់ព្រមពីអនីតិជននោះ ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០២៥.-** សុំកូនរវាងអ្នកអាណាព្យាបាល និង ជននៅក្រោមអាណាព្យាបាល

ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដាក់ពាក្យសុំឱ្យបង្កើតសុំកូន ដោយយកអនីតិជននៅក្រោមអាណាព្យាបាលរបស់ខ្លួន មកធ្វើជាកូនសុំ ឬ ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅ ដាក់ពាក្យសុំឱ្យបង្កើតសុំកូន ដោយយកជននៅក្រោមអាណាព្យាបាលទូទៅរបស់ខ្លួន មកធ្វើជាកូនសុំ តុលាការអាចឱ្យបង្កើតសុំកូនបាន លុះត្រាតែក្នុងករណីដែលបានអនុវត្តត្រឹមត្រូវ ក្នុងការគ្រប់គ្រងថែរក្សាជននៅក្រោមអាណាព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិ ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតួនាទីរបស់អ្នកអាណាព្យាបាលបានចប់ តែមិនទាន់បានបញ្ចប់ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រង ។

**មាត្រា ១០២៦.-** អានុភាពនៃសុំកូនធម្មតា ចំពោះបុត្តភាព

១-ទោះបីជាមានការបង្កើតសុំកូនធម្មតាក៏ដោយ ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ត្រូវបន្តអត្ថិភាព ហើយកូនសុំ និង ឪពុកម្ដាយបង្កើត មានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក ។

២-កូនសុំ និង ឪពុកម្ដាយបង្កើត មានសិទ្ធិទាមទារ និង ករណីយកិច្ចផ្ដត់ផ្គង់

អាហារកាតព្វកិច្ច ។

**មាត្រា ១០២៧.–** អានុភាពនៃសុំកូន ក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្ដាយចិញ្ចឹម ជាអាទិ៍

១-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១០១៥ (អានុភាពនៃសុំកូនពេញលេញ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសុំកូនធម្មតា ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-ក្នុងករណីដែលកូនសុំ ជាអនីតិជន កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលយកកូនបង្កើតរបស់សហព័ទ្ធ មកធ្វើជាកូនសុំ កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុក ឬ ម្ដាយចិញ្ចឹម និង សហព័ទ្ធនោះ ។

**មាត្រា ១០២៨.–** ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា

១-ភាគីនៃសុំកូន អាចដាក់ពាក្យសុំទៅតុលាការ ឱ្យកាត់កាល់សុំកូនបាន ក្នុងករណីដែលភាគីសងខាងព្រមព្រៀងអំពីការកាត់កាល់នោះ ។

២-ក្នុងករណីដែលកូនសុំជាអនីតិជន ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើង ដោយឪពុកម្ដាយចិញ្ចឹម និង បុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ ក្រោយពេលកាត់កាល់ ។ ប៉ុន្តែ បើកូនសុំដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ហើយ ត្រូវទទួលការយល់ព្រមពីកូនសុំនោះ ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើឪពុកម្ដាយបង្កើតរបស់កូនសុំ បានលែងលះគ្នាហើយ ឪពុកម្ដាយបង្កើតរបស់កូនសុំនោះ ត្រូវពិភាក្សា និង កំណត់ថា ឪពុក ឬ ម្ដាយបង្កើត ជាបុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបា នៅក្រោយពេលកាត់កាល់ ។

៤-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់បុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបា ដោយគិតពិចារណាទៅលើផលប្រយោជន៍របស់កូន ។

**មាត្រា ១០២៩.–** ការកាត់កាល់រវាងប្ដីប្រពន្ធដែលបានសុំកូនដោយសហការ និង កូនសុំជាអនីតិជន

ក្នុងករណីដែលប្ដីប្រពន្ធដែលបានសុំកូនដោយសហការគ្នា ជាឪពុកម្ដាយចិញ្ចឹម ដើម្បីកាត់កាល់កូនសុំជាអនីតិជន ប្ដីប្រពន្ធត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់សុំកូនពម្មតា) ខាងលើនេះ ជាមួយគ្នា ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះប្ដីប្រពន្ធណាម្នាក់មិនអាចបង្ហាញឆន្ទៈរបស់ខ្លួន ។

**មាត្រា ១០៣០.–** ការវិនិច្ឆ័យអំពីការកាត់កាល់សុំកូនពម្មតា

បើមានពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់សុំកូនពម្មតា) ខាងលើនេះ តុលាការអាចសម្រេចឱ្យកាត់កាល់សុំកូនបានលុះត្រាតែបានបញ្ជាក់ថា ភាគីសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងរវាងឪពុកម្ដាយ និង កូន ។

**មាត្រា ១០៣១.–** មូលហេតុនៃការកាត់កាល់

១-ភាគីម្ខាងនៃសុំកូន អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យកាត់កាល់បាន លុះត្រាតែក្នុងករណីខាងក្រោមនេះ :

ក-បើត្រូវបានបោះបង់ចោល ដោយភាគីម្ខាងទៀត ដោយទុច្ចរិត ។

ខ-បើមិនច្បាស់ ក្នុងរយៈពេលយ៉ាងតិច ១ (មួយ) ឆ្នាំ ថាភាគីម្ខាងទៀតនៅរស់ ឬ ទទួលមរណភាព ។

គ-បើមានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលបណ្ដាលឱ្យមានការពិបាកក្នុងការបន្តសុំកូន ។

២-ក្នុងអំឡុងពេលដែលកូនសុំពុំទាន់ក្លាយជានីតិជន ឪពុកម្ដាយចិញ្ចឹម មិនអាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះកូនសុំបានឡើយ ។

៣-បើកូនសុំជានីតិជន បញ្ញត្តិចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់សុំកូនពេញ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនសុំដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះឪពុកម្ដាយចិញ្ចឹម ។

**មាត្រា ១០៣២.-** អានុភាពនៃការកាត់កាល់សុំកូនពេញ

១-អានុភាពទាំងឡាយនៃសុំកូនពេញ ត្រូវបញ្ចប់ឆ្ពោះទៅអនាគត ដោយការកាត់កាល់ ។

២-ក្រោយការកាត់កាល់ កូនសុំអាចទទួលវិញ នូវនាមត្រកូលមុនសុំកូនក៏បាន ឬអាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមក៏បាន ។

**មាត្រា ១០៣៣.-** ការចុះបញ្ជីនៃសុំកូនពេញ និង បញ្ជីកំណើត

ប្រសិនបើបានបង្កើតសុំកូនពេញ ត្រូវសរសេរការបង្កើតសុំកូនពេញ នៅលើរឹមទំព័រនៃបញ្ជីកំណើតដើមរបស់កូនសុំនោះ ។

# ឧបសម្ព័ន្ធ២

## ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែន
## ជាបណ្តឹង

# ច្បាប់
# ស្តីពី
# នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី
# ដែលមិនមែនជាបណ្តឹង

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលដៅនៃច្បាប់នេះ**

ច្បាប់នេះមានគោលដៅបញ្ញត្តនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ។

**មាត្រា ២.- គោលបំណងនៃច្បាប់នេះ**

ច្បាប់នេះមានគោលបំណងធានាការអនុវត្តឲ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ។

**មាត្រា ៣.- វិសាលភាពនៃច្បាប់នេះ**

១- ក្នុងចំណោមចំណុចដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់តុលាការ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ចំពោះចំណុចដែលកំណត់ក្នុងផ្នែកនីមួយៗ នៃតារាងឧបសម្ព័ន្ធ តុលាការត្រូវសម្រេចសេចក្ដីតាមបញ្ញត្តិនៃច្បាប់នេះ លើកលែងតែករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

២- ការសម្រេចសេចក្ដីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើងដោយដីកាសម្រេច ។

៣- ក្រៅពីករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់នេះ បញ្ញត្តិស្ដីពីដីកាសម្រេច ដូចមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

## ជំពូកទី ២
## តុលាការ
### ផ្នែកទី ១
### សមត្ថកិច្ចសាលាដំបូងក្ដី

**មាត្រា ៤.- តុលាការដែលមានសមត្ថកិច្ច**

១- រឿងក្ដីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) ខាងលើនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ ។

២- សមត្ថកិច្ចសាលាជម្រះក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ដោយយកពេលដាក់ពាក្យសុំ ។

## មាត្រា ៥.- ការកំណត់តុលាការដែលមានសមត្ថកិច្ច

១- ក្នុងករណីដែលតុលាការមានសមត្ថកិច្ច មិនអាចអនុវត្តសិទ្ធិសម្រេចសេចក្តីបាន ដោយសារច្បាប់ ឬ ហេតុការណ៍ពិត ឬ ករណីដែលសមត្ថកិច្ចសាលាជម្រះក្តីមិនអាចកំណត់បាន ដោយសារដែនសមត្ថកិច្ចនៃតុលាការមិនពិតប្រាកដ តុលាការកំពូលត្រូវកំណត់តុលាការដែលមានសមត្ថកិច្ច ដោយដីកាសម្រេចតាមពាក្យសុំ ។

២- ចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចប្តឹងឧបាស្រ័យបានឡើយ ។

## មាត្រា ៦.- ការចាត់ចែងរឿងក្តីខុសសមត្ថកិច្ច

១- ប្រសិនបើតុលាការយល់ឃើញថា រឿងក្តីណាមួយមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ តុលាការនេះត្រូវផ្ទេររឿងក្តីនោះទៅតុលាការដែលមានសមត្ថកិច្ច តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ ។

២- ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ លើកលែងតែករណីដែលមានការដាក់ពាក្យសុំនៅកាលបរិច្ឆេទ ។ នៅពេលដាក់ពាក្យសុំនេះ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីមូលហេតុនៃពាក្យសុំនោះ ។

## មាត្រា ៧.- សមត្ថកិច្ចជាអាទិភាព និង ការផ្ទេរ

១- ក្នុងករណីមានតុលាការច្រើនមានសមត្ថកិច្ចលើរឿងក្តីណាមួយ តុលាការដែលទទួលពាក្យសុំមុនគេចំពោះរឿងក្តីនោះ ត្រូវមានសមត្ថកិច្ច ។

២- ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាសមរម្យដើម្បីចាត់ចែងរឿងក្តី តុលាការអាចផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានសមត្ថកិច្ចតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិបាន ។

៣- ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ លើកលែងតែករណីដែលមានការដាក់ពាក្យសុំនៅកាលបរិច្ឆេទ។

### មាត្រា ៨.- ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ

តុលាការអាចពិនិត្យភស្តុតាងចំពោះបញ្ហាដែលទាក់ទងនឹងសមត្ថកិច្ចដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

### មាត្រា ៩.- បណ្តឹងជំទាស់

១- ចំពោះដីកាសម្រេចផ្ទេរ និង ដីកាសម្រេចលើកចោលពាក្យសុំផ្ទេរ អាចប្តឹងជំទាស់បាន ។

២- បញ្ញត្តិនៃមាត្រា ៤០ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) និង មាត្រា ៤១ (ការបំពេញនូវសកម្មភាពប្តឹងជំទាស់ ក្រោយពីអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងផុត) នៃច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់ដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

### មាត្រា ១០.- អានុភាពនៃដីកាសម្រេចផ្ទេរ ជាអាទិ៍

១- ដីកាសម្រេចស្ថាពរនៃការផ្ទេរ ត្រូវមានអានុភាពឲ្យតុលាការដែលទទួលការផ្ទេរប្រតិបត្តិតាម ។

២- តុលាការដែលទទួលការផ្ទេរ មិនអាចផ្ទេររឿងក្តីទៅតុលាការផ្សេងទៀតបានឡើយ ។

៣- នៅពេលដីកាសម្រេចផ្ទេរចូលជាស្ថាពរ រឿងក្តីនោះត្រូវចាត់ទុកថាតុលាការដែលទទួលការផ្ទេរចាត់ការតាំងពីដើម ។

៤- នៅពេលដីកាសម្រេចផ្ទេរចូលជាស្ថាពរ តុលាការដែលបានសម្រេចការផ្ទេរ ត្រូវបញ្ជូនសំណុំរឿងអំពីរឿងក្តីនេះ ទៅតុលាការដែលទទួលការផ្ទេរ ។

## ផ្នែកទី ២
## រចនាសម្ព័ន្ធនៃតុលាការ

### មាត្រា ១១.- ការជម្រះក្តីលើកទី ១ ដោយចៅក្រមមួយរូប ឬ ដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម

១- នៅសាលាដំបូង រឿងក្តីត្រូវទទួលបន្ទុកដោះស្រាយដោយចៅក្រមម្នាក់ លើកលែងតែករណីដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២- ចំពោះរឿងក្តីដែលតុលាការយល់ឃើញថា គួរតែត្រូវបានវិនិច្ឆ័យ និង ជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយគិតពិចារណាអំពីចំនួននៃជនពាក់ព័ន្ធ និង បញ្ហាផ្សេងទៀត ត្រូវទទួលបន្ទុកដោះស្រាយដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ។

៣- ក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវមានចៅក្រម ៣ ( បី ) នាក់ ហើយចាត់តាំងម្នាក់ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

៤- ដីកាសម្រេចឲ្យវិនិច្ឆ័យ និង ជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយយោងតាមកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សា ។

## មាត្រា ១២.- ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះ

១- ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះមិនត្រូវធ្វើជាសាធារណៈទេ ។

២- ការពិភាក្សាត្រូវបានបើក និងដឹកនាំដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

៣- ចៅក្រមម្នាក់ៗ ត្រូវបញ្ចេញមតិយោបល់របស់ខ្លួនក្នុងការពិភាក្សានេះ ។

៤- ដំណើរការនៃការពិភាក្សា មតិយោបល់របស់ចៅក្រមម្នាក់ៗ និង ចំនួនសំឡេងនៃមតិត្រូវរក្សាទុកជាសម្ងាត់ ។

## មាត្រា ១៣.- ការសម្រេចនៃក្រុមប្រឹក្សាជំនុំជម្រះ

១- ការសម្រេចត្រូវធ្វើឡើងដោយមតិភាគច្រើនរបស់ចៅក្រមក្នុងក្រុមប្រឹក្សាជំនុំជម្រះ ។

២- ចៅក្រមម្នាក់ៗ ក្នុងក្រុមប្រឹក្សាជំនុំជម្រះ ត្រូវមានសិទ្ធិសម្រេចស្មើគ្នា ។

# ផ្នែកទី ៣

# ការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្តឹងជំទាស់ និង ការដកខ្លួន

## មាត្រា ១៤.- ការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្តឹងជំទាស់ និង ការដកខ្លួនរបស់ចៅក្រម ជាអាទិ៍

១- ពោតិតីពីការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្តឹងជិតចិត្ត និងការដកខ្លួនរបស់ចៅក្រម

## ជំពូកទី ៤
## ប្រាក់ប្រដាប់ក្ដី

### មាត្រា ២២.- បន្ទុកនៃប្រាក់ប្រដាប់ក្ដី

១- ដើម្បីដាក់ពាក្យសុំតាមនីតិវិធីនៃរឿងក្ដីដែលកំណត់ក្នុងច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។

២- បញ្ញត្តិនៃមាត្រា ៦២ (ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ) និង មាត្រា ៦៣ (ប្រាក់ប្រដាប់ក្ដីកាតី) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រាក់ប្រដាប់ក្ដីក្រៅពីពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ។

៣- ប្រាក់ប្រដាប់ក្ដីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ
គឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ
លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសអំពីអ្នកទទួលបន្ទុកនោះក្នុងច្បាប់នេះ ។

៤- ចំពោះរឿងក្ដីដែលតំណាងអយ្យការបានដាក់ពាក្យសុំ ឬ រឿងក្ដីដែលតុលាការបានចាប់ផ្ដើមដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រាក់ប្រដាប់ក្ដីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ ជាបន្ទុករបស់រដ្ឋ ។

៥- បញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្ដីដែលបានបង់រួចហើយ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានជនច្រើននាក់ដែលត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្ដីដោយរួមគ្នា ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៦- ក្នុងករណីដែលអ្នកដាក់ពាក្យសុំ ត្រូវបង់ពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឲ្យបង់ពន្ធនោះ។ ក្នុងករណីនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវលើកលិខិតពាក្យសុំចោលដោយដីកាសម្រេច ។

៧- ចំពោះដីកាសម្រេចលើកចោលលិខិតពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ៦ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៨- ដើម្បីប្តឹងជំទាស់ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣៩ (បណ្តឹងជំទាស់) នៃច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។ បញ្ញត្តិនៃកថាខណ្ឌទី ៦ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដាក់ពាក្យបណ្តឹងជំទាស់មិនបានបង់ពន្ធនោះ ។

## មាត្រា ២៣.- ដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី

១- ប្រសិនបើយល់ឃើញថាចាំបាច់សម្រេចអំពីអ្នកទទួលបន្ទុក ឬ ចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងមាត្រា ២២ (បន្ទុកនៃប្រាក់ប្រដាប់ក្តី)ខាងលើនេះ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីនោះ និង ត្រូវចេញដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តីនោះ ព្រមជាមួយគ្នានឹងដីកាសម្រេចអំពីរឿងក្តីនោះ ។

២- ក្នុងករណីដែលមានស្ថានភាពពិសេស តុលាការអាចបង្គាប់ឲ្យជនពាក់ព័ន្ធដែលមិនមែនជាជនដែលត្រូវទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីតាមបញ្ញត្តិនៃច្បាប់នេះ ទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីទាំងស្រុង ឬ មួយភាគបាន ។

៣- ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី មានតែជនដែលត្រូវបានបង្គាប់ឲ្យទទួលបន្ទុកប្រាក់ប្រដាប់ក្តីនេះទេ ដែលអាចប្តឹងជំទាស់បាន ប៉ុន្តែមិនអាចប្តឹងជំទាស់ដោយឯករាជ្យបានឡើយ ។

## មាត្រា ២៤.- ការអនុវត្តដោយបង្ខំអំពីប្រាក់ប្រដាប់ក្តី

១- ម្ចាស់បំណុលលើប្រាក់ប្រដាប់ក្តី អាចអនុវត្តដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តីបាន ។

២- បញ្ញត្តិនៃគន្ថីទី ៦ (ការអនុវត្តដោយបង្ខំ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តដោយបង្ខំដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប៉ុន្តែមិនចាំបាច់ធ្វើការបញ្ជូនដីកាសម្រេចមុនពេលអនុវត្តទេ ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣០៥ (ការផ្អាកអានុភាពនៃដីកាសម្រេចដើម) នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានបណ្តឹងជំទាស់ ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី ។

**មាត្រា ២៥.- ការបង់ប្រាក់ប្រដាប់ក្តីជំនួសជាមុន**

ចំពោះប្រាក់ប្រដាប់ក្តីសម្រាប់ការពិនិត្យភស្តុតាង ការកោះហៅ ការជូនដំណឹង និង ការចាត់ចែងចាំបាច់ផ្សេងទៀត ដែលធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ រដ្ឋត្រូវបង់ជំនួសជាមុន ប៉ុន្តែចំពោះសកម្មភាពដែលត្រូវការប្រាក់ប្រដាប់ក្តី តុលាការអាចបង្គាប់ឲ្យជនពាក់ព័ន្ធបង់ប្រាក់ប្រដាប់ក្តីនោះជាមុនបាន ។

## ជំពូកទី ៥
## ការវិនិច្ឆ័យ

**មាត្រា ២៦.- របៀបដាក់ពាក្យសុំ និងចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ**

១- ពាក្យសុំអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ។

២- នៅក្នុងលិខិតនៃពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ ៖

ក- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ- ខ្លឹមសារនៃដីកាសម្រេច ឬ សកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ។

៣- ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជី ។ ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និង ចុះហត្ថលេខា ។ កំណត់ហេតុនោះត្រូវបានចាត់ទុកជាលិខិតពាក្យសុំ ។

៤- ក្នុងករណីដែលមានឯកសារជាភស្តុតាង អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដើម ឬ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិតនៃពាក្យសុំ ឬ ត្រូវដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យសុំ ។

# ឧបសម្ព័ន្ធ៣

## ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

# ច្បាប់

# ស្តីពី

# សុំកូនអន្តរប្រទេស

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់ពីគោលការណ៍ លក្ខខណ្ឌ នីតិវិធី ទម្រង់បែបបទ និង អានុភាពនៃសុំកូនអន្តរប្រទេស ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណងធានាឧត្តមប្រយោជន៍ និង ការពារសិទ្ធិជាមូលដ្ឋាន របស់កុមារ ដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពលើការសុំកុមារសញ្ជាតិខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្តីប្រពន្ធ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសណាមួយផ្សេងទៀត ដើម្បីយកទៅចិញ្ចឹមជាកូន ដែលទទួលស្គាល់ដោយច្បាប់នៅប្រទេសនោះ ។

**មាត្រា ៤.-**

វាក្យស័ព្ទសំខាន់ៗ ដែលប្រើប្រាស់ក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

- **ការថែទាំជំនួស** សំដៅដល់ការថែទាំ ដែលផ្តល់ទៅឱ្យកុមារកំព្រា និង កុមារងាយរងគ្រោះ ដែលមិនស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្តាយបង្កើតនៃកុមារទាំងនោះ ។
- **កុមារដែលត្រូវការនូវការថែទាំពិសេស** សំដៅដល់កុមារពិការផ្នែកកាយសម្បទាធ្ងន់ធ្ងរ ឬ ពិការផ្នែកស្មារតី ឬ កុមារដែលមានជំងឺរ៉ាំរ៉ៃ ។
- **កុមារដែលត្រូវគេបោះបង់ចោល** សំដៅដល់កុមារដែលអាជ្ញាធរមានសមត្ថកិច្ចរកឃើញ ឬ ត្រូវបានសាធារណជនរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច និង ជាកុមារដែលមិនស្គាល់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ជាកុមារដែលឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបោះបង់ចោល ហើយមិនឃើញអ្នកទាំងនោះ យ៉ាងតិច ៥ (ប្រាំ) ខែជាប់គ្នា ។

- **ជនម្នាក់** សំដៅដល់ជនដែលគ្មានសហព័ទ្ធស្របច្បាប់ ។

- **ទីភ្នាក់ងារសុំកូនអន្តរប្រទេស** សំដៅដល់ទីភ្នាក់ងារដែលបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និង ពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួលកូនសុំ ដើម្បីធ្វើប្រតិបត្តិការក្នុងនីតិវិធីសុំកូនអន្តរប្រទេស ។

- **មុន្តភាព** សំដៅដល់ក្រសែញាតិ ដែលទាក់ទងពីឪពុកម្តាយទៅកូនបង្កើតរបស់ខ្លួន ។

- **ប្រទេសលំនៅឋានអចិន្ត្រៃយ៍** សំដៅដល់ប្រទេសដែលជនណាមួយកំពុងរស់នៅដោយមានបំណងយកប្រទេសនោះធ្វើជាលំនៅឋានអចិន្ត្រៃយ៍ ។ ជននោះត្រូវបានទទួលស្គាល់ដោយច្បាប់នៃប្រទេសដែលខ្លួនរស់នៅ ថាមានសិទ្ធិរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសនោះ ។

- **មណ្ឌលកុមារកំព្រា** សំដៅដល់មណ្ឌលរបស់រដ្ឋ ឬ របស់អង្គការមិនមែនរដ្ឋាភិបាល ដែលទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សម្រាប់ចិញ្ចឹមថែទាំ និង ផ្តល់នូវតម្រូវការជាមូលដ្ឋានគ្រប់យ៉ាងក្នុងការអភិវឌ្ឍរបស់កុមារដែលគ្មានឪពុកម្តាយ ឬ គ្មានឪពុក ឬ គ្មានម្តាយ ឬ កុមារ ដែលត្រូវបោះបង់ចោល ឬ កុមារដែលឪពុកម្តាយ ឬ អ្នកអាណាព្យាបាលពុំមានលទ្ធភាពផ្តល់ការថែទាំគ្រប់គ្រាន់ ។

- **ប្តីប្រពន្ធ** សំដៅដល់បុរសម្នាក់ និង ស្ត្រីម្នាក់ដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ។

- **សុំកូនដោយសាច់ញាតិ** សំដៅដល់ការសុំកូនដោយអ្នកសុំនូវកុមារដែលត្រូវជាចៅរបស់ខ្លួន ចៅទួតរបស់ខ្លួន ក្មួយរបស់ខ្លួន ឬ កុមារដែលត្រូវជាកូន ចៅ ចៅទួត ឬ ក្មួយរបស់សហព័ទ្ធរបស់ខ្លួន ។

- **សុំកូនពេញលេញ** សំដៅដល់សុំកូនដែលមានអានុភាពបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ ជាឪពុកម្តាយ និង កូនរវាងឪពុកម្តាយចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម និង កូនសុំ និង បញ្ចប់សិទ្ធិ និង កាតព្វកិច្ចរវាងកូននិងឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាល[illegible]នរបស់ខ្លួន ។

- **អ្នកសុំ** សំដៅដល់ប្តីប្រពន្ធដែលកំពុងស្វះស្វែងសុំកុមារយកទៅចិញ្ចឹម ។

- **ឪពុកម្តាយចិញ្ចឹម** សំដៅដល់ប្តីប្រពន្ធដែលបានទទួលសិទ្ធិជាផ្លូវការពី

តុលាការមានសមត្ថកិច្ច ឱ្យធ្វើជាឪពុកម្តាយថ្មីនៃកូនសុំស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ ។

## ជំពូកទី ២

## គោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេស

**មាត្រា ៥.-**

សុំកូនអន្តរប្រទេសត្រូវអនុវត្តតាមគោលការណ៍ដូចតទៅ :

១- កុមារត្រូវចម្រើនធំធាត់នៅក្នុងបរិយាកាសគ្រួសារ បរិយាកាសសុភមង្គល សេចក្តីស្រឡាញ់ និង ការយោគយល់ ដើម្បីឱ្យមានការអភិវឌ្ឍពេញលេញ និង យ៉ាងសុខដុមនូវបុគ្គលិកលក្ខណៈរបស់ខ្លួន ។ សុំកូនអន្តរប្រទេស អាចអនុញ្ញាតបានក្រោយពីអស់លទ្ធភាពផ្តល់ការឧបត្ថម្ភគាំទ្រ ដើម្បីឱ្យកុមាររស់នៅក្នុងគ្រួសារកំណើត និង ក្រោយពីបានធ្វើការពិចារណា អំពីសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- សុំកូនអន្តរប្រទេស អាចប្រព្រឹត្តទៅបានលុះត្រាតែជាសុំកូនពេញលេញ ដែលបង្កើតនូវទំនាក់ទំនងរវាងអ្នកសុំ និង កូនសុំជាអចិន្ត្រៃយ៍ និង ដែលផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និង កាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះ ។

៣- កុមារទាំងឡាយណាដែលបំពេញបាននូវលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១០ អាចធ្វើជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបានដោយមិនមានការរើសអើងអំពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិកំណើត ឋានៈក្នុងសង្គម ធនធាន ពិការភាព ឬ ស្ថានភាពផ្សេងៗទៀតរបស់កុមារ ឬរបស់ឪពុកម្តាយ ឬ របស់ឪពុក ឬ របស់ម្តាយ ឬ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

៤- រាល់ការសម្រេច និង សកម្មភាពទាក់ទងនឹងដំណើរការសុំកូនអន្តរប្រទេសត្រូវគិតគូរឱ្យបានច្រើនលើសលប់ដល់ឧត្តមប្រយោជន៍របស់កុមារ ។

៥- តុលាការ និង អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងដំណើរការសុំកូនអន្តរប្រទេស ត្រូវធានាថា នៅពេលកំពុងដំណើរការនីតិវិធីសុំកូន កុមារដែលមានសមត្ថភាពអាចយល់ដឹងសព្វគ្រប់ ត្រូវបានពិគ្រោះយោបល់ និង ពន្យល់ណែនាំឱ្យបានត្រឹមត្រូវអំពីអានុភាព

នានា ដែលកើតចេញពីសុំកូននេះដោយគិតគូរដល់សេចក្តីប្រាថ្នា និង មតិរបស់កុមារ ដើម្បីឧត្តមប្រយោជន៍របស់កុមារ ។

៦- ហាមការធ្វើអាជីវកម្ម ឬ ធ្វើសកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេស ។ អាជីវកម្ម ឬ សកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេសមាន :

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ដល់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឱ្យបោះបង់ទារកដែលកើតមកហើយ ឬ ដែលនឹងកើតដើម្បីឱ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ឪពុក ឬ ម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត និង

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅឱ្យអ្នកសុំ ។

៧- អាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធក្នុងនីតិវិធីសុំកូនអន្តរប្រទេស ត្រូវធានាថាដំណើរការសុំកូនអន្តរប្រទេស មិនបណ្តាលឱ្យមានការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនស្របច្បាប់ និង ត្រូវបង្ការមិនឱ្យមានការចាប់ពង្រត់ ការលក់ និង ការជួញដូរកុមារក្នុងពេលកំពុងដំណើរការសុំកូនអន្តរប្រទេស ។ មានតែប្រាក់ចំណាយ សោហ៊ុយ និង វិភាគទាន ដែលកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់នេះដែលត្រូវបង់ ។

## ជំពូកទី ៣

## អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស

**មាត្រា ៦.–**

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច បំពេញតួនាទីជាអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

មាត្រា ៧.-

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសមានតួនាទី និង ភារកិច្ចដូចតទៅ :

១- រៀបចំ និង ត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និង នីតិវិធីទាក់ទងនឹងការសម្រេចលើកិច្ចការសុំកូនអន្តរប្រទេស ។

២-ធ្វើសហប្រតិបត្តិការ និង ធ្វើការសម្របសម្រួលលើការប្រាស្រ័យទាក់ទងគ្នា ទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេសជាមួយក្រសួង ស្ថាប័ន និង ទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយកិច្ចការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង ជាមួយអាជ្ញាធរកណ្តាល និង អាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេស នៃប្រទេសទទួល ។

៣- ចាត់វិធានការសមស្របដើម្បីបង្ការ និង ទប់ស្កាត់ ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬ ផលចំណេញផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស ។

៤- រៀបចំបណ្តុះបណ្តាលជំនាញកិច្ចការសុំកូនអន្តរប្រទេសដល់មន្ត្រីពាក់ព័ន្ធ។

៥- ពិនិត្យលើសំណើរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសនីមួយៗតាមការចាំបាច់ ។

៦- ធ្វើអធិការកិច្ចលើកិច្ចការពាក់ព័ន្ធសុំកូនអន្តរប្រទេស ។ គ្មានជនណាអាចរារាំង បង្អាក់ ឬ ជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានឡើយ ។

៧- បំពេញភារកិច្ចផ្សេងៗទៀតដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច យល់ថាចាំបាច់សម្រាប់អនុវត្តកិច្ចការសុំកូនអន្តរប្រទេស ដោយអនុលោមទៅតាមច្បាប់ និង បទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៨.-

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស មានរដ្ឋបាលសុំកូនអន្តរប្រទេសជាលេខាធិការ ។ មន្ត្រីបម្រើការក្នុងរដ្ឋបាលសុំកូនអន្តរប្រទេសរួមមាន អ្នកធ្វើការងារផ្នែកសង្គមកិច្ច [illegible] និង អ្នកជំនាញខាងច្បាប់បានទទួលការបណ្តុះបណ្តាលពិសេស ស្តីពីសុំកូន

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

**មាត្រា ៩.–**

រដ្ឋបាលសុំកូនអន្តរប្រទេស មានតួនាទី និង ភារកិច្ចដូចតទៅ ៖

១-រៀបចំ ថែរក្សាបញ្ជីសម្ងាត់ និង សំណុំឯកសាររបស់កុមារដែលមានលក្ខណ-សម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស ។

២-វាយតម្លៃស្ថានភាពកុមារទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីសម្ងាត់ដើម្បីកំណត់ទម្រង់នៃការចិញ្ចឹមថែទាំសមស្របបំផុតសម្រាប់កុមារ និង ធានាថាកុមារទាំងនោះទទួលបានការចិញ្ចឹមថែទាំតាមតម្រូវការ ។

៣-ប្រឹងប្រែងរកដំណោះស្រាយឱ្យអស់លទ្ធភាពក្នុងប្រទេស ក្នុងការថែទាំជាអចិន្ត្រៃយ៍នៅតាមគ្រួសារ ឬ នៅជាមួយអ្នកអាណាព្យាបាល មុននឹងដំណើរការសុំកូនអន្តរប្រទេស ។

៤-ទទួលពិនិត្យ និង ចាត់ការពាក្យសុំកូនអន្តរប្រទេស និង ឯកសារពាក់ព័ន្ធផ្សេងៗទៀតរបស់អ្នកសុំ ។

៥-ផ្គូផ្គងអ្នកសុំជាមួយកុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស និង ផ្តល់មតិយោបល់លើករណីសុំកូនអន្តរប្រទេស ជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

៦-ផ្តល់ដំណឹងទៅអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតពីប្រទេសទទួល អំពីនីតិវិធីសុំកូន និង ការវិវឌ្ឍនៃករណីសុំកូន ។

៧-សម្របសម្រួលការប្រគល់កុមារទៅឱ្យអ្នកសុំ និង រៀបចំឯកសារ ដើម្បីឱ្យកុមារធ្វើដំណើរចូលទៅប្រទេសរបស់អ្នកសុំ ។

៨-ផ្តល់ ឬ សម្របសម្រួលការផ្តល់សេវាក្រោយសុំកូនសមស្របដល់កុមារ ក្រុមគ្រួសារកំណើត និង គ្រួសារបង្កើតតាមការចាំបាច់ ។

៩-ផ្តល់មតិយោបល់ទាក់ទងនឹងការផ្តល់ការអនុញ្ញាតឱ្យទីភ្នាក់ងារសុំកូនអន្តរ-

ប្រទេស ធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ឬ ការដកហូតការអនុញ្ញាត ជូនអាជ្ញាធរកណ្តាល ទទួលខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស ។

១០- បំពេញភារកិច្ចផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសតាមការចាំបាច់ ដោយអនុលោមទៅតាមច្បាប់ និង បទបញ្ញា របស់ព្រះរាជាណាចក្រកម្ពុជា និង តាមការប្រគល់អំណាចរបស់អាជ្ញាធរកណ្តាល ។

## ជំពូកទី ៤
## លក្ខខណ្ឌសម្រាប់សុំកូន
### ផ្នែកទី ១
### កូនសុំ

**មាត្រា១០.–**

កុមារដែលអាចជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបាន ត្រូវឆ្លើយតបនឹងលក្ខខណ្ឌទាំងអស់ ដូចខាងក្រោម :

១- កុមារសញ្ជាតិខ្មែរដែលមានលំនៅឋានជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-កុមារមានអាយុក្រោម ៨ (ប្រាំបី) ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំ លើកលែងតែករណីកុមារត្រូវការនូវការថែទាំពិសេស ដែលអាចអនុញ្ញាតបានដល់អាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។ ក្នុងករណី កុមារមានបងប្អូនបង្កើតច្រើននាក់ ហើយម្នាក់មានអាយុក្រោម ៨ (ប្រាំបី) ឆ្នាំ អាចអនុញ្ញាតឱ្យសុំកុមារនោះរួមជាមួយនឹងបងប្អូនបង្កើតដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

៣- កុមារកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬ រស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀត ដែលត្រួតពិនិត្យដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

៤- កុមារទាំងនោះស្ថិតក្រោមអាណាព្យាបាលសម្រាប់អនីតិជន ឬ កុមារដែល [illegible] អំណាចមេបាដែលមានស្ថានភាពលំបាកបំផុត ។

៥- កុមារនោះត្រូវបានប្រកាសថាអាចសុំជាកូនចិញ្ចឹមបាន ដោយអនុលោមតាមមាត្រា ១[illegible] នៃច្បាប់នេះ ។

10/35 Kol

ក្នុងករណីស៊ុំកូនដោយសាច់ញាតិ ស៊ុំកូនអាចអនុញ្ញាតបានចំពោះកុមារមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលរស់នៅក្នុង ឬ ក្រៅមណ្ឌលកុមារកំព្រា ។

**មាត្រា ១១.–**

ករណីមានកុមារត្រូវបានរកឃើញ និង បញ្ជូនមកមណ្ឌលកុមារកំព្រា ហើយរកមិនឃើញឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ប្រធានមណ្ឌលកុមារកំព្រា ត្រូវជូនដំណឹងទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត អំពីវត្តមានរបស់កុមារ ដែលបានចូលមកស្នាក់នៅក្នុងមណ្ឌល យ៉ាងយូរបំផុតរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីពេលដែលកុមារមកដល់មណ្ឌល ។ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីបញ្ចូលឈ្មោះកុមារទៅក្នុងបញ្ជី ស្តីពីកុមារដែលត្រូវបានរាយការណ៍ថាត្រូវបានគេបោះបង់ចោល ។

មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវប្រឹងប្រែងគ្រប់លទ្ធភាពដើម្បីស្វែងរកឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ និង អ្នកអាណាព្យាបាលសម្រាប់អនីតិជនមុន នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសាធារណៈទៅតាមលទ្ធភាពដូចជា ទូរទស្សន៍ វិទ្យុ ឬ សារព័ត៌មាន និង រូបភាពរបស់កុមារនោះ ។ជនណាដែលអះអាងថាខ្លួនជាឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ជននោះត្រូវបង្ហាញភស្តុតាងផ្សេងៗ ដែលបញ្ជាក់ថាខ្លួនមានជាប់ទាក់ទងជាសាច់ញាតិ ឬ អ្នកអាណាព្យាបាល សម្រាប់អនីតិជនជាមួយកុមារស្របទៅតាមបទប្បញ្ញត្តិជាធរមាន ។

បន្ទាប់ពីការផ្សព្វផ្សាយដំណឹងរយៈពេល ៥ (ប្រាំ) ខែ នៅតែរកមិនឃើញឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ និង អ្នកអាណាព្យាបាល សម្រាប់អនីតិជនមុននោះ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការខិតខំស្រាវជ្រាវនេះ ហើយត្រូវផ្ញើមួយច្បាប់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីចុះឈ្មោះកុមារទៅក្នុងបញ្ជីស្តីពីកុមារដែលត្រូវបោះបង់ចោល ។

ចាប់ពីពេលដែលកុមារត្រូវបានរកឃើញ រហូតដល់តុលាការបានជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ប្រធានមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត គឺជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន ។ បញ្ញត្តិស្តីពីអាណាព្យាបាលសម្រាប់អនីតិជនដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ត្រូវយកអនុវត្តផងដែរ ចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន ។ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន គ្មានសិទ្ធិផ្តល់ការយល់ព្រមលើស៊ុំកូនទេ ។

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវរៀបចំបញ្ជី និង បញ្ចូលព័ត៌មានថ្មីៗឱ្យ បានទៀងទាត់ស្តីពីកុមារដែលត្រូវបោះបង់ចោល ។

ករណីកុមារដែលត្រូវបោះបង់ចោលពុំអាចរកឃើញឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ហើយពុំមានសំបុត្រអត្រានុកូលដ្ឋានកំណើត ប្រធានមណ្ឌលកុមារកំព្រា ត្រូវសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតកុមារនោះ ទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ។

**មាត្រា ១២.-**

ប្រសិនបើ អ្នកអនុវត្តអំណាចមេបាដែលស្ថិតនៅក្នុងស្ថានភាពលំបាកបំផុត បានធ្វើការទុកដាក់កុមារឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនោះ ត្រូវបញ្ចូលឈ្មោះកុមារនៅក្នុងសៀវភៅកត់ត្រាកុមារ ដែលត្រូវបានធ្វើការទុកដាក់ឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវរៀបចំបញ្ជី និង បញ្ចូលព័ត៌មានថ្មីៗឱ្យ បានទៀងទាត់ស្តីពីកុមារដែលអ្នកអនុវត្តអំណាចមេបារបស់ខ្លួន បានធ្វើការទុកដាក់កុមារឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

**មាត្រា ១៣.-**

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបញ្ជូនកុមារទៅគ្រួសារកំណើត ហើយបើមិនអាចធ្វើទៅបានទេ ត្រូវទុកដាក់កុមារតាមរយៈស៊ុំកូនក្នុងស្រុកនៅក្នុងព្រះរាជាណាចក្រកម្ពុជា មុននឹងពិនិត្យរកលក្ខណសម្បត្តិស៊ុំកូនអន្តរប្រទេស

នៅពេលវិបានការផ្សេងៗ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវបានបញ្ចប់ កុមារអាចនឹងត្រូវបានបញ្ចូលឈ្មោះទៅក្នុងបញ្ជីស្តីពីកុមារដែលកំណត់ថាមានលក្ខណ-សម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស ។

## ផ្នែកទី ២
## ការយល់ព្រមលើសុំកូន

**មាត្រា១៤.–**

ដំណើរការសុំកូនអាចប្រព្រឹត្តទៅបានលុះត្រាតែមានការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារតាមករណីដូចខាងក្រោមនេះ :

ក- ក្នុងករណីកុមារមានចំណងបុត្តភាពជាមួយឪពុក និង ម្តាយ ការយល់ព្រមត្រូវផ្តល់ដោយឪពុក និង ម្តាយរបស់កុមារនោះ ។

ខ- ក្នុងករណីដែលឪពុក ឬ ម្តាយណាមួយរបស់កុមារបានស្លាប់ ឬ ស្ថិតក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬ ត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយឪពុក ឬ ម្តាយតែម្ខាងដែលមានអំណាចមេបាជាការគ្រប់គ្រាន់ ។

គ- ក្នុងករណីដែលឪពុកម្តាយរបស់កុមារបានស្លាប់ ឬ ស្ថិតនៅក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬ ត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារនោះ ។

**មាត្រា១៥.–**

ការយល់ព្រមខាងលើត្រូវផ្តល់ឱ្យដោយសេរី និង ច្បាស់លាស់ដោយមិនត្រូវមានវិការៈណាមួយដូចជា ការបង្ខិតបង្ខំ ការឆបោក ឬ ការបញ្ចុះបញ្ចូលតាមរយៈការផ្តល់ ឬ ការសន្យាផ្តល់ប្រាក់ រង្វាន់ សំណង ឬ ផលប្រយោជន៍ណាមួយឡើយ និង ដោយបានដឹងឮ អំពីផលវិបាកនៃការយល់ព្រមរបស់ខ្លួនចំពោះសុំកូនអន្តរប្រទេស ។



**មាត្រា ១៦.-**

ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ត្រូវទទួលនូវការពិគ្រោះយោបល់ពីភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ដែលបានទទួលការអនុញ្ញាតជាមុនសិន មុននឹងផ្តល់ការយល់ព្រម ។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវប្រាប់យ៉ាងច្បាស់លាស់ ដល់អ្នកដែលត្រូវផ្តល់ការយល់ព្រមអំពីអានុភាពនៃការយល់ព្រម ការបញ្ចប់នូវបុត្តភាព ព្រមទាំងការបញ្ចប់សិទ្ធិនិងកាតព្វកិច្ចជាអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង ត្រូវប្រាប់អំពីបែបបទ និង រយៈពេលបញ្ឈប់ការយល់ព្រមដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់នេះ ។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍របស់ខ្លួនជាមួយឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

ទោះក្នុងករណីណាក៏ដោយ ការយល់ព្រមត្រូវផ្តល់សក្ខីកម្មជាលាយលក្ខណ៍អក្សរ នៅចំពោះមុខមេឃុំ ឬ ចៅសង្កាត់ខាងទីលំនៅរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

មេឃុំ ឬ ចៅសង្កាត់ និងភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចត្រូវធានាថា រាល់ការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាការយល់ព្រមដែលគោរពទៅតាមខ្លឹមសារនៃមាត្រា ១៥ នៃច្បាប់នេះ ។

មេឃុំ ឬ ចៅសង្កាត់ ត្រូវចាត់ចែងធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមនេះ ក្រោយពីបានពិនិត្យថា ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចបានពិគ្រោះយោបល់ជាមុនជាមួយឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និង បានប្រាប់យ៉ាងត្រឹមត្រូវអំពីអានុភាពនៃការយល់ព្រមនេះ ។

**មាត្រា ១៧.-**

ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារអាចបញ្ឈប់ការយល់ព្រមរបស់ខ្លួនវិញបាន រហូតដល់មុនពេលសេចក្តីសម្រេចរបស់តុលាការដែលចូលជាស្ថាពរ ។ ការបញ្ឈប់ការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននេះ អាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ នៅចំពោះមុខមេឃុំ ឬ ចៅសង្កាត់ខាងលំនៅឋានរបស់ខ្លួន ។ មេឃុំ ឬ ចៅសង្កាត់ខាង

លិខិតបរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ត្រូវធ្វើកំណត់ហេតុអំពីកិច្ចការនេះ ហើយត្រូវបញ្ជូនកំណត់ហេតុនេះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ប្រធានមណ្ឌលកុមារកំព្រាដែលពាក់ព័ន្ធ និង ត្រូវប្រគល់កំណត់ហេតុចម្លងដែលមានសេចក្តីបញ្ជាក់នៅលើកំណត់ហេតុនោះ ទៅឱ្យឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។

**មាត្រា ១៨.-**

ដំណើរការសុំកូនអាចប្រព្រឹត្តទៅបាន លុះត្រាតែផុតកំណត់ពេល ៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

**មាត្រា ១៩.-**

ករណីឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារបដិសេធការយល់ព្រម ឬ បញ្ឈប់ការយល់ព្រមរបស់ខ្លួន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចប្តឹងសុំឱ្យតុលាការប្រកាសដកហូតអំណាចមេបាពីឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ បញ្ឈប់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និងជ្រើសតាំងអ្នកអាណាព្យាបាលថ្មីសម្រាប់អនីតិជនរបស់កុមារ ក្នុងករណីពិនិត្យឃើញថា ការបដិសេធ ឬ ការបញ្ឈប់ការយល់ព្រមនេះ ធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់កុមារ ឬ បណ្តាលឱ្យប៉ះពាល់ដល់សុខភាព សុវត្ថិភាព ឬ សីលធម៌របស់កុមារ ។ ពាក្យបណ្តឹងទៅតុលាការត្រូវធ្វើក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ បដិសេធ ឬ បញ្ឈប់ការយល់ព្រមរបស់ខ្លួន ។

**មាត្រា ២០.-**

ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារដែលយល់ថា ការយល់ព្រមរបស់ខ្លួនបានមកពីការបង្ខាញបន្ទះដែលមានវិការៈ ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អាចបញ្ឈប់ ឬ លុបចោលនូវការយល់ព្រមរបស់ខ្លួនបាន រហូតដល់មុនដីកាសម្រេចរបស់តុលាការលើសុំកូនចូល

## ផ្នែកទី ៣

## អ្នកសុំ

**មាត្រា ២១.-**

អ្នកសុំដែលអាចអនុញ្ញាតឱ្យសុំកុមារយកទៅចិញ្ចឹមជាកូនបាន ត្រូវឆ្លើយតបនឹងលក្ខខណ្ឌ ដូចតទៅ ៖

១-អ្នកសុំជាប្តីប្រពន្ធត្រូវមានអាយុចាប់ពី ៣០(សាមសិប)ឆ្នាំ និង មានអាយុលើសកូនសុំយ៉ាងតិច ២២(ម្ភៃពីរ)ឆ្នាំ និង យ៉ាងច្រើនបំផុត ៤៥(សែសិបប្រាំ)ឆ្នាំ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យសុំកូន ។

២-ក្នុងករណីដែលអ្នកសុំមិនបានបំពេញតាមចំណុច ១ ខាងលើ ហើយក្នុងករណីសុំកូនឆ្លើយតបនឹងឧត្តមប្រយោជន៍របស់កុមារ សុំកូនអាចអនុញ្ញាតឱ្យបាន ក្នុងស្ថានភាពដូចតទៅ ៖

ក-អ្នកសុំមានដើមកំណើតសញ្ជាតិខ្មែរ សុំកុមារដែលជាសាច់ញាតិរបស់ខ្លួន ឬ

ខ-អ្នកសុំជាសហព័ទ្ធដែលសុំកូននៃសហព័ទ្ធម្ខាងទៀត ឬ

គ-អ្នកសុំ សុំកុមារដែលត្រូវការការថែទាំពិសេស ឬ ស្ថានភាពផ្សេងទៀត ដែលបម្រើឧត្តមប្រយោជន៍របស់កុមារ ។

៣-ក្នុងករណីអ្នកសុំមានប្តី ឬ ប្រពន្ធ ការសុំកូនត្រូវធ្វើដោយសហព័ទ្ធទាំងពីររួមគ្នា លើកលែងតែករណីដែលសហព័ទ្ធណាម្ខាង សុំកូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

៤-ច្បាប់ជាតិរបស់អ្នកសុំនីមួយៗ និង ច្បាប់ប្រទេសនៃលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំបានទទួលស្គាល់ និង អនុញ្ញាតនូវបុគ្គភាពនៃសុំកូនពេញលេញ ។

៥-ប្រទេសនៃសញ្ជាតិ ឬ ប្រទេសលំនៅឋានអចិន្ត្រៃយ៍នៃអ្នកសុំ ត្រូវតែជាប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា ។

៦-អ្នកសុំត្រូវមានលក្ខណសម្បត្តិ និង លក្ខខណ្ឌជាសារវន្តនានាសម្រាប់សុំកូនស្របទៅតាមច្បាប់ប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួន ។

៧-អ្នកសុំត្រូវតែជាជនពុំធ្លាប់ត្រូវបានផ្តន្ទាទោស ឬ កំពុងត្រូវបានប្តឹងអំពីកំហុសទាក់ទងទៅនឹងកិរិយាមារយាទ ឬ ការប្រព្រឹត្តបទល្មើសនុក្រិដ្ឋ ឬ មជ្ឈិមណាមួយនៅក្នុងប្រទេសនៃសញ្ជាតិរបស់ខ្លួន ឬ ប្រទេសលំនៅឋានអចិន្ត្រៃយ៍ ឬ ក្នុងប្រទេសណាមួយដែលខ្លួនបានស្នាក់នៅចុងក្រោយ ។

៨-អ្នកសុំត្រូវតែជាអ្នកមានសមត្ថភាពផ្តល់ការថែទាំសមស្រប និង ការគាំទ្រចាំបាច់ដល់កូនសុំ ។

៩-អ្នកសុំត្រូវបានអនុញ្ញាតឱ្យសុំកូនបាន លុះត្រាតែអ្នកសុំកូនគ្មានកូន ឬ មានកូនតែម្នាក់នៅក្នុងបន្ទុក ។ អ្នកសុំអាចសុំកូនបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែកុមារដែលមានបងប្អូនបង្កើតអាចអនុញ្ញាតឱ្យ សុំច្រើននាក់បាន ។

## ជំពូកទី ៥
## នីតិវិធីសុំកូន
### ផ្នែកទី ១
### នីតិវិធីរដ្ឋបាល

**មាត្រា ២២.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវរៀបចំសំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសរួមមាន ព័ត៌មានចាំបាច់អំពីអត្តសញ្ញាណរបស់កុមារ ភាពអាចសុំជាកូនចិញ្ចឹម សាវតារជាតិរបស់កុមារ បរិយាកាសសង្គមរបស់កុមារ ប្រវត្តិគ្រួសាររបស់កុមារ ប្រវត្តិសុខភាពរបស់កុមារ និង ប្រវត្តិសុខភាពគ្រួសាររបស់កុមារ និង សេចក្តីត្រូវការជាពិសេសណាមួយរបស់កុមារ ។

ក្នុងករណីកុមារត្រូវបានបោះបង់ចោល រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា ការខិតខំប្រឹងប្រែងដើម្បីស្វះស្វែងរកឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារត្រូវបានធ្វើរួចហើយ ។

រដ្ឋបាលសុំកូនអន្តរប្រទេសក៏ត្រូវធានាផងដែរថា រាល់ការយល់ព្រមចាំបាច់ទាំងឡាយត្រូវបានធ្វើឡើងស្របទៅតាមបទប្បញ្ញត្តិនានានៃច្បាប់នេះ ។

ROYAUME du CAMBODGE • LE MINISTRE du PALAIS ROYAL

សំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារ រាប់បញ្ចូលទាំងភស្តុតាងបង្ហាញពីការយល់ព្រម និង/ឬ ការខិតខំប្រឹងប្រែងដើម្បីស្វះស្វែងរកឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារផងដែរ ។

មាត្រា ២៣.-

អ្នកសុំត្រូវដាក់ពាក្យសុំកូនទៅអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាដោយភ្ជាប់មកជាមួយនូវឯកសាររួមមាន :

១-ភស្តុតាងដែលបញ្ជាក់ថា អាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់ខ្លួន ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ចាត់ទុកថា អ្នកសុំមានលក្ខណសម្បត្តិ និង មានភាពសមស្រប សម្រាប់សុំកូនដោយផ្អែកលើការវាយតំលៃលើជីវប្រវត្តិផ្ទាល់ខ្លួន ប្រវត្តិគ្រួសារ ប្រវត្តិសុខភាព បរិយាកាសគ្រួសារ បរិយាកាសសង្គម មូលហេតុសុំកូន និងលទ្ធភាពនៃការទទួលបន្ទុកចិញ្ចឹមបីបាច់ថែរក្សា ឬ រ៉ាប់រងចំពោះសុំកូនអន្តរប្រទេស ។

២-ព័ត៌មានចាំបាច់ទាក់ទងនឹងការឆ្លើយតបទៅនឹងលក្ខខណ្ឌនានាដែលមានចែងក្នុងមាត្រា ២១ នៃច្បាប់នេះ ។

៣-ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកសុំ ដែលក្នុងនោះរួមមានឯកសារទាក់ទងនឹងអត្រានុកូលដ្ឋាន ។

៤-ព័ត៌មានទាក់ទងនឹងលក្ខណសម្បត្តិផ្សេងៗរបស់កុមារ ដែលអ្នកសុំអាចនឹងមានលក្ខណសម្បត្តិថែទាំបាន ។

៥-ភស្តុតាងទទួលបានពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលដែលបញ្ជាក់ថា នៅពេលពាក្យសុំកូនរបស់ខ្លួនត្រូវបានយល់ព្រមហើយ កូនសុំនោះត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសទទួល ។

ឯកសារទាំងអស់ ត្រូវបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

គ្រប់ឯកសារច្បាប់ដើមទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេស ឬ ភាសាបារាំងដែលមានការបញ្ជាក់ត្រឹមត្រូវ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

18/35

Kol

**មាត្រា ២៤.–**

ពាក្យសុំដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ត្រូវបញ្ជូនមកក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ តាមរយៈអាជ្ញាធរកណ្តាល ស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសទទួលប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលបានបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារទាំងនោះ ។ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យផ្តល់យោបល់ និង ត្រូវបញ្ជូនសំណុំឯកសារសុំកូនអន្តរប្រទេស ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលពាក្យសុំ ។ ក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ (ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលពាក្យសុំពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកសុំ តាមរយៈអាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់អ្នកសុំ ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ ដោយបញ្ជាក់ថា ខ្លួនបានទទួលពាក្យសុំកូន ។

**មាត្រា ២៥.–**

អ្នកសុំត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និង វិភាគទានានា សម្រាប់ជួយឧបត្ថម្ភដល់ជីវភាពនានានៃការថែទាំជំនួស និង ការជួយឧបត្ថម្ភទូទៅដល់មណ្ឌលកុមារកំព្រារបស់រដ្ឋទូទាំងប្រទេស និង កម្រៃសេវាចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសដែលនឹងកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ ក្រៅពីនេះ មិនត្រូវយកថ្លៃសោហ៊ុយសុំកូនពីអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូន ។ មិនអនុញ្ញាតឱ្យអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូនបង់ថ្លៃសោហ៊ុយសុំកូនទៅតាមកុមារម្នាក់ៗ ឬ ទៅតាមសោហ៊ុយសុំកូនមួយៗដែលនឹងត្រូវបញ្ជូនទៅឱ្យមណ្ឌលកុមារកំព្រាណាមួយ ឬ មិនអនុញ្ញាតឱ្យអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូនធ្វើការផ្តល់សោហ៊ុយ អំណោយ ឬ ការទូទាត់ ទោះក្នុងរូបភាពណាក៏ដោយឱ្យទៅមណ្ឌលកុមារកំព្រាដែលកុមារនៅទីនោះត្រូវបានសុំយកទៅចិញ្ចឹម ឬ ទៅឱ្យបុគ្គលិក នាយក ឬ សមាជិកនៃគណៈគ្រប់គ្រងទោះជាដោយផ្ទាល់ ឬ ដោយប្រយោលក្តី ។



**មាត្រា ២៦.–**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចទទួលសំណុំលិខិតសុំកូន ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។ ក្នុងករណីសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ហើយ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវបញ្ជាក់ថា អ្នកសុំបានបំពេញលក្ខខណ្ឌត្រឹមត្រូវតាមច្បាប់នេះហើយ ។

ក្នុងករណីដែលសំណុំលិខិតដាក់ជូនរដ្ឋបាលសុំកូនអន្តរប្រទេស មិនទាន់គ្រប់គ្រាន់ ឬ មិនទាន់ត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវជូនដំណឹងទៅអ្នកសុំជាលាយលក្ខណ៍អក្សរអំពីឯកសារដែលនៅខ្វះ ឬ មិនទាន់ត្រឹមត្រូវ តាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលឯកសារដែលនៅខ្វះ ឬ កែតម្រូវរួច។

ក្នុងករណីអ្នកសុំខកខានមិនបានផ្តល់ឯកសារដែលនៅខ្វះ ឬ មិនទាន់ត្រឹមត្រូវក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃរដ្ឋបាលសុំកូនអន្តរប្រទេសបានជូនដំណឹងអំពីឯកសារដែលមិនទាន់គ្រប់គ្រាន់ ឬ មិនទាន់ត្រឹមត្រូវ នោះពាក្យសុំកូនអន្តរប្រទេសត្រូវទុកជាមោឃៈ ។

ក្នុងករណីបដិសេធពាក្យសុំ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវមានបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរ ។

**មាត្រា ២៧.–**

ក្នុងករណីសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ និង ត្រឹមត្រូវ ហើយអ្នកសុំបានបំពេញទៅតាមលក្ខខណ្ឌនៃច្បាប់នេះ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យពិចារណាទៅលើសំណុំឯកសាររបស់កុមារទាំងឡាយដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសបាន និងត្រូវផ្គូផ្គងពីលក្ខណសម្បត្តិរបស់អ្នកសុំណាដែលត្រូវគ្នាល្អបំផុតនឹងលក្ខណសម្បត្តិរបស់កុមារ ។

ក្នុងការផ្តល់ដោយគិតគូរដល់ឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិចារណាឱ្យបានសមស្របទៅលើអត្ថប្រយោជន៍នៃការបន្តឱ្យមានការបីបាច់ថែរក្សាកុមារ ដូចពេលកន្លងមក ព្រមទាំងពិចារណាទៅលើសាវតារសង្គម ជាតិពន្ធុ សាសនា និងវប្បធម៌របស់កុមារ ។

**មាត្រា ២៨.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវផ្ញើសំណុំឯកសាររបស់កុមារដែលត្រូវបានផ្តល់ រួមទាំងភស្តុតាងដែលបង្ហាញថា រាល់ការយល់ព្រមចាំបាច់នានា ត្រូវបានទទួលរួចហើយ និងមូលហេតុដែលខ្លួនកំណត់ទុកដាក់កុមារជាមួយអ្នកសុំនោះទៅអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីពិនិត្យនិងបញ្ជូនទៅអ្នកសុំដោយមិនចាំបាច់ជូនដំណឹងអំពីអត្តសញ្ញាណឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារឡើយ លើកលែងតែករណីសុំកូនដោយសាច់ញាតិ ។

**មាត្រា ២៩.-**

អ្នកសុំត្រូវឆ្លើយតបទៅរដ្ឋបាលសុំកូនអន្តរប្រទេសជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមសុំកុមារ ដែលរដ្ឋបាលសុំកូនអន្តរប្រទេសបានផ្តល់ឱ្យតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ។

ក្នុងករណីអ្នកសុំមិនបានឆ្លើយតបមករដ្ឋបាលសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលរដ្ឋបាលសុំកូនអន្តរប្រទេសបានផ្ញើសំណុំឯកសាររបស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសអាចចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ហើយរដ្ឋបាលសុំកូនអន្តរប្រទេសអាចផ្តល់កុមារនោះឱ្យទៅអ្នកសុំផ្សេងទៀតបាន ។ ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទានទាក់ទងនឹងការដាក់ពាក្យសុំមិនត្រូវបានបង្វិលសងវិញឡើយ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ក្នុងករណីអ្នកសុំបានឆ្លើយតបថាមិនទទួលយកកុមារដែលបានផ្តល់ផ្គងឱ្យខ្លួននៅលើកទីមួយទេ អ្នកសុំនោះអាចស្នើសុំឱ្យរដ្ឋបាលសុំកូនអន្តរប្រទេសផ្តល់ផ្គងកុមារជាលើកទីពីរបាន ។ ការផ្តល់ផ្គងនេះមិនត្រូវអនុញ្ញាតឱ្យធ្វើជាលើកទីបីឡើយ ។

ចំពោះអ្នកសុំដែលមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ អ្នកសុំនោះអាចដាក់ពាក្យសុំកូនសាជាថ្មីស្របតាមនីតិវិធីនៃច្បាប់នេះ ។ ក្នុងការសម្រេចអំពីការសុំឱ្យមានការផ្តល់ផ្គងសាជាថ្មី ឬ ការទទួលពាក្យសុំកូនសាជាថ្មី រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិចារណាអំពីមូលហេតុដែលអ្នកសុំខកខានមិនបានឆ្លើយតប ឬ ឆ្លើយតបថា មិនមានបំណងសុំកុមារដែលបានផ្តល់ផ្គងពីលើកមុនតាពេលកន្លងមក ។

**មាត្រា ៣០.–**

បន្ទាប់ពីអ្នកសុំ បានបញ្ជាក់ការយល់ព្រមរបស់ខ្លួនស្របតាមបទប្បញ្ញត្តិក្នុងមាត្រា ២៩ នៃច្បាប់នេះ ហើយអាជ្ញាធរកណ្តាលនៃប្រទេសទទួល បានយល់ព្រមលើការសម្រេចនេះ រដ្ឋបាលសុំកូនអន្តរប្រទេសតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ត្រូវរៀបចំឱ្យមានការជួបប្រាស្រ័យរវាងអ្នកសុំ និង កុមារដែលត្រូវបានផ្តល់ផ្គងរួចហើយ ។

ការជួបប្រាស្រ័យនេះត្រូវប្រព្រឹត្តទៅតាមកាលបរិច្ឆេទមួយសមស្របសម្រាប់អ្នកសុំ និង រដ្ឋបាលសុំកូនអន្តរប្រទេស និង ត្រូវមានវត្តមានមន្ត្រីសង្គមកិច្ចមានសមត្ថកិច្ចមួយរូបផង ។ ការជួបប្រាស្រ័យនេះ ត្រូវធ្វើក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលការយល់ព្រមពីអ្នកសុំ ។

មុនការជួបប្រាស្រ័យរវាងអ្នកសុំ និង កុមារ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធ្វើសម្ភាសន៍អ្នកសុំ និង ធានាថា អ្នកសុំ និង កុមារត្រូវបានរៀបចំខ្លួនជាស្រេចតាមរយៈការពិគ្រោះយោបល់ ការផ្លាស់ប្តូរព័ត៌មាន ការផ្លាស់ប្តូររូបថត និង វិធានការចាំបាច់ផ្សេងៗទៀត ដើម្បីការជួបប្រាស្រ័យនេះ ។

ករណីមានសហព័ទ្ធ បើសហព័ទ្ធណាម្ខាងមិនអាចមកបាន សហព័ទ្ធនោះត្រូវធ្វើលិខិតប្រគល់សិទ្ធិឱ្យទៅសហព័ទ្ធម្ខាងទៀត ធ្វើជាអ្នកតំណាងរបស់ខ្លួន ដើម្បីធ្វើសកម្មភាពក្នុងការសុំកូននេះ ។ លិខិតប្រគល់សិទ្ធិត្រូវមានការបញ្ជាក់ពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសទទួល ។

ក្នុងករណីអ្នកសុំមិនមកក្នុងរយៈពេលដូចបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើ ដោយគ្មានមូលហេតុត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវសាកសួរយោបល់របស់កុមារដែលអាចដឹងខុសត្រូវបាន ព្រមទាំងប្រាប់កុមារឱ្យបានដឹងអំពីអានុភាពដែលកើតចេញពីសុំកូននេះ ហើយត្រូវស្តាប់កុមារបញ្ចេញមតិយោបល់របស់ខ្លួន ដោយគ្មានវត្តមានរបស់ភាគីផ្សេងទៀតឡើយ ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវយល់ដឹងឱ្យបានច្បាស់ អំពីទស្សនៈកុមារលើរាល់បញ្ហាដែលពាក់ព័ន្ធផលសុំកូន ក្នុងនោះមានជាអាទិ៍ ការជ្រើសរើសអ្នកសុំ ហើយមតិយោបល់របស់កុមារត្រូវយកទៅគិតគូរពិចារណាដោយផ្អែកទៅតាមវ័យ និង កម្រិតយល់ដឹងរបស់កុមារ ។ សំអាងស្តីពីការយល់ព្រមរបស់កុមារត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍ និង ការជួបប្អាខាងលើនេះ ។

**មាត្រា ៣១.–**

បទប្បញ្ញត្តិ ដែលមានចែងក្នុងជំពូកនេះត្រូវយកមកអនុវត្តផងដែរចំពោះសុំកូនដោយសាច់ញាតិ ។

**មាត្រា ៣២.–**

ក្នុងករណីរដ្ឋបាលសុំកូនអន្តរប្រទេសពិនិត្យឃើញថា អ្នកសុំ និង កុមារបំពេញបាននូវលក្ខណវិនិច្ឆ័យ និង លក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស ហើយសុំកូននេះពិតជាបានឆ្លើយតបទៅនឹងឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវផ្តល់មតិយោបល់ជាវិជ្ជមានក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីការជួបប្អាររវាងអ្នកសុំ និង កុមារ ។

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវដាក់សំណុំលិខិតទាំងនេះ ជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំការពិនិត្យ និង ផ្តល់អនុសាសន៍លើដំណើរការសុំកូន ។

**មាត្រា ៣៣.–**

ក្រោយពីទទួលអនុសាសន៍លើដំណើរការសុំកូនពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អ្នកសុំត្រូវសហការជាមួយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដាក់ពាក្យសុំកូនដែលបានផ្គូផ្គងរួច តាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេសទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីសុំដីកាសម្រេចសុំកូន ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវបញ្ជូនពាក្យសុំកូនទៅសាលាដំបូងរាជធានីភ្នំពេញដោយភ្ជាប់មកជាមួយនូវសំណុំឯកសាររបស់កុមារ និង អ្នកសុំ ព្រមទាំងអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ គិតពីកាលបរិច្ឆេទទទួលពាក្យសុំ ។ ឯកសារចាំបាច់ទាំងអស់ត្រូវបកប្រែជាភាសាខ្មែរ និង មានការបញ្ជាក់ពីរដ្ឋបាលសុំកូនអន្តរប្រទេស ។

ក្នុងករណីអ្នកសុំមិនបានដាក់ពាក្យសុំក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចាត់ទុកថាអ្នកសុំនោះបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ។

## ផ្នែកទី ២
## នីតិវិធីតុលាការ

**មាត្រា ៣៤.–**

សាលាដំបូងរាជធានីភ្នំពេញ មានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស ។

តុលាការដែលមានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស ត្រូវយកបទប្បញ្ញត្តិស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងមកអនុវត្តចំពោះនីតិវិធីតុលាការទាក់ទងនឹងសុំកូនអន្តរប្រទេស លើកលែងតែមានបទប្បញ្ញត្តិពិសេសដូចមានចែងនៅក្នុងច្បាប់នេះ ។

**មាត្រា ៣៥.–**

អ្នកសុំត្រូវបង់ប្រាក់សរុបចំនួន ១.០០០.០០០ (មួយលាន) រៀល ដើម្បីទ្រទ្រង់សោហ៊ុយលើពាក្យសុំ ការពិនិត្យភស្តុតាង ការចេញដីកាសម្រេច ការបញ្ជូនឯកសារ ការផ្សព្វផ្សាយសេចក្តីជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និង សកម្មភាពខាងនីតិវិធីផ្សេងៗទៀត

ដែលទាក់ទងនឹងកិច្ចការស៊ុំកូនអន្តរប្រទេស ។ តុលាការត្រូវបង្គាប់ឱ្យអ្នកសុំបង់ចំនួនទឹកប្រាក់នោះជាមុន ។ ក្នុងករណីដែលសោហ៊ុយចាំបាច់ដែលបានកំណត់ខាងលើនេះ លើសពី ១.០០០.០០០ (មួយលាន) រៀល តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែម និង បង្គាប់ឱ្យអ្នកសុំបង់សោហ៊ុយបន្ថែមនោះជាមុន ។ ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញទេ ។

**មាត្រា ៣៦.-**

ជាគោលការណ៍ សំណុំឯកសារ និង របាយការណ៍ដែលដាក់ជូនតុលាការដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវសន្មតជាភស្តុតាងនៃអង្គហេតុពិតទាក់ទងនឹងលក្ខណសម្បត្តិ ស៊ុំកូនរបស់កុមារ និង ភាពសមស្របសម្រាប់ស៊ុំកូនរបស់អ្នកសុំលើកលែងតែមានភស្តុតាងផ្ទុយមកបញ្ជាក់ ។

ក្នុងករណីចាំបាច់ តុលាការអាចបង្គាប់ឱ្យអ្នកតំណាងរដ្ឋបាលស៊ុំកូនអន្តរប្រទេសមកបំភ្លឺបន្ថែមអំពីលទ្ធផលនៃការស្រាវជ្រាវ និង អនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ទាក់ទងនឹងករណីស៊ុំកូនអន្តរប្រទេសរួមទាំងឯកសារ របាយការណ៍ និង ភស្តុតាងជាឯកសារពាក់ព័ន្ធដែលគាំទ្រលទ្ធផលនៃការស្រាវជ្រាវខាងលើ ។

**មាត្រា ៣៧.-**

តុលាការត្រូវពិនិត្យផ្ទៀងផ្ទាត់ថា :

ក- លក្ខណវិនិច្ឆ័យ ឬ លក្ខខណ្ឌទាំងអស់នៃស៊ុំកូនអន្តរប្រទេសត្រូវបានបំពេញ ។

ខ- ការពិគ្រោះយោបល់ជាចាំបាច់នានាត្រូវបានធ្វើមុននឹងផ្តល់ការយល់ព្រម ។

គ- ការយល់ព្រមចាំបាច់នានាត្រូវបានផ្តល់ ដោយគោរពតាមខ្លឹមសារផ្នែកទី ២ ជំពូកទី ៤ នៃច្បាប់នេះ ។

ឃ- មានការពិចារណាត្រឹមត្រូវលើគ្រប់លទ្ធភាពក្នុងការទុកដាក់កុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង- អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារស៊ុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល យល់ព្រមលើការទុកដាក់កុមារ ។

- កុមារនឹងត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេស

៦

ស៊ុំកូនអន្តរប្រទេសនេះពិតជាឧត្តមប្រយោជន៍របស់កុមារ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

25/16.

Kol

**មាត្រា ៣៨.-**

តុលាការសម្រេចសេចក្តីអំពីរឿងក្តីដែលទាក់ទងនឹងសុំកូនអន្តរប្រទេស ដោយពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ។

ក្នុងករណីមានភាពចាំបាច់ដាច់ខាតត្រូវបំភ្លឺអង្គហេតុពាក់ព័ន្ធ តុលាការអាចអញ្ជើញអ្នកសុំ ឬ អ្នកតំណាង ឬ អ្នកមានអំណាចមេបាម្ខាង ឬ ទាំងពីរ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អ្នកតំណាងទីភ្នាក់ងារសុំកូនអន្តរប្រទេសពាក់ព័ន្ធ និងសាក្សីផ្សេងទៀត ដើម្បីផ្តល់ភស្តុតាងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ទាក់ទងនឹងអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុ ។

**មាត្រា ៣៩.-**

តុលាការត្រូវលើកយកសំណុំរឿងសុំកូនអន្តរប្រទេសមកវិនិច្ឆ័យ និងចេញដីកាសម្រេចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំកូន ។ តុលាការត្រូវបញ្ជូនដីកាសម្រេចនេះទៅអ្នកសុំ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូនសុំ និងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ដីកាសម្រេចនេះមិនត្រូវចូលជាស្ថាពរនៅមុនពេលផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ ដែលបានកំណត់នៅក្នុងមាត្រា ៤០ នៃច្បាប់នេះ ។ ក្នុងករណីមានការប្តឹងជំទាស់ចំពោះដីកាសម្រេចនេះ ដីកាសម្រេចនេះមិនត្រូវចូលជាស្ថាពររហូតដល់ពេលមានដីកាសម្រេចអំពីបណ្តឹងជំទាស់នោះ ។

**មាត្រា ៤០.-**

បុគ្គលដែលមានសិទ្ធិ ឬ ផលប្រយោជន៍របស់ខ្លួនត្រូវបានប៉ះពាល់ដោយដីកាសម្រេចលើពាក្យសុំកូនអន្តរប្រទេស អាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ ចំពោះដីកាសម្រេចនោះបាន ។

ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់ជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលខ្លួនទទួលបានការជូនដំណឹងអំពីដីកាសម្រេច ។

ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់ មិនមែនជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ)

LE MINISTRE DU PALAIS ROYAL

16/35

KL

ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដែលអ្នកសុំបានទទួលការជូនដំណឹងអំពីដីកាសម្រេច ។

អំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ដែលកំណត់ក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើមិនអាចពន្យារបានឡើយ ។

សាលាឧទ្ធរណ៍ត្រូវលើកយកពាក្យបណ្តឹងជំទាស់នោះមកវិនិច្ឆ័យ និង ចេញដីកាសម្រេចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្តឹងជំទាស់ ។

ដីកាសម្រេចរបស់សាលាឧទ្ធរណ៍លើបណ្តឹងជំទាស់មិនអាចប្តឹងជំទាស់ទៀតបានឡើយ ។

## ជំពូកទី ៦
## អានុភាពនៃសុំកូន

**មាត្រា ៤១.-**

សុំកូនអន្តរប្រទេសត្រូវតែជាសុំកូនពេញលេញ ។ សុំកូនអន្តរប្រទេសមានអានុភាពបង្កើតនូវទំនាក់ទំនងញាតិភាពរវាងឪពុកម្តាយ និង កូនជាអធិគ្រ្កយ៍ ដោយផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និង កាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម ហើយវាបញ្ចប់ញាតិភាពរវាងកុមារ និង ឪពុកម្តាយបង្កើតរបស់ខ្លួន ។

**មាត្រា ៤២.-**

អានុភាពផ្សេងទៀតនៃសុំកូនអន្តរប្រទេស ត្រូវគ្រប់គ្រងដោយច្បាប់ជាតិរបស់អ្នកសុំ ឬ ប្រសិនបើគ្មានច្បាប់រួមមួយទេ ត្រូវគ្រប់គ្រងដោយច្បាប់នៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

## ជំពូកទី ៧
## ការជូនដំណឹងពីចំណាត់ការ និង នីតិវិធី បន្ទាប់ពីបញ្ចប់ដំណើរការសុំកូនអន្តរប្រទេស

**មាត្រា ៤៣.-**

អ្នកដែលបានសុំកូនអន្តរប្រទេស ត្រូវជូនដំណឹងអំពីការប្រព្រឹត្តទៅនៃនីតិវិធីសុំកូន [illegible]ដែលអាជ្ញាធរមានសមត្ថកិច្ចបានចាត់ការ និង ការវិវត្តនៃការសុំកូននៅគ្រប់

ដំណាក់កាលរបស់នីតិវិធីសុំកូនឱ្យ បានទៀងទាត់ ទៅអ្នកសុំតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាត ។

**មាត្រា ៤៤.–**

ក្រោយពីដីកាសម្រេចរបស់តុលាការចូលជាស្ថាពរ ក្រសួងទទួលបន្ទុកវិស័យសង្គម-កិច្ច ត្រូវជូនដំណឹងទៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ អំពីដីកាសម្រេចនេះ ។

នៅពេលដែលនីតិវិធីសុំកូនអន្តរប្រទេសត្រូវបានបញ្ចប់ ដោយអនុលោមទៅតាមអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និង សហប្រតិបត្តិការ ទាក់ទងនឹងសុំកូនអន្តរ-ប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចេញលិខិតបញ្ជាក់អនុលោមតាមមាត្រា ២៣ នៃអនុសញ្ញានេះ ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវរៀបចំពិធីប្រគល់កុមារ និង លិខិតបញ្ជាក់ស្តីពីការប្រគល់កូនជាផ្លូវការទៅអ្នកសុំ ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវជួយសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងការរៀបចំ និង ផ្តល់នូវលិខិតឆ្លងដែន ទិដ្ឋាការ និង ឯកសារចាំបាច់នានា ដើម្បីឱ្យកុមារធ្វើដំណើរចូលទៅប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

ការធ្វើដំណើររបស់កុមារទៅកាន់ប្រទេសទទួល ត្រូវអមដំណើរដោយអ្នកសុំ ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធានាថាការផ្ទេរកុមារទៅកាន់ប្រទេសទទួល ប្រព្រឹត្តទៅក្នុងកាលៈទេសៈមានសុវត្ថិភាព ដោយមានការគិតគូរដល់សេចក្តីត្រូវការនានារបស់កុមារ ។

**មាត្រា ៤៥.–**

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវសម្របសម្រួលជាមួយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីផ្តល់ ឬ សម្របសម្រួលសេវាក្រោយសុំកូនសមស្របដល់កុមារ គ្រួសារចិញ្ចឹម និង គ្រួសារបង្កើតតាមការចាំបាច់ ។

ក្រោយពីកុមារត្រូវបានទទួលការអនុញ្ញាតឱ្យធ្វើជាកូន ឪពុកម្តាយចិញ្ចឹមត្រូវផ្តល់របាយការណ៍អំពីស្ថានភាពវិវឌ្ឍន៍របស់កុមារមករដ្ឋបាលសុំកូនអន្តរប្រទេសជាទៀងរាល់ ៦ (ប្រាំមួយ) ខែម្តង ក្នុងរយៈពេល ៣ (បី) ឆ្នាំ បន្ទាប់មកត្រូវផ្តល់របាយការណ៍ ១ ឆ្នាំម្តង រហូតដល់កុមារមានអាយុ ១៨ ឆ្នាំ ។

ឪពុកម្តាយចិញ្ចឹមត្រូវផ្ញើរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលសុំកូនអន្តរប្រទេសដោយផ្ទាល់ ឬ តាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល ឬ ប្រទេសជាលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួនទៅតាមស្ថានភាពសមស្រប ។

**មាត្រា ៩៦.–**

រដ្ឋបាលសុំកូនអន្តរប្រទេស និង សាលាដំបូងរាជធានីភ្នំពេញ ត្រូវរក្សាទុកសំណុំឯកសារសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ (ហុកសិប) ឆ្នាំ គិតពីកាលបរិច្ឆេទដែលដីកាសម្រេចសុំកូនអន្តរប្រទេសនោះចូលជាស្ថាពរ ។

សំណុំឯកសារ និង កំណត់ហេតុទាំងអស់ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ទោះជារក្សាទុកនៅតុលាការ រដ្ឋបាលសុំកូនអន្តរប្រទេស ទីភ្នាក់ងារសុំកូនអន្តរប្រទេស មណ្ឌលកុមារកំព្រា និង អ្នកជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធនឹងនីតិវិធីសុំកូនអន្តរប្រទេសត្រូវរក្សាទុកជាការសម្ងាត់ ។ ក៏ប៉ុន្តែសំណុំឯកសារនិងកំណត់ហេតុ ឬ ព័ត៌មានទាំងឡាយដែលមាននៅក្នុងសំណុំឯកសារ និង កំណត់ហេតុទាំងនោះអាចនឹងត្រូវបញ្ចេញទៅតាមការស្នើសុំ ឬ ការបង្គាប់ជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរមានសមត្ថកិច្ច នៅក្នុង ឬ ក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណីមានតម្រូវការទាក់ទងនឹងករណី ឬ នីតិវិធីតុលាការដែលកំពុងតែប្រព្រឹត្តទៅ ឬ កាលៈទេសៈពិសេសដទៃទៀត ។

ឪពុកម្តាយចិញ្ចឹមអាចដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំច្បាប់ចម្លងនៃសំណុំលិខិត ដែលរួមមានអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតរបស់កូនសុំ ក្រោយពីដីកាសម្រេចសុំកូនរបស់តុលាការចូលជាស្ថាពរ ។ កូនសុំដែលដល់អាយុដឹងខុសត្រូវគ្រប់គ្រាន់អំពីផលវិបាកនៃការដឹងអត្តសញ្ញាណរបស់ខ្លួន អាចត្រូវបានអនុញ្ញាតឱ្យមើលសំណុំលិខិតរបស់ខ្លួនរួមទាំងអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតបាន ដោយធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីការមើលនេះជាឧត្តមប្រយោជន៍របស់កូនសុំ ។ កូនសុំដែលឈានចូលអាយុនីតិភាពមានសិទ្ធិមើលសំណុំឯកសារ និង កំណត់ហេតុទាក់ទងនឹងអត្តសញ្ញាណខ្លួន ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា កូនសុំទទួលបានការពិគ្រោះយោបល់សមស្របមុននឹងមើលព័ត៌មាននៅក្នុងសំណុំលិខិតរបស់ខ្លួន ។

## ជំពូកទី ៨

## ការផ្ដល់ការអនុញ្ញាតដល់ទីភ្នាក់ងារ

**មាត្រា ៤៧.-**

មានតែទីភ្នាក់ងារដែលបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជា និង ពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល ស្របតាមមាត្រាជាបន្តបន្ទាប់ដូចខាងក្រោមប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើប្រតិបត្តិការក្នុងនីតិវិធីសុំកូនអន្តរប្រទេស ។

ចំនួនទីភ្នាក់ងារមកពីប្រទេសទទួលនីមួយៗ ដែលអនុញ្ញាតឱ្យផ្ដល់សេវានៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវកំណត់ដោយកិច្ចព្រមព្រៀងរួមគ្នាមួយរវាងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និង អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួល ។

**មាត្រា ៤៨.-**

ដើម្បីសុំការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារត្រូវមានលក្ខណសម្បត្តិដូចតទៅ :

១- មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល ។

២- មានទិសដៅមិនស្វែងរកផលចំណេញ និង បានបំពេញនូវលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិច្បាប់ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ឬ បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងលក្ខណៈនៃទីភ្នាក់ងារនោះ ។

៣- មានអ្នកដឹកនាំនិងមានបុគ្គលិកដែលមានសមត្ថភាពប្រកបដោយគុណធម៌ និង សីលធម៌ ព្រមទាំងបានទទួលការបណ្ដុះបណ្ដាល និង មានបទពិសោធន៍ធ្វើការងារក្នុងវិស័យសុំកូនអន្តរប្រទេស ។

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវបានអនុញ្ញាតឱ្យបើក ឬ យកមណ្ឌលកុមារកំព្រា ជាប្រភពដើម្បីផ្ដល់កូនចិញ្ចឹម ពីកុមារកំព្រា នៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

**មាត្រា ៤៩.-**

ទីភ្នាក់ងារនីមួយៗត្រូវបានចុះបញ្ជីតាមបទប្បញ្ញត្តិច្បាប់ជាធរមាន របស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ឬ បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត ទាក់ទងនឹងលក្ខណៈនៃទីភ្នាក់ងារនោះ មុនពេលដាក់ពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច តាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេស ។ ទីភ្នាក់ងារសុំកូនអន្តរប្រទេសត្រូវចុះកិច្ចសន្យាស្តីពីប្រតិបត្តិការសុំកូនអន្តរប្រទេស និង បំពេញបែបបទផ្សេងៗទៀត តាមការកំណត់របស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

**មាត្រា ៥០.-**

ពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស នៅព្រះរាជាណាចក្រកម្ពុជា ដែលដាក់ជូនរដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារដូចខាងក្រោម :

១- ពាក្យសុំការអនុញ្ញាតដោយមានការយល់ព្រម និង ទទួលស្គាល់ពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

២- ឯកសារសង្ខេបអំពីប្រវត្តិ និង សកម្មភាពរបស់ទីភ្នាក់ងារ ។

៣- ច្បាប់ចម្លងដែលមានបញ្ជាក់ត្រឹមត្រូវអំពីការអនុញ្ញាតឱ្យបើកទីភ្នាក់ងារពីប្រទេសទទួលរបស់ខ្លួន ចំពោះទីភ្នាក់ងារអន្តរជាតិ ។

៤- ច្បាប់ចម្លងលិខិតចុះបញ្ជីដែលមានបញ្ជាក់ត្រឹមត្រូវដូចមានចែងក្នុងមាត្រា ៤៩ នៃច្បាប់នេះ ។

៥- លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងរបស់ទីភ្នាក់ងារ ។

៦- ជីវប្រវត្តិសង្ខេបនិងរូបថតរបស់សមាជិកក្រុមប្រឹក្សាភិបាល ឬ គណៈគ្រប់គ្រង ។

៧- ជីវប្រវត្តិសង្ខេបរបស់បុគ្គលដែលបានទទួលការអនុញ្ញាតឱ្យធ្វើជាអ្នកតំណាងទីភ្នាក់ងារចំពោះកិច្ចការសុំកូនអន្តរប្រទេស ។ អ្នកតំណាងទាំងនេះមិនត្រូវឱ្យលើសពីពីរនាក់ និង មិនមែនជានាយក នាយករង ឬ បុគ្គលិកនៃមណ្ឌលកុមារកំព្រាណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

៨- ឯកសារភស្តុតាងនានាដែលបញ្ជាក់ថាអ្នកតំណាងដូចមានចែងក្នុងចំណុចទី ៧ ខាងលើ គ្មានជាប់ឈ្មោះក្នុងបញ្ជីថ្កោលទោសនៅប្រទេសដើមរបស់ខ្លួន និង នៅប្រទេសចុងក្រោយដែលខ្លួនរស់នៅ ក្នុងករណីប្រទេសខុសគ្នា ។

៩- កិច្ចព្រមព្រៀងទ្វេភាគីស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសុំកូនអន្តរ-ប្រទេស រវាងព្រះរាជាណាចក្រកម្ពុជា និង ប្រទេសរបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ក្នុងករណីដែលប្រទេសនោះមិនមែនជារដ្ឋភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និង សហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសទេ ។

១០- របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មឯករាជ្យ និង កិច្ចព្រមព្រៀងផ្តល់ជំនួយមនុស្សធម៌ ឬ ការជួយឧបត្ថម្ភដល់កុមារកំព្រានានា នៅក្នុងព្រះរាជាណា-ចក្រកម្ពុជា ។

១១- តម្រូវការផ្សេងៗទៀតដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចយល់ថា ចាំបាច់ ដើម្បីជាឧត្តមប្រយោជន៍របស់កុមារ ដូចមានចែងនៅក្នុងនីតិវិធីទាក់ទងនឹងការផ្តល់ការអនុញ្ញាត ។

ច្បាប់ចម្លងចំនួនមួយច្បាប់នៃពាក្យសុំ និង សំណុំលិខិតសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារ ត្រូវផ្ញើជូនស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសទទួល ដែលទីភ្នាក់ងារធ្វើប្រតិបត្តិការនៅទីនោះ ។

**មាត្រា ៥១.-**

ក្នុងកំឡុងពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំការអនុ-ញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅទីភ្នាក់ងារវិញអំពីការសម្រេចជាផ្លូវការរបស់ខ្លួន ។ ក្នុងករណីមានការបដិសេធ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវបញ្ជាក់អំពីមូលហេតុឱ្យ បានច្បាស់លាស់ ។

**មាត្រា ៥២.-**

មានតែអ្នកតំណាងដែលមានឈ្មោះក្នុងសំណុំឯកសារពាក្យសុំការអនុញ្ញាតតែប៉ុណ្ណោះដែលមានសិទ្ធិធ្វើជាអ្នកតំណាងទីភ្នាក់ងារនៅក្នុងដំណើរការសុំកូនអន្តរប្រទេស ។ ក្នុងករណីអ្នកតំណាងដែលបានទទួលការអនុញ្ញាត ត្រូវជំនួសដោយអ្នកផ្សេងនោះ ទីភ្នាក់

32/35

ងារត្រូវដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំការអនុញ្ញាតជាថ្មីឡើងវិញ។

**មាត្រា ៥៣.-**

ការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ត្រូវផ្តល់ឱ្យសម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ ហើយអាចអនុញ្ញាតឱ្យបន្តទៀតបាន ដោយទីភ្នាក់ងារត្រូវដាក់ពាក្យសុំសាជាថ្មី និងត្រូវបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៤៨ មាត្រា ៤៩ និង មាត្រា ៥០ នៃច្បាប់នេះ ដរាបណាសេវារបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស នៅតែចាំបាច់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៩

## ទោសប្បញ្ញត្តិ

**មាត្រា ៥៤.-**

ដោយមិនទាន់គិតដល់ទោសប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ជាធរមាន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចព្យួរ ឬ ដកហូតការទទួលស្គាល់ ឬ បដិសេធការទទួលស្គាល់ ទីភ្នាក់ងារសុំកូនអន្តរ~~ប្រទេសសាជាថ្មី ប្រសិនបើមានភស្តុតាងបង្ហាញឱ្យឃើញ~~ថា ទីភ្នាក់ងារសុំកូនអន្តរប្រទេស ជាប់ពាក់ព័ន្ធនឹងអំពើណាមួយដូចតទៅ :

១- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ឱ្យឪពុកម្តាយ ឬ ឪពុក ឬ ម្តាយបោះបង់ទារកដែលកើតមកហើយ ឬ ដែលនឹងកើត ដើម្បីឱ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស ។

២- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ឪពុកម្តាយ ឬឪពុក ឬ ម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត ។

៣- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅឱ្យអ្នកសុំ ។

៤- អំពើក្លែងបន្លំ ឬ សមគំនិតក្លែងបន្លំស្ថានភាពលំបាកបំផុត ដើម្បីទទួលបាន ការយល់ព្រមពីឪពុកម្តាយបង្កើត ឬ ឪពុកបង្កើត ឬ ម្តាយបង្កើត ឬ អ្នកអាណាព្យាបាល សម្រាប់អនីតិជនរបស់កុមារ ។

៥- អំពើរៀបចំឱ្យមានការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារដោយការបង្ខិតបង្ខំ ការគំរាមកំហែង ការបោក ឬ ការបញ្ចុះបញ្ចូលតាមរយៈការផ្តល់ ឬ សន្យាផ្តល់ប្រាក់ រង្វាន់ សំណង ឬ ផលប្រយោជន៍ណាមួយ ។

៦- ការបញ្ចេញសំណុំឯកសារ និង កំណត់ហេតុទាំងអស់ ឬ មួយផ្នែកទាក់ទង នឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ដោយគ្មានការអនុញ្ញាតពីក្រសួងទទួល បន្ទុកវិស័យសង្គមកិច្ច ឬ តុលាការមានសមត្ថកិច្ច ។

៧- ការបង្គាប់ ឬ ការទទួលដោយផ្ទាល់ ឬ ដោយប្រយោល នូវថ្លៃប្រាក់កាស ទំនិញ ឬ សេវា ដោះដូរនឹងការបម្រុងទុកកុមារណាមួយសម្រាប់សុំកូន ។

៨- ការផ្តល់ប្រាក់កាស ទំនិញ ឬ សេវាទៅឱ្យមន្ត្រី ឬ អ្នកតំណាងណាមួយ នៃរដ្ឋបាលសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាជ្ញាធរកណ្តាលទទួល ខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស ឬ មន្ត្រីពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យផ្តល់នូវសិទ្ធិជាអាទិ- ភាពនៅក្នុងនីតិវិធីសុំកូនអន្តរប្រទេសដល់អ្នកសុំ ។

៩- ការផ្សាយពាណិជ្ជកម្ម ឬ ការបោះពុម្ពផ្សាយនូវអត្តសញ្ញាណ ឬ រូបថត របស់កុមារណាមួយដែលជាកម្មវត្ថុសុំកូន ក្នុងគោលបំណងបញ្ចុះបញ្ចូលបុគ្គលណាមួយ ឱ្យដាក់ពាក្យសុំកូន ។

១០- ការតែងតាំង ឬ ចាត់តាំងអ្នកតំណាងណាមួយដោយមិនមានការឯកភាព ពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

១១- ការចូលរួមក្នុងការរៀបចំការផ្គូផ្គង ឬ ការទាក់ទងគ្នារវាងអ្នកសុំ និង ឪពុកម្តាយបង្កើត ឬ ឪពុកបង្កើត ឬ ម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កុមារក្នុង គោលបំណងកំណត់ទុកជាមុននូវកុមារណាមួយដែលនឹងត្រូវសុំ ។

១២- ការរំលោភបំពានដល់បទប្បញ្ញត្តិនៃច្បាប់នេះ បទដ្ឋានអប្បបរមានៃ ការថែទាំជំនួសចំពោះកុមារ និង បទប្បញ្ញត្តិផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រ កម្ពុជា ។

មាត្រា ៥៥.-

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនអនុវត្តតាមកថាខណ្ឌទី ១ មាត្រា ៤៧ ឬ កថាខណ្ឌទី ២ មាត្រា ៤៨ នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។ ការដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ ប្រាក់ពិន័យអន្តរការណ៍នេះត្រូវបង់ចូលទៅក្នុងមូលនិធិសម្រាប់ទ្រទ្រង់វិស័យសុខុមាលភាពកុមារ ។

ក្នុងករណីទីភ្នាក់ងារមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍នេះទេ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចបញ្ជូនសំណុំរឿងទៅតុលាការ ។

**មាត្រា ៥៦.-**

បទល្មើសពាក់ព័ន្ធទៅនឹងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**មាត្រា ៥៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥៨.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩

*នស/រកម/១២០៩/០២៤*

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ហត្ថលេខា

អ៊ិត សំហេង

លេខ: ១០៥៩ ច.ល
ចំលងចេញពីច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល